# សង្កេតការណ៍

១៩

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

ខែមករា ឆ្នាំ២០១៣



## មាតិកា


សវនាការស្តាប់សក្ខីកម្ម

មាស សាវ៉ាន់ ២

អោ វី និង ចៅ នី ១០

ទឹង សុខា ១៧

ពេជ ស្រីផល និង គឹម វ៉ាន់ឌី ២៥

ហ៊ុន ឈុនលី ៣៤

ផាន វ៉ាន ៤៥

ដេនីស អាឡេងស្ទូ ៥១

ស្ទួន កានិល ៥៧



ក្រុមសង្កេតការណ៍ ៖

ឆាយ ឈុនលី, លឹម ជ័យទត្ត

ឌី សុជាតា, និង ចាន ប្រាថ្នា


រូបថតក្មេងនៅប្រាសាទអង្គរវត្ត ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កុមារកម្ពុជារាប់សែននាក់ គឺជាកុមារកំព្រា ។ រូបថតនេះថតនៅក្នុងឆ្នាំ១៩៧៩ ដោយកងទ័ពវៀតណាម (ខេត្តសៀមរាប)

មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org



មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យកំពុងអមដំណើរប្រមុខរដ្ឋនៃប្រទេសភូមា នេ វីន នៅក្នុងដំណើរទស្សនកិច្ច
មកប្រទេសកម្ពុជានៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការលើសំណុំរឿង០០២ : ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដំណាក់កាលទី១ និងទី២ និងការសម្លាប់អតីតទាហាន លន់ នល់

## ថ្ងៃទី១៧ ខែវិច្ឆិកា ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២

*ឌី សុដាតា, ឆាយ ឈុនលី, និង លឹម ជ័យទត្ត*

ចាប់ពីថ្ងៃទី១៧ ខែវិច្ឆិកាដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តបើកសវនាការដោយកោះហៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១០រូប ដើម្បីសួរដេញដោលអង្គហេតុទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដំណាក់កាលទី១ និងដំណាក់កាលទី២ ដោយរបបខ្មែរក្រហម និងការសម្លាប់អតីតទាហាននៃរដ្ឋការលន់ នល់ ។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង១០រូប រួមមាន៖ ទី១) ដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន់, ទី២) ដើមបណ្តឹងរដ្ឋប្បវេណី ថៅ នី, ទី៣) ដើមបណ្តឹងរដ្ឋប្បវេណី អោ រី, ទី៤) ដើមបណ្តឹងរដ្ឋប្បវេណី ទីង សុខា, ទី៥) ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល, ទី៦) ដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី, ទី៧) សាក្សី ហ៊ុន ឈុនលី, ទី៨) សាក្សី ផាន វ៉ាន, ទី៩) ដើមបណ្តឹងរដ្ឋប្បវេណី ដេនីស អាហ៊ុងសូ និងទី១០) សាក្សី សួន កានិល ។

សវនាការសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង១០រូប បានប្រព្រឹត្តទៅ ខណៈពេលដែលជនជាប់ចោទ អៀង សារី កំពុងប្រឈមនឹងបញ្ហាសុខភាពធ្ងន់ធ្ងរ ដោយពុំអាចចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់បាន ។ ទោះបីយ៉ាងណាក៏ដោយ អៀង សារី នៅតែបន្តចូលរួមស្តាប់សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលចូលមកផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីខាងក្រោមសាលសវនាការ ដែលរៀបចំឡើងដោយមន្ត្រីរដ្ឋបាលរបស់តុលាការដែរ ។

តាមនីតិវិធីដែលកំណត់ដោយអង្គជំនុំជម្រះ ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវបានប្រព្រឹត្តទៅតាមលំដាប់លំដោយ ដោយចាប់ផ្តើមពីក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសហព្រះរាជអាជ្ញា និងចុងក្រោយ គឺមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីក្រុម ។ ដូចជាសវនាការមុនៗដែរ មេធាវីការពារក្តីឲ្យជនជាប់ចោទពុំមានសំណួរច្រើនដើម្បីសាកសួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។

នៅចុងបញ្ចប់នៃការសួរដេញដោល អង្គជំនុំជម្រះបានផ្តល់ឱកាសជូនដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីថ្លែងទុក្ខសោក ការបាត់បង់ និងផលប៉ះពាល់ដោយសារតែរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងអំឡុងពេលនៃសវនាការស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង១០រូប មានការចូលរួមតាមដានដោយផ្ទាល់ពីសំណាក់ប្រជាជន សិស្ស និស្សិត និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ប្រមាណ៣០០០នាក់ មកពីបណ្តាខេត្តមួយចំនួនដូចជាកណ្តាល កំពង់ចាម តាកែវ កំពង់ធំ និងព្រៃវែង ។



ដើមបណ្តឹងរដ្ឋប្បវេណី និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងអំឡុងពេលសវនាការថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១
(ប្រភពរូបថត៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់

## ថ្ងៃទី១៧ និង២២ ខែវិច្ឆិកា ឆ្នាំ២០១២

នៅរសៀលថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២ បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សី ប៉េជុយ ជីបសែ អង្គជំនុំជម្រះបានបន្តស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ដែលជាជនរងគ្រោះដោយសារការជម្លៀសប្រជាជនដោយយោធាខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ បានប្រព្រឹត្តទៅដោយចំណាយពេលចំនួនពីរថ្ងៃ គឺថ្ងៃទី១៤ និងថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ ដោយផ្តោតជាសំខាន់លើព្រឹត្តិការណ៍នៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ កាលពី៣៨ឆ្នាំមុន ។ អង្គហេតុទាក់ទងនឹងការជម្លៀសប្រជាជន គឺជាផ្នែកមួយនៃសវនាការលើសំណុំរឿង០០២/០១ ដែលអង្គជំនុំជម្រះកំពុងលើកយកមកជំនុំជម្រះ បន្ទាប់ពីបញ្ចប់ការដេញដោលលើអង្គហេតុទាក់ទងនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រព័ន្ធទំនាក់ទំនងរដ្ឋបាល និងការងារ និងប្រព័ន្ធទំនាក់ទំនងយោធានៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយហេតុថាសវនាការនេះ ជាសវនាការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះនីតិវិធីតម្រូវឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកចាប់ផ្តើមចោទសួរមុនភាគីផ្សេងទៀត ដែលខុសគ្នាពីការសួរដេញដោលចំពោះសាក្សី ដែលជាធម្មតា គឺសហព្រះរាជអាជ្ញាជាអ្នកចាប់ផ្តើមមុន ។

តាមការអង្កេត ក្នុងចំណោមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម មានតែក្រុមមេធាវីការពារក្តី នួន ជា ប៉ុណ្ណោះដែលបានចោទសួរដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ។ រីឯមេធាវីការពារក្តីជនជាប់ចោទពីរក្រុមផ្សេងទៀត មិនមានសំណួរដើម្បីចោទសួរទេ ដោយសារសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមិនមានជាប់ទាក់ទងដោយផ្ទាល់ជាមួយនឹងបទចោទប្រកាន់លើកូនក្តីរបស់ខ្លួន ។

នៅក្នុងអំឡុងពេលនៃសវនាការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ មានប្រជាជន និងយុវសិស្សដែលកំពុងសិក្សានៅតាមបណ្តាវិទ្យាល័យផ្សេងៗប្រមាណ៧០០នាក់ ដែលមកពីខេត្តតាកែវ កំពង់ចាម ព្រៃវែង បានចូលរួមស្តាប់នៅក្នុងបន្ទប់សវនាការផ្ទាល់ ។

### ១) ប្រវត្តិសាវតាររបស់ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់

មុនពេលប្រគល់វេទិកាសួរដេញដោលជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានសាកសួរទាក់ទងនឹងប្រវត្តិសាវតារសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ។ ឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះ មាស សារ៉ាន់ បានជម្រាបថា លោកកើតនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៤៩ និងមានទីកន្លែងកំណើតនៅឃុំបុសមន ស្រុករំដួល ខេត្តស្វាយរៀង ។ បច្ចុប្បន្នរស់នៅទីក្រុងភ្នំពេញ និងបម្រើការជាគ្រូពេទ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា លោកមានឪពុកឈ្មោះ មាស ខាវ និងម្តាយឈ្មោះ អ៊ុំ ឈាង និងភរិយាឈ្មោះ មាន គឹមលីត ប៉ុន្តែបានបាត់ខ្លួននៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧



ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខែមេសា ឆ្នាំ១៩៧៥ ។

មុនពេលបញ្ចប់ការសាកសួររបស់ខ្លួន ប្រធានអង្គជំនុំជម្រះ និល ណុន បានជម្រាបដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ថា ៖

*"ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី នៅទីបំផុតនៃការសួរដេញដោល លោកអាចថ្លែងរៀបរាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខវេទនា ឬព្យសនកម្មដែលកើតមានឡើងចំពោះលោក ដែលមានជាអាទិ៍ ការខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ សម្ភារៈ ហើយព្យសនកម្មនោះ ជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានឡើងពិតប្រាកដ រហូតដល់បច្ចុប្បន្ន ដែលនាំឲ្យលោកសម្រេចចិត្តប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទដែលប៉ះពាល់ចំពោះលោក នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ"* ។

បន្ទាប់មក ប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់។

## ២) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

### ២.ក) ស្ថានភាពមុនឆ្នាំ១៩៧៥

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានសញ្ជាតិបារាំង គឺលោកស្រី គ្រីស្ទីន ម៉ាទីណូ បានចាប់ផ្តើមសំណួរដំបូងរបស់ខ្លួនទាក់ទងនឹងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងស្ថានភាពទីក្រុងភ្នំពេញ នៅមុនពេលនៃការចូលមកដល់របស់យោធាខ្មែរក្រហមក្នុងឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ បានបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៦៩ លោកបានចូលរៀននៅសាលាគិលានុបដ្ឋាករដ្ឋ និងបានបញ្ចប់ការសិក្សានៅក្នុងឆ្នាំ១៩៧២ ហើយចូលមកបម្រើការនៅមន្ទីរពេទ្យព្រះកេតុមាលានៅទីក្រុងភ្នំពេញ ។ ប៉ុន្តែមួយរយៈក្រោយមក ត្រូវបានផ្លាស់ទៅបម្រើការជាពេទ្យទាហាន នៅសុីសុផុន រយៈពេល១៨ខែ ដោយសារជាកាតព្វកិច្ចដែលរដ្ឋតម្រូវឲ្យត្រូវតែធ្វើ ។ នៅទីនោះ មាស សារ៉ាន់ បានរៀបការជាមួយនឹងប្រពន្ធរបស់ខ្លួនដែលជាអ្នកស្រុកសុីសុផុន ។ នៅចុងឆ្នាំ១៩៧៤ បន្ទាប់ពីចប់កាតព្វកិច្ចជាពេទ្យទាហានរយៈពេល ១៨ខែ ខ្លួននិងភរិយា ដែលកំពុងមានផ្ទៃពោះបានត្រឡប់មករស់នៅទីក្រុងភ្នំពេញវិញ ។ នៅពេលមកដល់ទីក្រុងភ្នំពេញ ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ត្រូវបានរដ្ឋចាត់តាំងឲ្យមកបម្រើការនៅ បុរីកីឡាដែលមានកន្លែងវះកាត់ចំនួន៥ ដើម្បីទទួលព្យាបាលអ្នករងរបួស ប៉ុន្តែទីនោះមិនមែនជាមន្ទីរពេទ្យទេ គឺគ្រាន់តែជាកន្លែងសម្រាប់ព្យាបាលបណ្តោះអាសន្នដែលគ្រប់គ្រងដោយទាហានតែប៉ុណ្ណោះ ។ លោកបន្តទៀតថា មានអ្នករបួសជាច្រើន ទាំងទាហាន ទាំងជនសុីវិល ដែលរងគ្រោះដោយសារគ្រាប់ផ្លោង និងគ្រាប់កាំភ្លើង សុទ្ធសឹងតែត្រូវបានដឹកបញ្ជូនមកព្យាបាលនៅបុរីកីឡាទាំងអស់ ។

### ២.ខ) ស្ថានភាពនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ឆ្លើយតបនឹងសំណួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលសួរថា តើនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរពេទ្យមានត្រៀមលក្ខណៈចំពោះសភាពការណ៍ណាមួយដែលនឹងកើតឡើងដែលឬទេ? មាស សារ៉ាន់ បានបញ្ជាក់ថា មន្ទីរពេទ្យដែលខ្លួនធ្វើការ មិនបានត្រៀមលក្ខណៈចំពោះ សភាពការណ៍ណាមួយដែលអាចនឹងកើតឡើងទេ ។ ប៉ុន្តែនៅរយៈពេលប៉ុន្មានថ្ងៃមុនការចូលមកដល់របស់យោធាខ្មែរក្រហម សភាពការណ៍នៅទីក្រុងភ្នំពេញមានលក្ខណៈពិបាកនឹងរៀបរាប់ ដោយសារតែមនុស្សជាច្រើនស្ថិតនៅក្នុងសភាពភ័យខ្លាច មានប្រជាជនជាច្រើនបានទទួលរងរបួស និងមនុស្សមួយចំនួន បានស្លាប់បាត់បង់ជីវិតដោយសារតែការបាញ់ផ្លោងរវាងទាហាន លន់ នល់ និងខ្មែរក្រហម ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបន្តទៀតថា នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខណៈពេលកំពុងធ្វើការនៅជាន់ខាងលើនៃអគារនៅបុរីកីឡា លោកបានឃើញផ្សែង និងភ្លើងឆាបឆេះយ៉ាងសន្ធោសន្ធៅនៅមុំស្ពានជ្រោយចង្វារ ហើយខ្លួនគិតថាការប្រយុទ្ធគ្នានេះអាចនឹងចប់នៅក្នុងពេលឆាប់ៗ ។ ចំណែកឯអ្នកជំងឺ ដែលបញ្ជូនមកកន្លែងរបស់ខ្លួនមានចំនួនកាន់តែច្រើនឡើងៗ មានទាំងក្មេង ទាំងចាស់ ហើយអ្នកខ្លះបានស្លាប់ ដោយមិនមានបងប្អូនមកយកទៅធ្វើបុណ្យទេ ។ មាស សារ៉ាន់ បានរៀបរាប់អំពីព្រឹត្តិការណ៍ជាក់ស្តែងដែលខ្លួនមិនអាចបំភ្លេចបាន ដោយសម្រក់

ទឹកភ្នែកនៅចំពោះមុខអង្គជំនុំជម្រះ នៅពេលព្យាយាមរំឭកអំពីទិដ្ឋភាពក្មេងស្រីអាយុ៨ឆ្នាំមួយរូប ដែលរងរបួសធ្ងាយពោះ ហើយលោកបានជួយព្យាបាល និងប្អូនរបស់ក្មេងស្រីនោះបានដេកស្លាប់នៅក្បែរខ្លួននាង ។ នៅពេលឃើញស្ថានភាពក្មេងស្រីនេះ លោកបានព្យាយាមជួយដេរផ្ចិតពោះ និងព្យួរសេរ៉ូមឲ្យដើម្បីសង្គ្រោះជីវិត ហើយមុខរបស់ក្មេងតូចនោះស្ថិតនៅក្នុងអារម្មណ៍របស់លោកជានិច្ច ដោយសារក្មេងស្រីនោះបានចាប់រកភរិយារបស់ខ្លួន ដោយសារតែលោកគិតថា ខ្មែរក្រហមអាចនឹងជួយព្យាបាលអ្នកជំងឺទាំងអស់ដែលកំពុងរងចាំការជួយសង្គ្រោះនៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបន្ថែមថា នៅតាមផ្លូវចាកចេញពីមន្ទីរពេទ្យទៅកន្លែងដែលភរិយារបស់ខ្លួនស្នាក់នៅ (មុំផ្លូវប៉ាស្ទ័រ) គឺមានការបាញ់ប្រយុទ្ធគ្នាយ៉ាងខ្លាំង ដែលត្រូវបង្ខំចិត្តដើរវាងតាមផ្លូវវត្តមហាមន្ត្រី ។ ប៉ុន្តែ មាស សារ៉ាន់ នៅតែពុំអាចជួប



ទិដ្ឋភាពយោធាខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

អាវរបស់លោក និងសុំឲ្យលោកជួយនាំយកនាងទៅជាមួយ ខណៈពេលដែលស្ថានភាពក្នុងមន្ទីរពេទ្យមានសភាពកាន់តែច្របូកច្របល់ដោយសារតែខ្មែរក្រហមបង្ខំឲ្យចាកចេញពីទីនោះ ។ មាស សារ៉ាន់ បន្តថា លោកមិនដឹងថាតើគួរត្រូវធ្វើបែបណាឡើយ ព្រោះម្យ៉ាងត្រូវគិតដល់ភរិយារបស់ខ្លួនដែលកំពុងមានផ្ទៃពោះ ៨ខែនៅឯផ្ទះ និងម្យ៉ាងទៀតគឺអ្នកជំងឺជាច្រើន ដែលកំពុងត្រូវការអ្នកព្យាបាល ខណៈពេលដែលសភាពការណ៍កំពុងចលាចលកាន់តែខ្លាំង ។ ប៉ុន្តែទីបំផុត លោកសម្រេចចិត្តចាកចេញទៅភរិយារបស់ខ្លួន ដោយសារខ្មែរក្រហមបានបង្ខំឲ្យលោកចាកចេញពីទីក្រុងភ្នំពេញរយៈបីថ្ងៃ ព្រោះខ្លាចយន្តហោះរបស់សហរដ្ឋអាមេរិកមកទម្លាក់គ្រាប់បែក ។

### ២.ក) ការចាកចេញពីទីក្រុងភ្នំពេញ

ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបន្តរៀបរាប់ជូនអង្គជំនុំជម្រះទៀតថា ខ្លួនចាកចេញពីទីក្រុងភ្នំពេញ តាមផ្លូវជាតិលេខ១ ដោយត្រូវឆ្លងកាត់ស្ពានព្រះមុន្នីវង្សដែលពោរពេញទៅដោយមនុស្សយ៉ាងច្រើនកកកុញ ។ បន្ទាប់មកត្រូវរង់ចាំនៅត្រើយ

ខាងកើតស្ពាននេះរយៈកន្លះខែ មុនពេលចាកចេញទៅរកភរិយារបស់ខ្លួននៅស្រុកសេរីសោភ័ណ្ឌនៅខេត្តបាត់ដំបង (បច្ចុប្បន្នស្រុកសេរីសោភ័ណ្ឌស្ថិតនៅខេត្តបន្ទាយមានជ័យ) ។

ឆ្លើយតបនឹងសំណួរដែលសួរថា ហេតុអ្វីបានជាមិនព្រមចាកចេញទៅខេត្តស្វាយរៀងដែលជាស្រុកកំណើតតែម្តង នៅអំឡុងពេលវង់ចាំត្រង់ត្រើយខាងកើតស្ពានព្រះមុន្នីវង្ស? មាស សារ៉ាន់ បានអះអាងថា មូលហេតុដែលមិនបន្តដំណើរទៅខេត្តស្វាយរៀងដែលជាស្រុកកំណើត ដោយសារខ្លួនគិត ថាភរិយារបស់ខ្លួននឹងមិនធ្វើដំណើរទៅខេត្តស្វាយរៀងទេ ។ ដូច្នេះហើយខ្លួនក៏សម្រេចចិត្តទៅតាមរកភរិយានៅខេត្តបាត់ដំបងដែលជាស្រុកកំណើតរបស់ភរិយាវិញ ។ លោកបន្តថា ក្រោយរយៈពេលបីថ្ងៃ គឺមានការអំពាវនាវពីសំណាក់ក្រុមខ្មែរក្រហមឲ្យអ្នកដែលធ្លាប់បម្រើការនៅក្នុងរបបចាស់ឲ្យត្រឡប់ចូលមកទីក្រុងភ្នំពេញវិញ ដើម្បីចូលរួមកសាងប្រទេសឡើងវិញជាមួយនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលនោះមានមនុស្សជាច្រើនបានត្រឡប់ចូលភ្នំពេញតាមការអំពាវនាវនេះ ប៉ុន្តែអ្នកទាំងនោះមិនឃើញត្រឡប់ចេញមកវិញឡើយ ។ ឃើញដូច្នេះខ្លួនមានការព្រួយបារម្ភ និងបានសម្រេចចិត្តមិនត្រឡប់ចូលទីក្រុងភ្នំពេញទេ ហើយទៅស្វែងរកភរិយានៅខេត្តបាត់ដំបងវិញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ ។

នៅពេលទៅដល់ខេត្តបាត់ដំបង មាស សារ៉ាន់ បានជួបនឹងឪពុកម្តាយក្មេករបស់ខ្លួន ប៉ុន្តែមិនបានឃើញភរិយានៅទីនោះទេ ដែលធ្វើឲ្យខ្លួនមានការខកចិត្តយ៉ាងខ្លាំង ។ លោកបានរៀបរាប់ទៀតថា នៅថ្ងៃដំបូងម្តាយក្មេករបស់ខ្លួនបានស្នើឲ្យខ្លួនប្រាប់ពីប្រវត្តិរូបពិតប្រាកដទៅដល់ប្រធានភូមិនៅទីនោះ ដោយសារតែអង្គការមានភ្នែកដូចម្នាស់ ដែលមិនអាចលាក់ប្រវត្តិរូបរបស់ខ្លួនបានទេ ។ បន្ទាប់ពីប្រាប់ពីប្រវត្តិរូបពិតរបស់ខ្លួនដែលជាអតីតទេព្យទាហានក្នុងរដ្ឋការ លន់ នល់ បីថ្ងៃក្រោយមក មាស សារ៉ាន់ ត្រូវបានយោធាខ្មែរក្រហមហៅទៅជួបដោយប្រាប់ថាឲ្យជួយមើលថ្នាំពេទ្យមកពីប្រទេសចិននៅម៉ោង១០យប់ ។ ប៉ុន្តែនៅពេលទៅដល់កម្មាភិបាលខ្មែរក្រហមបានចាប់ខ្លួនចងក្នុងគោលបំណងយកទៅសម្លាប់ ប៉ុន្តែដោយសារមានការធានាពីអ្នកភូមិទើបខ្មែរក្រហមព្រមដោះលែងខ្លួនឲ្យចេញមកវិញ ។ មាស សារ៉ាន់ បានបន្តថា ក្រោយមកខ្លួនត្រូវបានចាប់ខ្លួនបញ្ជូនទៅស្រុកសេរីសោភ័ណជាមួយនឹងអ្នកផ្សេងទៀតចំនួន១២គ្រួសារ ។ នៅទីនោះខ្លួនបានទទួលរងទារុណកម្មយ៉ាងដំណំរហូតដល់សន្លប់ ដោយសារតែខ្លួនសារភាពថាធ្លាប់ធ្វើជាពេទ្យនៅក្នុងរបបចាស់ ។ ជាសំណាងល្អ ខ្មែរក្រហមពុំបានយកខ្លួនទៅសម្លាប់ ហើយបែរជាបញ្ជូនមកភូមិវិញ ។ ប៉ុន្តែនៅពេលត្រឡប់មកពីស៊ីសុផុនវិញ អ្នកភូមិទាំងអស់ចាប់ផ្តើមមានការភ័យខ្លាចក្នុងការទាក់ទងជាមួយនឹងខ្លួន ដោយសារតែខ្លួនត្រូវបានអង្គការចាត់ទុកថាជាប្រជាជនថ្មី ។

ឆ្លើយតបនឹងសំណួររបស់មេធាវី ម៉ាទីណូ ដែលសួរថាតើលោកធ្លាប់បានឃើញខ្មែរក្រហមយកមនុស្សទៅសម្លាប់ ឬធ្វើទារុណកម្មដែរឬទេ? មាស សារ៉ាន់ បានបញ្ជាក់ថា លោកធ្លាប់បានឃើញយោធាខ្មែរក្រហមចាប់មនុស្សម្នាក់ដែលលោកធ្លាប់ស្គាល់យកទៅសម្លាប់ និងធ្លាប់ឃើញបុរសម្នាក់ដែលបានប្រព្រឹត្តខុសសីលធម៌ជាមួយនឹងនារីម្នាក់ទៀតដែលមិនមែនជាប្រពន្ធរបស់ខ្លួន ត្រូវបានកម្មាភិបាលខ្មែរក្រហមចាប់យកមកធ្វើទារុណកម្មនៅចំពោះមុខប្រជាជនទាំងអស់ ។

### ៣) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ជនជាតិបារាំង គឺលោក វ៉ាំងសង់ ដឺវ៉ាល់ ដេស្មាឯល បានចំណាយពេលប្រហែល២០នាទី ដើម្បីសួរបញ្ជាក់ឡើងវិញ ទាក់ទងនឹងចម្លើយដែលដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ បានឆ្លើយតបចំពោះសំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ភាគច្រើននៃសំណួររបស់តំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ បានផ្តោតជាសំខាន់លើការជួយព្យាបាលអ្នកជំងឺនៅបុរីកីឡា និងទិដ្ឋភាពនៅទីនោះក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួរទាំងនោះ មាស សារ៉ាន់ បានបញ្ជាក់ថា នៅពេលនោះមានអ្នករបួសជាច្រើនត្រូវបានបញ្ជូនទៅព្យាបាលនៅបុរីកីឡា ហើយអ្នកដែលស្លាប់នៅមុនពេលខ្មែរក្រហមចូលមកដល់ភ្នំពេញមួយថ្ងៃក្នុងអគារបុរីកីឡាមិនមាននរណាយកចេញឡើយ ។ លោកបានពិពណ៌នាទៀតថា អ្នកដែលរងរបួសល្មមៗគឺ អាចដើរចេញដោយខ្លួនឯងបាន ប៉ុន្តែអ្នកផ្សេងទៀតដែលរងរបួសធ្ងន់ធ្ងរ គឺត្រូវដេក

រង់ចាំនៅលើគ្រែ ។ នៅពេលមានការបញ្ជាឲ្យអ្នករបួសចេញពីបុរីកីឡាពីសំណាក់កម្មាភិបាលខ្មែរក្រហម ខ្លួនមានអារម្មណ៍ថា ប្រហែលជាខ្មែរក្រហមនឹងយកអ្នកជំងឺ និងអ្នករងរបួសទាំងនោះទៅព្យាបាលបន្ត ប៉ុន្តែខ្មែរក្រហមមិនបានយកអ្នកទាំងនោះទៅព្យាបាលបន្តឡើយ ។ មាស សារ៉ាន់ បានបន្ថែមថា អ្វីដែលធ្វើឲ្យខ្លួននៅតែមិនអស់ចិត្ត គឺនៅពេលដែលមានក្មេងស្រីអាយុ៨ឆ្នាំម្នាក់ដែលរងរបួសធ្លាយពោះបានសុំឲ្យខ្លួនយកនាងទៅជាមួយ ប៉ុន្តែខ្លួនមិនអាចជួយនាង និងយកនាងចេញពីទីនោះបាន ។


កុមារកម្ពុជាដែលឪពុកម្តាយរបស់ខ្លួនបានស្លាប់នៅអំឡុងពេលនៃរបបខ្មែរក្រហម ។ រូបថតនេះថតនៅក្នុងឆ្នាំ១៩៧៩ ដោយកងទ័ពវៀតណាម (ខេត្តសៀមរាប) (ប្រភព: មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឆ្លើយតបនឹងសំណួរតំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ ដែលសួរទាក់ទងនឹងសាកសពដែលប្រទះឃើញនៅជិតស្ពានព្រះមុន្នីវង្ស មាស សារ៉ាន់ បានអះអាងថា នៅពេលដែលខ្លួនត្រូវបានជម្លៀសមកដល់ស្ពានព្រះមុន្នីវង្ស ខ្លួនបានឃើញមានសាកសពបុរសពីរនាក់ ប៉ុន្តែពុំមែនស្លៀកពាក់ជាទាហានទេ គឺជាជនស៊ីវិលធម្មតា ។ ចំពោះសំណួរដែលសួរថា តើលោកធ្លាប់បានទទួលដំណឹងអ្វីពីភរិយារបស់លោកដែរឬទេ? ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានឆ្លើយតបទាំងទឹកមុខស្រពោនថា ចាប់តាំងពីថ្ងៃដែលខ្លួនត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មក ខ្លួនពុំដែលបានទទួលដំណឹងពីភរិយា ដែលមានផ្ទៃពោះ៨ខែទាល់តែសោះរហូតមកដល់ពេលបច្ចុប្បន្ននេះ ។ លោកពុំបានដឹងថា តើប្រពន្ធរបស់លោកត្រូវបានជម្លៀស ឬនាំយកចេញទៅទីណាទេ ។

## ៤) ការសួរដេញដោលដោយចៅក្រមអន្តរជាតិ ហ្សង់ម៉ាក ឡាវីញ

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាបានបញ្ចប់ការសួរដេញ

ដោលរបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនទៅក្រុមអន្តរជាតិ ហ្សង់ម៉ាក ឡាវ៉ែញ ដើម្បីចោទសួរសំណួរមួយចំនួន ។ ចៅក្រម ឡាវ៉ែញ បានសួរទាក់ទងនឹងការថែទាំ និងព្យាបាលអ្នកជំងឺ ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ដែលធ្លាប់បានឃើញពីស្ថានភាពនោះផ្ទាល់ភ្នែកធ្វើការពណ៌នាបន្ថែម ។ ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះពុំមានថ្នាំសង្កូវគ្រាប់គ្រាន់សម្រាប់ព្យាបាលអ្នកជំងឺដែលរងរបួសទេ ហើយស្ថានភាពនៅថ្ងៃទី១៧ ខែមេសា គឺមានសភាពកាន់តែលំបាកខ្លាំងជាងនេះទៅទៀត ។ លោកបន្តថា នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទំនិញទាំងអស់បានឡើងថ្លៃ ហើយមានមនុស្សជាច្រើនរត់ចូលមករស់នៅក្នុងទីក្រុងភ្នំពេញ ដែលបណ្តាលឲ្យមានការខ្វះខាតស្បៀងអាហារដើម្បីផ្គត់ផ្គង់ និងប្រជាជនពុំមានអាហារហូបចុកគ្រប់គ្រាន់ឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបន្ថែមថា ចាប់តាំងពីថ្ងៃដែលខ្មែរក្រហមបានជម្លៀសខ្លួនចេញពីទីក្រុងភ្នំពេញ ខ្មែរក្រហមពុំដែលមានអ្វីមកឲ្យខ្លួនសូម្បីតែបន្តិច ។

### ៥) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា

ដូចដែលបានគូសបញ្ជាក់នៅខាងដើម ដោយសារក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី និង ខៀវ សំផន ពុំមានសំណួរដើម្បីចោទសួរដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ដូច្នេះមានតែក្រុមមេធាវីការពារក្តី នួន ជា មួយប៉ុណ្ណោះ ដែលបានចោទសួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី ។ នៅអំឡុងពេលនៃការសួរដេញដោល មានបញ្ហាជាច្រើនត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តី នួន ជា ទាក់ទងនឹងការអនុវត្តប្រព័ន្ធច្បាប់ផ្សេងគ្នានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលតម្រូវឲ្យអង្គជំនុំជម្រះត្រូវចំណាយពេលច្រើនដើម្បីដោះស្រាយបញ្ហាទាំងនោះ ជាជាងការស្តាប់ការសួរដេញដោល ។

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោក អេនឌ្រូ អ៊ីនូហ៊ីវ្ស បានសាកសួរសំណួរជាច្រើនទាក់ទងនឹងប្រវត្តិសាវតារ និងស្ថានភាពនៃទីក្រុងភ្នំពេញនៅមុនពេលនៃការជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ មេធាវី អ៊ីនូហ៊ីវ្ស បានសួរថា ចំពោះស្ថានភាពខ្វះខាតស្បៀងអាហារ បើតាមការយល់ដឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី តើការខ្វះខាតនោះ បណ្តាលមកពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ឬដោយសារសង្គ្រាមស៊ីវិលរវាងខ្មែរក្រហម និងទាហានលន់ នល់? ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ បានបញ្ជាក់ថា នៅអំឡុងពេលដែលខ្លួនកំពុងរៀនសូត្រនៅក្នុងទីក្រុងភ្នំពេញ អាហារ និងរបស់របរនៅទីក្រុងភ្នំពេញមានតម្លៃកាន់តែខ្ពស់ទៅៗ ប៉ុន្តែពុំទាន់ខ្វះខាតអាហារបរិភោគនៅឡើយទេ ។ ចំពោះសំណួរដែលសួរថា តើហេតុអ្វីបានជាមានជនភៀសខ្លួនច្រើនរត់ចូលភ្នំពេញ? មាស សារ៉ាន់ បានឆ្លើយថាដោយសារតែការប្រយុទ្ធគ្នាកាន់តែកើនឡើង ហើយខ្មែរក្រហមបានហ៊ុមព័ទ្ធជុំវិញទីក្រុងភ្នំពេញ ដែលធ្វើឲ្យប្រជាជនចូលមកទីក្រុងមានកាន់តែច្រើនឡើងៗ និងអ្នកខ្លះរស់នៅតាមផ្ទះសាច់ញាតិរបស់ខ្លួន និងអ្នកខ្លះរស់នៅតាមវត្ត និងអ្នកខ្លះរស់នៅតាមផ្លូវ ។

**បញ្ហាផ្សេងៗ ៖**

នៅអំឡុងពេលនៃការសួរដេញដោល មេធាវី អ៊ីនូហ៊ីវ្ស បានប្រើប្រាស់វិធីសាស្ត្រនៃការសួរសំណួររបស់ខ្លួនចំពោះ មាស សារ៉ាន់ ដោយចាប់ផ្តើមជាមួយនឹងពាក្យថា «តើត្រឹមត្រូវទេ?» ឬ«តើលោកយល់ស្របជាមួយខ្ញុំទេ?»ជាច្រើនដង ។ ឧទាហរណ៍ មេធាវី អ៊ីនូហ៊ីវ្ស បានចោទសួរដើមបណ្តឹងរដ្ឋប្បវេណីថា «តើលោកយល់ស្របជាមួយខ្ញុំទេ ដែលថាប្រជាជននៅទីក្រុងនៅខែមេសា ឆ្នាំ១៩៧៥ មានការកើនឡើងចំនួនទ្វេរដង?» និងឧទាហរណ៍មួយផ្សេងទៀត «តើត្រឹមត្រូវដែរទេ ដែលថានៅមុនពេលលោកចេញទៅស៊ីសុផុននៅឆ្នាំ១៩៧៣ នៅទីក្រុងកំពុងប្រឈមមុខនឹងការព្យាបាលជំងឺដោយសារការផ្គត់ផ្គង់ថ្នាំពេទ្យ និងឧបករណ៍ផ្សេងៗកំពុងមានបញ្ហា?» ។ ការសួរសំណួរដូច្នេះ បានទទួលរងការជំទាស់ពីសំណាក់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ ដឺវ៉ាល់ ដេស្នាឯល ។ តំណាងសហព្រះរាជអាជ្ញាបានអះអាងថា វិធីសាស្ត្រក្នុងការសួរសំណួររបស់មេធាវីការពារក្តី នួន ជា ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តើមជាមួយនឹងពាក្យថា «តើត្រឹមត្រូវទេ?» ជាច្រើនដង គឺជាការសួរសំណួរដែលមានលក្ខណៈនាំមុខដើមបណ្តឹងរដ្ឋប្បវេណីឲ្យឆ្លើយយល់ស្របតាមខ្លួន

ហើយតំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ ក៏បានស្នើសុំឲ្យក្រុមមេធាវីការពារក្តី នួន ជា រៀបចំសំណួររបស់ខ្លួនឡើងវិញ ។ ឆ្លើយតបនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា មេធាវី អ៊ីនូហ៊្សី បានបញ្ជាក់ថា ការសួរសំណួរដូច្នេះ គឺដោយសារខ្លួនយល់ថាដើមបណ្តឹងរដ្ឋប្បវេណីគឺជាបុគ្គលដែលមានចំណេះដឹង និងមានសមត្ថភាពអាចឆ្លើយតបនឹងសំណួរដែលខ្លួនចោទសួរបាន ។

បន្ទាប់ពីបានពិភាក្សាក្នុងចំណោមចៅក្រមអង្គជំនុំជម្រះ ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានសម្រេចថា ការកត់សម្គាល់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិចំពោះវិធីសាស្ត្រក្នុងការចោទសួររបស់មេធាវីការពារក្តី គឺមានភាពសមស្រប និងបង្គាប់ឲ្យមេធាវីការពារក្តី នួន ជា រៀបចំវិធីសាស្ត្រក្នុងការសួរសំណួររបស់ខ្លួនឡើងវិញ ។ ចៅក្រម និល ណុន បានសង្កត់ធ្ងន់ថា សំណួរនាំមុខ ឬសំណួរដែលធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីឆ្លើយបញ្ជាក់លើសេចក្តីសន្និដ្ឋានរបស់ភាគី គឺជាការមិនត្រឹមត្រូវ ។

ឆ្លើយតបនឹងការសម្រេចរបស់អង្គជំនុំជម្រះ មេធាវី អ៊ីនូហ៊្សី បានអះអាងថា ការសួរសំណួរឲ្យសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបញ្ជាក់ គឺជាភាពចាំបាច់មួយដែលត្រូវបានអនុវត្តជាទូទៅនៅក្នុងប្រព័ន្ធច្បាប់ ខំមិនឡ (Common Law) និងថាសំណុំរឿង០០២ គឺជាសំណុំរឿងដែលមានទំហំធំ ហេតុនេះមេធាវីការពារក្តីមានការលំបាកក្នុងការសួរសំណួរដែលមានលក្ខណៈបើក ។ ប៉ុន្តែប្រធានអង្គជំនុំជម្រះបានពន្យល់មេធាវី អ៊ីនូហ៊្សី វិញថា នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ប្រភពច្បាប់ដែលត្រូវបានយកមកអនុវត្តគឺយកចេញពីប្រព័ន្ធច្បាប់ស៊ីវិល(Civil Law) ហើយសំណួរដែលមានលក្ខណៈនាំមុខគឺមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់នៅក្នុងសវនាការចាប់តាំងពីការចាប់ផ្តើម ។ ម៉្យាងវិញទៀត ការធ្វើសេចក្តីសន្និដ្ឋានដោយភាគី ហើយស្នើដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីឲ្យធ្វើការបញ្ជាក់ គឺត្រូវបានហាមឃាត់ជាដាច់ខាតនៅក្នុងនីតិវិធីដែលមានចែងក្នុងប្រព័ន្ធច្បាប់ស៊ីវិល ។ ចៅក្រមបានសង្កត់ធ្ងន់ទៀតថា អនុលោមតាមកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានអនុម័តយល់ព្រមយកច្បាប់កម្ពុជាមកប្រើប្រាស់ជាអតិបរមានៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មេធាវី



**កម្មាភិបាលពេទ្យខ្មែរក្រហមកំពុងកាត់ស្លឹកឈើ ឬសឈើ ដើម្បីយកទៅធ្វើថ្នាំព្យាបាលជំងឺ (ថតដោយ ហ្គូណា ប៊ិយស្រ្តង នៅខែសីហា ឆ្នាំ១៩៧៨) (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)**

ការពារក្តីឲ្យជនជាប់ចោទ នួន ជា នៅតែពុំយល់ស្របនឹងការលើកឡើងរបស់ប្រធានអង្គជំនុំជម្រះ និងបានស្នើឲ្យអង្គជំនុំជម្រះបង្ហាញពីយុត្តិសាស្ត្រនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលណាមួយដែលហាមឃាត់ពុំឲ្យចោទសួរសំណួរនាំមុខចំពោះសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ។ បន្ថែមពីលើនេះ មេធាវី អ៊ីនូហ៊្សី ក៏បានលើក

ឡើងដែរថា សហព្រះរាជអាជ្ញា មេធាវីការពារក្ដីជនជាប់ចោទ អៀង សារី និងចៅក្រម អង្គជំនុំជម្រះក៏ធ្លាប់បានប្រើប្រាស់សំណួរនាំមុខដើម្បីចោទសួរសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីដែរ ។ ទោះបីជាមេធាវីការពារក្ដីរូបនេះព្យាយាមលើកឡើងបន្ថែមក៏ដោយ ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ជាចុងក្រោយថា អង្គជំនុំនឹងមិនអនុញ្ញាតឲ្យមានការចោទសួរសំណួរដែលមានលក្ខណៈនាំមុខនៅចំពោះមុខអង្គជំនុំជម្រះ ឡើយ ។

**បញ្ជាក់ ៖** ប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជាត្រូវបានកំណត់យកតាមប្រព័ន្ធស៊ីវិល និងកំពុងត្រូវបានអនុវត្ត ។ ប៉ុន្តែអ្វីដែលគួរឲ្យចាប់អារម្មណ៍គឺ សាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហមនាពេលបច្ចុប្បន្នកំពុងដំណើរការនីតិវិធីរបស់ខ្លួនដោយមានការចូលរួមពីសំណាក់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ឬអ្នកច្បាប់ ដែលចេញមកពីប្រទេសដែលប្រកាន់យកប្រព័ន្ធច្បាប់ផ្សេងគ្នា ។ មានន័យថា តុលាការមួយប្រព័ន្ធច្បាប់ពីរ គឺអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលផង និងប្រព័ន្ធច្បាប់ខំមិនឡផង ។ ការណ៍នេះ បានធ្វើឲ្យកិច្ចដំណើរការនីតិវិធី ពេលខ្លះជួបប្រទះនឹងបញ្ហានៅក្នុងការអនុវត្ត ។

### ៦) ការថ្លែងសេចក្ដីទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី មាស សាវ៉ាន់

នៅមុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធីសួរដេញដោលអង្គជំនុំជម្រះបានផ្ដល់វេទិកាជូនដើមបណ្ដឹងរដ្ឋប្បវេណី មាស សាវ៉ាន់ ដើម្បីថ្លែងរៀបរាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខវេទនា ឬការទទួលរងដែលកើតឡើងចំពោះខ្លួនដោយសារឧក្រិដ្ឋកម្មដែលកើតឡើងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ខាងក្រោមនេះ គឺជាការថ្លែងរៀបរាប់ទាំងស្រុងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មាស សាវ៉ាន់ ៖

“ជម្រាបលោកប្រធាន ខ្ញុំថ្លែងអំណរគុណលោកដែលអនុញ្ញាតឲ្យខ្ញុំក្នុងរយៈពេលចុងក្រោយនេះ ។

ខ្ញុំជម្រាបអ៊ីចេះថា សវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ ខ្ញុំសង្ឃឹមថា ការដែលខ្ញុំនេះបែកបាក់ប្រពន្ធកូនរបស់ខ្ញុំ ឪពុកម្ដាយខ្ញុំ ខ្ញុំសង្ឃឹមថា តុលាការអាចរកការពិតឲ្យខ្ញុំ ។ អាចរកការពិត ខ្ញុំនៅតែសង្ឃឹមថា តុលាការនឹងរកការពិតឲ្យខ្ញុំ ពីព្រោះខ្ញុំរហូតមកដល់ឥឡូវ ខ្ញុំអត់ៗយល់ហេតុអ្វីខ្មែរក្រហមធ្វើរបៀបហ្នឹង ខ្ញុំអត់យល់ទេ ។ បាទ ខ្ញុំសង្ឃឹមថា តុលាការនឹងរកការពិតឲ្យខ្ញុំ ។ ហើយខ្ញុំសូមអភ័យទោស បើសិនណាការសំណូមពររបស់ខ្ញុំនេះមិនមានការយល់ទាស់ ខ្ញុំសូមឲ្យយកឆ្អឹងទាំងអស់ដែលដាក់តាំងឲ្យគេមើលហ្នឹង យកទៅបូជា ពីព្រោះថា បើសិនណាក្នុងហ្នឹងមានប្រពន្ធខ្ញុំ ខ្ញុំមិនអាចឲ្យគេយកប្រពន្ធខ្ញុំទៅដាក់ក្នុងទូធុងសម្រាប់ឲ្យគេមើលទេ ។ សូមៗអភ័យទោសទៅសាលាក្ដី បើសិនណាជាការធ្វើបានក៏ធ្វើ បើធ្វើមិនបានខ្ញុំអត់អាចថា ប្រឆាំងតទល់អីអត់ទេ ។ ប៉ុន្តែខ្ញុំសូមថា បើសិនជាអាចធ្វើបានគឺឆ្អឹងទាំងប៉ុន្មាននៅកន្លែងដែលដាក់តាំងឲ្យគេមើលសូមយកទៅបូជាតាមប្រពៃណីខ្មែរ ពីព្រោះក្នុងហ្នឹងសុទ្ធតែមនុស្សដែលត្រូវគេសម្លាប់ ។ ហើយសម្លាប់ដោយអ្នកណា? សម្លាប់ដោយអ្នកទាំងអស់នេះ ។ ម៉្លោះហើយ ខ្ញុំសូមអភ័យទោស ធ្វើជាស្ដីមួយ បើសិនណាជាលោកធ្វើបាន ។ បើសិនណាជាធ្វើមិនបានទេ អាហ្នឹងខ្ញុំៗអត់ដឹងធ្វើម៉េច ។ ប៉ុន្តែក្នុងចិត្តខ្ញុំ ខ្ញុំសូមថា ដាក់បូជាតាមប្រពៃណីខ្មែរ ចេតិយមួយដាក់កន្លែងដែលសមរម្យ ដែលថាគេមើលឃើញគ្រប់គ្នា ឲ្យគេមើលឃើញគ្រប់គ្នាថា នេះកន្លែងនេះ កុំឲ្យយើងពិបាកទៅរក ។ នេះសូមៗ ទោសដែលខ្ញុំហ៊ាននិយាយដល់ថ្នាក់ហ្នឹង ចំពោះកន្លែងសាលាក្ដី ។ រឿងនេះឯង ខ្ញុំៗគិតមើលទៅ ខ្ញុំបាត់ប្រពន្ធខ្ញុំរហូតមកដល់ពេលនេះ ខ្ញុំមិនដឹងនៅឯណាផង ។ ខ្ញុំមិនដឹងថាកូនខ្ញុំរស់ ឬស្លាប់ផង ។ ហើយបើសិនណាជាប្រពន្ធខ្ញុំហ្នឹងស្លាប់ ស្លាប់ហើយទៅនៅក្នុងទូធុង ខ្ញុំសូមអភ័យទោស បូជាដាក់នៅកន្លែងមួយដែលសមរម្យ កន្លែងណាមួយ មិនមាន មិនខុះ កន្លែងទេ ប្រហែលជាមិនខុះកន្លែងទេ ។ ហើយឲ្យគេ គេគង់តែដឹងគ្រប់គ្នា ឧបមាថា ចង់បានឲ្យគេ ឲ្យមនុស្សហ្នឹងដឹងថា នេះជារឿង កុំឲ្យកើតមានថ្ងៃក្រោយ ។ មិនអីទេចេតិយ ប៉ុន្តែខ្ញុំសូមថា កុំឲ្យឃើញឆ្អឹងក្បាលអីចឹង ។ សូមអភ័យទោសៗ បាទ ។”

សូមបញ្ជាក់ថា សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មាស សាវ៉ាន់ បានបញ្ចប់នៅរសៀលថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ បន្ទាប់មកអង្គជំនុំជម្រះបានបន្តស្ដាប់ការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀត គឺឈ្មោះ អោ រី ។

# សវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី អោ រី និង ចៅ នី

## ថ្ងៃទី២២-២៣ ខែវិច្ឆិកា ឆ្នាំ២០១២



ដើមបណ្ដឹងរដ្ឋប្បវេណី អោ រី
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)



ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ នី
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀលថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ បន្ទាប់ពីបញ្ចប់ការសាកសួរសាក្សី មាស សារ៉ាន់ អង្គជំនុំជម្រះសាលាដំបូងបានបន្តកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី អោ រី ដើម្បីមកផ្ដល់សក្ខីកម្មទាក់ទងនឹងបទពិសោធន៍ដែលខ្លួនបានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សក្ខីកម្មរបស់ អោ រី បានបន្តធ្វើនៅព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ ថែមទៀតទើបចប់។ ជាធម្មតាប្រធានអង្គជំនុំជម្រះបានចាប់ផ្ដើម សួរសំណួរមុនភាគីទាំងអស់ និងបន្ទាប់មក អង្គជំនុំជម្រះបានផ្ទេរវេទិកាជូនមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ដោយឡែក សហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី និងក្រុមមេធាវីការពារក្ដីជនជាប់ចោទ ខៀវ សំផន មិនមានសំណួរដើម្បីសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទេ ហើយក្រុមមេធាវីការពារជនជាប់ចោទ អៀង សារី និង នួន ជា បានចោទជាសំណួរបន្តិចបន្តួចប៉ុណ្ណោះ។

សូមបញ្ជាក់ថា ក្នុងអំឡុងពេលសវនាការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី អោ រី អង្គជំនុំជម្រះ បានកោះដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀត ឈ្មោះ ចៅ នី ដើម្បីមកផ្ដល់សក្ខីកម្មទាក់ទងនឹងជម្លៀសប្រជាជនតំណាក់កាលទី១ និងទី២។

ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ នី ក្រុមមេធាវីការពារក្ដីជនជាប់ចោទទាំងបីក្រុមពុំបានចោទសួរសំណួរទេ ប៉ុន្តែនៅមុនពេលបញ្ចប់សវនាការ ចៅ នី បានស្នើសុំអង្គជំនុំជម្រះសួរសំណួរទៅកាន់ជនជាប់ចោទ ខៀវ សំផន ទាក់ទងនឹងការបាត់ខ្លួនប្ដីរបស់ខ្លួន។ សំណើរនេះ បានបង្កឲ្យមានការពិភាក្សាគ្នាជាច្រើន ដោយសារតែមេធាវីអន្តរជាតិការពារក្ដីជនជាប់ចោទ ខៀវ សំផន អះអាងថា ការសាកសួរបែបនេះគឺជាការរំលោភសិទ្ធិនៅស្ងៀមមិនឆ្លើយរបស់កូនក្ដីខ្លួន និងបានស្នើសុំអង្គជំនុំជម្រះឲ្យសួរសំណួរទាក់ទងនឹងអង្គហេតុដែលដើមបណ្ដឹងលើកឡើងទៅវិញ។

### ១) ប្រវត្តិសាវតាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី អោ រី

ប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានចាប់ផ្ដើមសំណួរដំបូងរបស់ខ្លួនទាក់ទងនឹងប្រវត្តិសាវតាររបស់ដើម

បណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណី អោ រី បានរៀបរាប់ថា ខ្លួនមាន អាយុ៥០ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ មានឪពុកឈ្មោះ អោ និងម្តាយឈ្មោះ ផាត ហើយស្វាមីឈ្មោះ ហ៊ុន ម៉ៅ និងមានកូន ៤ នាក់ ។ បន្ទាប់មកចៅក្រម និល ណុន បានបញ្ជាក់ប្រាប់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមកិច្ចដំណើរការសវនាការ ព្រមទាំងសិទ្ធិក្នុងការថ្លែងទុក្ខសោក និងការបាត់បង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅចុងបញ្ចប់នៃការសួរដេញដោល ។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះបានផ្តល់វេទិកាជូនមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសាកសួរបន្ត ។

### ក) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

#### ក.១) ស្ថានភាពនៅមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥

ឆ្លើយតបនឹងសំណួររបស់មេធាវីជាតិ លោកស្រី ទី ស្រ៊ីនណា ទាក់ទងនឹងព្រឹត្តិការណ៍នានា ដែលកើតមានឡើងនៅមុនរបបខ្មែរក្រហម អោ រី បានបញ្ជាក់ថា មុនរបបខ្មែរក្រហមខ្លួនបានមករស់នៅក្នុងទីក្រុងភ្នំពេញ ហើយបានឮស្គរកាំភ្លើងបាញ់ផ្លោងចូលទីក្រុងជារៀងរាល់ថ្ងៃ ។ បងស្រីរបស់ខ្លួនបានរងរបួសដោយសារអំបែងគ្រាប់បានខ្ទាត និងត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យធំអស់រយៈពេលមួយខែ ។ ពីរទៅបីថ្ងៃក្រោយមក យោធាខ្មែរក្រហមក៏ចូលមកដល់ទីក្រុងភ្នំពេញជាមួយនឹងសំលៀកបំពាក់ពណ៌ខ្មៅដើរជាជួរៗ ហើយប្រកាសប្រាប់ឲ្យប្រជាជនចេញពីទីក្រុងភ្លាមៗ ។ ដើមបណ្តឹងរដ្ឋប្បវេណី បានបន្តរៀបរាប់ថា នៅពេលនោះប្រជាជនជនមានការក្រាញមិនចង់ចាកចេញទេ ប៉ុន្តែខ្មែរក្រហមបានប្រកាសឲ្យប្រជាជនចេញដោយមិនចាំបាច់យកសម្ភារៈទៅជាមួយទេ ព្រោះចាកចេញរយៈពេលបីថ្ងៃតែប៉ុណ្ណោះ ។

#### ក.២) ការជម្លៀសចេញពីទីក្រុងភ្នំពេញ

ដើមបណ្តឹងរដ្ឋប្បវេណី អោ រី បានបន្តរៀបរាប់ថា ខ្លួន និងក្រុមគ្រួសារបានធ្វើដំណើរទៅស្រុកកំណើតនៅភូមិត្បូងដំរី ត្រូវចំណាយពេលមួយថ្ងៃមួយយប់ទើបបានទៅដល់ភូមិកំណើត ។ ដោយសារពុំមាន អាហារសម្រាប់ហូបចុកឲ្យបានគ្រប់គ្រាន់ អោ រី បានជួបប្រទះការលំបាកជាច្រើន ។ នៅទីនោះខ្លួន និងក្រុមគ្រួសារបានស្នាក់នៅផ្ទះជីដូនពីរបីថ្ងៃ ទើបខ្មែរក្រហមបំបែកម្តាយខ្លួនឲ្យទៅនៅផ្ទះផ្សេង ដោយសារតែមានការបែងចែកប្រជាជនចាស់ និងប្រជាជនថ្មី ។ បន្ទាប់ពីនៅទីនោះបានមួយរយៈខ្លួន និងក្រុមគ្រួសារត្រូវបានបញ្ជូនតាមកប៉ាល់នៅព្រែកតាមាក់ ហើយបន្ទាប់មក រថយន្តទ្រុងជាច្រើនគ្រឿងមកដឹកបន្តទៅខេត្តពោធិ៍សាត់ ។ ដើមបណ្តឹងរដ្ឋប្បវេណី អោ រី បានបញ្ជាក់ទៀតថា ប្រជាជនម្នាក់ៗពុំចង់ឡើងឡានឡើយ ។ ដោយសារតែមានមេកង និងយោធាផ្សេងទៀតកាន់កាំភ្លើងគ្រប់ដៃ ទើបម្នាក់ៗនាំគ្នាឡើងឡានយ៉ាងណែនកកកុញ ។

#### ក.៣) ស្ថានភាពរស់នៅក្រោយពេលជម្លៀស

ឆ្លើយតបនឹងសំណួរទាក់ទងនឹងស្ថានភាពរស់នៅក្រោយពេលជម្លៀស ដើមបណ្តឹងរដ្ឋប្បវេណី អោ រី បានរៀបរាប់បន្តថា នៅពេលទៅដល់ចំការតាពូ ខេត្តពោធិ៍សាត់ ម្តាយខ្លួនដែលទើបតែសម្រាលកូនរួច ត្រូវបានចាត់តាំងឲ្យទៅធ្វើស្រែ ។ ចំណែកបងស្រីដែលមានជំងឺត្រូវបញ្ជូនទៅធ្វើការនៅកន្លែងចុងភៅ ហើយខ្លួនត្រូវទៅកាប់ទន្រ្ទានខែត្រសម្រាប់ធ្វើជី ។ ការរស់នៅ គឺមានការបែងចែកប្រជាជនចាស់ និងប្រជាជន ថ្មី ។ ប្រជាជនចាស់ត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុងផ្ទះរបស់ខ្លួន ចំណែកប្រជាជនថ្មី គឺត្រូវរស់នៅផ្ទះវែងជុំគ្នា ។

ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តរៀបរាប់ថា បងប្រុសរបស់ខ្លួនត្រូវបានសម្លាប់ដោយសារតែបានលួចឡើងដើមត្នោត ។ ក្រោយមក សមាជិកនៅក្នុងគ្រួសាររបស់ខ្លួនក៏ត្រូវបានសម្លាប់ ទោះបីខ្លួនព្យាយាមអង្វរឲ្យទុកជីវិតម្តាយ និងប្អូនប្រុសតូចក៏ដោយ ។ ប្អូនតូចរបស់ខ្លួនត្រូវបានខ្មែរក្រហមបោះឡើងទៅលើរួចចាក់នឹងចំពុះទង់ ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រធានអង្គជំនុំជម្រះ និល ណុន បានផ្តល់វេទិកាជូនមេធាវីការពារក្តីដើម្បីបន្តការសាកសួរ ដោយសារតែសហព្រះរាជអាជ្ញាពុំមានសំណួរសួរដើមបណ្តឹងរដ្ឋប្បវេណី ។

### ខ) ការសួរដេញដោលដោយមេធាវីការពារក្តី

មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ នួន ជា គឺលោក សុន អរុណ បានចាប់ផ្តើមសួរសាក្សីបន្តទៀតដោយផ្តោតជាសំខាន់

ពាក់ព័ន្ធនឹងការសម្លាប់ក្រុមគ្រួសាររបស់ អោ រី ។ ឆ្លើយតបនឹងសំណួរនេះ អោ រី បានសង្កត់ធ្ងន់ថា មានការសម្លាប់ប្រជាជនដែលមកពីខេត្តស្វាយរៀងជាមុន បន្ទាប់មកទើបខ្មែរក្រហមសម្លាប់គ្រួសាររបស់ខ្លួន ដោយសារគ្រួសារខ្លួនបានរស់នៅជាមួយប្រជាជនទាំងនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្លួនត្រូវបានខ្មែរក្រហមបញ្ជូនយកទៅបាញ់សម្លាប់ចោល ប៉ុន្តែដោយសារគ្រាប់កាំភ្លើងដែលបាញ់នោះមិនផ្ទុះ ទើបខ្លួនបានរួចជីវិតមកដល់សព្វថ្ងៃ ។

ចំណែកមេធាវីការពារក្តី អៀង សារី វិញ ការសួរភាគច្រើនផ្តោតទៅលើនីតិវិធីនៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែសំណួរទាំងនោះពុំត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យសាកសួរទេ ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ពុំមានសំណួរចោទសួរដើមបណ្តឹងរដ្ឋប្បវេណី អោ រី ឡើយ ។

### ក) ការថ្លែងសេចក្តីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី អោ រី

ដើមបណ្តឹងរដ្ឋប្បវេណី អោ រី បានថ្លែងរៀបរាប់អំពីទុក្ខសោករបស់ខ្លួនដូចតទៅ ៖

«ខ្ញុំសូមនិយាយថា ពីខ្ញុំចេញពីទីក្រុងភ្នំពេញ ខ្ញុំបាត់បង់ផ្ទះសំបែង ទ្រព្យសម្បត្តិ ហើយមកតាមផ្លូវអត់មានអាហារហូបតាមផ្លូវ វេទនារហូតទាល់តែទៅដល់ស្រុកកំណើត ។ ទៅដល់ស្រុកកំណើតហើយនឹកស្មានថាបាននៅជាមួយជីដូនជីតា អកុសលអីបានបញ្ជូនខ្ញុំម្តងហើយទៅម្តងទៀតទាល់តែទៅដល់ខេត្តពោធិ៍សាត់ គេដាក់ទារុណកម្មខ្ញុំ ព្រោះខ្ញុំនៅតូច ខ្ញុំធ្វើការមិនបានជិតដិតនឹងគេ គេវ៉ៃនឹងខ្នងចប ។ គេយកខ្ញុំរែកដី គេយកដងរែកមកសំពងខ្ញុំ កំភួនជើង ឆ្អឹងខ្នង គេថាខ្ញុំនឹងចក្រព័ន្ធ គេថាខ្ញុំខ្ជិល ។ ខ្ញុំរែកម៉េចនឹងរួច! បើដីពេញៗ ហើយជម្រៅណាណី ខ្ញុំអូសតែបង្គីរអូសមិនចង់រួចផង ។ ចំណែកគេឲ្យខ្ញុំទៅស្ទូង ខ្ញុំអត់ចេះស្ទូង គេយកដៃខ្ញុំមកផ្ទាប់នឹងភ្លឺស្រែ វ៉ៃខ្ញុំឡើងចង់ខ្ទេចអស់ហើយដៃ ទើបតែមកជាសព្វថ្ងៃនេះទេ ខ្ញុំធ្វើអីក៏មិនកើតដែរ ។ ហើយឲ្យខ្ញុំបាត់បង់ឪពុកម្តាយបងប្អូនអស់ទាំងពូជ ធ្វើឲ្យខ្ញុំក្លាយជាក្មេងអនាថា អត់មានឪពុកម្តាយ ក្មេងកំព្រា តែលតោលគ្មានគោលដៅ ដើរសុំតែទានគេស៊ីរើសកាកសំណល់គេសល់ពីរនាក់បងប្អូនដើររើសតាមផ្លូវ ។ លើកដៃសំពះអង្វរសុំគេ សុំឲ្យតែប្អូនហូប ខ្លួនឯងសុខចិត្តអត់ព្រោះប្អូន ។ ហើម/ជើងប៉ុនៗណាណី ប៉ុនៗដរី ។ ចំណែកឯខ្ញុំ ណាត្រូវរបួសដើរអូសក៏អូសជើងដែរ ខ្ញុំឈឺចាប់ទល់សព្វថ្ងៃនេះ ។ សព្វថ្ងៃណាមួយបងស្រីទើបតែជួបគ្នា ខ្ញុំស្មានតែបងខ្ញុំនឹងស្លាប់ គេបញ្ជូនទៅធ្វើការឆ្ងាយនោះ បងស្រីដែលត្រូវគ្រាប់នោះ ឥឡូវគាត់រស់នៅទល់សព្វថ្ងៃ របួសគាត់គ្មានធ្វើអីកើតទេ នៅទល់សព្វថ្ងៃនៅជាមួយនឹងខ្ញុំ គ្មានប្តីគ្មានសីអីទេ តែជីវិតខ្ញុំក៏អកុសល ខ្ញុំក៏អាក្រក់ម្ល៉េះជួបតែទុក្ខលំបាកវេទនា សូមឲ្យលោកប្រធានជួយរកការខុសត្រូវឲ្យខ្ញុំផង ខ្ញុំសូមអគុណ!»

### ២) ប្រវត្តិសាវតាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី

ដូចបានបញ្ជាក់ពីខាងដើម សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី គឺធ្វើឆ្លាស់គ្នាជាមួយនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អោ រី ដោយសក្ខីកម្មរបស់ ចៅ នី ត្រូវបានចាប់ផ្តើមនៅពេលសៀល ។

ការសួរដេញដោលនេះ ប្រធានអង្គជំនុំជម្រះគឺចៅក្រម និល ណុន បានសួរទាក់ទងនឹងប្រវត្តិសាវតាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ។ ចៅ នី បានរៀបរាប់ថា ខ្លួនមានអាយុ៥៩ឆ្នាំ មានស្រុក កំណើតនៅភូមិភ្នំពៀ ខេត្តអានយ៉ាង (កម្ពុជាក្រោម) ហើយបច្ចុប្បន្នខ្លួនរស់នៅខេត្តតាកែវ ។

បន្ទាប់មក ចៅក្រម និល ណុន បានរំឭកដល់ដើមបណ្តឹងរដ្ឋប្បវេណីអំពីសិទ្ធិ និងករណីកិច្ចក្នុងពេលដំណើរការសវនាការ និងសិទ្ធិក្នុងការធ្វើសេចក្តីថ្លែងទុក្ខសោកនៅចុងបញ្ចប់នៃកិច្ចដំណើរការសួរដេញដោល ។

### ក) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិ គង់ ផល្ល័ក បានចាប់ផ្តើមសួរសំណួរមួយចំនួនទាក់ទងនឹងព្រឹត្តិការណ៍នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ និងស្ថានភាពរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រោយពេលជម្លៀស ។

#### ក.១) ព្រឹត្តិការណ៍ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥

ឆ្លើយតបនឹងសំណួរសួរដេញដោលរបស់មេធាវី គង់ ផល្ល័ក ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី បានរៀបរាប់ថា ខ្លួនបានមក

រស់នៅទីក្រុងភ្នំពេញនៅឆ្នាំ១៩៧០ ដើម្បីធ្វើជាទាហាន លន់ នល់ ប៉ុន្តែពេលនោះ បងប្អូនរបស់ខ្លួនមិនអនុញ្ញាតទេ ។ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានចូលមកកាន់កាប់ទីក្រុងភ្នំពេញ ដោយមានប្រជាពលរដ្ឋជាច្រើនបានចេញទៅអបអរសាទរ ។ ចំណែកឯសមាជិកក្រុមគ្រួសាររបស់ខ្លួនពុំបានចេញទៅទទួលឡើយ ។ ប្រហែល២ម៉ោងក្រោយមកខ្មែរក្រហមប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញលាយឡំជាមួយនឹងស្នូរកាំភ្លើង ។ ប្រជាជន ចាស់ ក្មេង និងអ្នកជំងឺនៅតាមមន្ទីរពេទ្យត្រូវបានបង្ខំឲ្យចាកចេញ ។ ចំណែកឯក្រុមគ្រួសាររបស់ខ្លួនក៏ស្ថិតនៅក្នុងចំណោមអ្នកដែលត្រូវបានជម្លៀសទាំងអស់នោះដែរ ។ មានប្រជាជនជាច្រើនបានស្លាប់នៅតាមផ្លូវដោយគ្មាននរណាជួយឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា ខ្លួនមានបំណងធ្វើដំណើរទៅស្រុកកំណើត (កម្ពុជាក្រោម) វិញ ប៉ុន្តែមិនបានទៅដល់គោលដៅឡើយ គឺត្រូវឈប់នៅត្រឹមភូមិត្រពាំងសាបស្ថិតនៅក្នុងស្រុកបាទី ខេត្តតាកែវ ។



ប្រជាជនកម្ពុជាកំពុងលើកទំនប់ ជីកប្រឡាយ នៅការដ្ឋានមួយ ។ រូបថតនេះថតនៅអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

### ក.២) ស្ថានភាពរស់នៅក្រោយពេលជម្លៀស

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ម៉ាឌូ ម៉ូហាន បានបន្តពីសហភាគាជាតិរបស់ខ្លួនដោយសួរទាក់ទងនឹងការលាក់ប្រវត្តិរូបនៅអំឡុងពេលនៃរបបខ្មែរក្រហម ។ ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី បានបញ្ជាក់ថា បន្ទាប់ពីដឹងដំណឹងថាខ្មែរកម្ពុជាក្រោមអាចនឹងត្រូវបានសម្លាប់ខ្លួនបានសម្រេចចិត្តផ្លាស់ប្តូរពីត្រកូល ចៅ មកត្រកូល នន់ វិញ ។ ចៅ នី បានពន្យល់ថា ត្រកូល ចៅ គឺសំដៅទៅលើប្រជាជនដែលរស់នៅក្នុងខេត្តមួយនៅកម្ពុជាក្រោម ។

ទាក់ទឹងការរស់នៅប្រចាំថ្ងៃ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា ខ្លួនត្រូវបានជម្លៀសពីភូមិត្រពាំងសាបទៅស្រុកមោងឫស្សីតាមរទេះភ្លើង ហើយនៅពេលទៅដល់មានរទេះគោជាច្រើនចាំទទួលយកទៅសហករណ៍ តាហ៊ុយ ហើយបន្ទាប់មកត្រូវបានបញ្ជូន

ទៅសហករណ៍ចកធំ ។ នៅសហករណ៍នោះ ពុំមានអាហារហូបគ្រប់គ្រាន់ទេ ដូច្នេះក្មួយទាំងពីររបស់ខ្លួនចាប់ផ្តើមធ្លាក់ខ្លួនឈឺ ហើយមានតែថ្នាំអាចម៍ទន្សាយប៉ុណ្ណោះសម្រាប់ព្យាបាល ។ នៅក្នុងសហករណ៍ចកធំ មានប្រជាជនរស់នៅច្រើន ប៉ុន្តែពុំមាននរណាម្នាក់ហ៊ាននិយាយទាក់ទងគ្នាឡើយ ។ ចៅ នី បានសង្កត់ធ្ងន់ថា តាហ៊ុយ ដែលមានតំណែងជាប្រធានសហករណ៍ត្រូវបានចាត់ទុកថាជាឃាតករសម្លាប់មនុស្សទាំងមុខញញឹមដោយគ្មានញញើតដៃ ។ ប្រជាជនដែលរស់នៅក្នុងសហករណ៍ចកធំធ្វើការច្រើនម៉ោង ប៉ុន្តែពុំមានអាហារហូបចុកគ្រប់គ្រាន់ទេ ដូច្នេះមានមនុស្សស្លាប់កាន់តែច្រើនដោយសារអត់បាយ ។

## ២.ខ) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ថារីក បានបន្តសួរទាក់ទងនឹងការជម្លៀសប្រជាជនដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ឡើងវិញ ។ ឆ្លើយតបនឹងសំណួរនេះ ចៅ នី បានបញ្ជាក់ថា ខ្លួនបានឮការប្រកាសឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញ ដោយយកហេតុផលថា យន្តហោះអាមេរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ ។ ខ្មែរក្រហមបានប្រាប់ប្រជាជនឲ្យចាកចេញពីផ្ទះក្នុងរយៈពេលតែបីថ្ងៃប៉ុណ្ណោះ ។

## ២.គ) ការសួរដេញដោលដោយចៅក្រម ហ្សង់ម៉ាក ឡាវើញ

បន្ទាប់ពីបញ្ចប់ការសាកសួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ លោកចៅក្រម ហ្សង់ម៉ាក ឡាវើញ បានបន្តសួរទាក់ទងនឹងភាពភ័យខ្លាចរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយសារការរើសអើងថា ខ្លួនជាខ្មែរកម្ពុជាក្រោម ។ ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី បានបញ្ជាក់ថា ក្រោយពេលបានឮថាខ្មែរ ក្រហមមានការរើសអើងលើប្រជាជនកម្ពុជាក្រោម ខ្លួនមានការភ័យខ្លាចជាខ្លាំង ដោយត្រូវបង្ខំចិត្តផ្លាស់ប្តូរនាមត្រកូល ។ មុនពេលចូលកាន់អំណាចខ្មែរក្រហមមិនមានការរើសអើងខ្មែរក្រោមឡើយ ប៉ុន្តែក្រោយពេលចូលកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហមក៏ចាប់ផ្តើមបង្កើតនយោបាយរើសអើងលើប្រជាជនខ្មែរកម្ពុជាក្រោមទៅវិញ ។ ជាងនេះទៅទៀត ក្រោយពេលដែលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្លួនក៏បានឃើញពាក្យស្លោករបស់ខ្មែរក្រហមដែលសរសេរនៅលើជញ្ជាំងនៅមន្ទីរស-២១ថា "កុំឆ្លើយថាឯងជាខ្មែរក្រោមដើម្បីចង់រួចខ្លួន" ថែមទៀត ។

## បញ្ហាផ្សេងៗ

ដោយសារមេធាវីការពារជនជាប់ចោទទាំងបីក្រុមពុំមានសំណួរសួរដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី អង្គជំនុំជម្រះបានផ្តល់វេទិកាជូនដើមបណ្តឹងរដ្ឋប្បវេណីដើម្បីធ្វើសេចក្តីថ្លែងអំពីទុក្ខសោករបស់ខ្លួនដែលទទួលរងនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ បន្ទាប់ពីទទួលបានការអនុញ្ញាត ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ពុំទាន់ថ្លែងអំពីទុក្ខសោករបស់ខ្លួនភ្លាមៗទេ ប៉ុន្តែបានស្នើសុំ



ប្រជាជនកម្ពុជាកំពុងធ្វើការនៅការដ្ឋានសាងសង់ទំនប់ទឹកក្នុងរបប

អង្គជំនុំជម្រះដើម្បីសួរជនជាប់ចោទ ខៀវ សំផន អំពីការស្លាប់ពូរបស់ខ្លួន ។ បន្ទាប់ពីបានឮសំណើសុំនេះភ្លាម មេធាវីអន្តរជាតិរបស់ជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិថ្លែងអំពីទុក្ខសោក និងការទទួលរងរបស់ខ្លួនដោយសាររបបខ្មែរក្រហម ប៉ុន្តែការអនុញ្ញាតឲ្យមានការចោទ

សួរសំណួរចំពោះជនជាប់ចោទណាម្នាក់នោះ គឺជាការមិនសមស្របឡើយ ។ ឆ្លើយតបនឹងការលើកឡើងនេះ មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ូហាន បានបញ្ជាក់ថា ករណីនេះពុំធ្លាប់មានពីមុនមកទេ ហើយការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីសាកសួរដូច្នេះ ក៏មិនមានចែងនៅក្នុងវិធានផ្ទៃក្នុងដែរ ។ ដូច្នេះខ្លួនគាំទ្រឲ្យមានការសាកសួរបែបនេះទៅកាន់ជនជាប់ចោទ ។ មេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ អៀង សារី គឺលោក អាង ឧត្តម បានបង្ហាញអំពីជំហររបស់ខ្លួនថា ដើមបណ្តឹងរដ្ឋប្បវេណី



បកម្ពុជាប្រជាធិបតេយ្យ (ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មានសិទ្ធិធ្វើសេចក្តីថ្លែងទុក្ខសោក ហើយជនជាប់ចោទមានសិទ្ធិរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ដូចក្នុងករណីជនជាប់ចោទ ខៀវ សំផន ជាដើម ។

ឆ្លើយតបនឹងការលើកឡើងទាំងនោះ តំណាងសហព្រះរាជអាជ្ញា ថារីក អាប់ឌុលហាក់ បានអះអាងថា ករណីនេះ គឺអាស្រ័យទៅលើតុលាការជាអ្នកធ្វើការថ្លឹងថ្លែងនូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យមានមតិយោបល់លើសេចក្តីថ្លែងការណ៍នោះ ។ ម្យ៉ាងទៀត ជនជាប់ចោទ ខៀវ សំផន មិនបានរក្សាភាពនៅស្ងៀមមិនឆ្លើយតបរៀងរហូតនោះទេគឺតែក្នុងរយៈពេលមួយខ្លីប៉ុណ្ណោះ ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ អង្គជំនុំជម្រះបានចោទសួរជនជាប់ចោទ ខៀវ សំផន ថាតើ ជនជាប់ចោទនៅរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបដែរឬទេ? ជនជាប់ចោទបានបញ្ជាក់ថា ខ្លួននៅតែរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយខ្លួននឹងធ្វើការឆ្លើយតបប្រសិនបើអង្គជំនុំជម្រះតម្រូវឲ្យខ្លួនធ្វើដូច្នោះ ហើយដូចដែលខ្លួនបញ្ជាក់កាលពីមុនថា ខ្លួននឹងមិនឆ្លើយតបនឹងសំណួរដែលចោទសួរ និងរង់ចាំឲ្យមានការដាក់កស្តុតាងគ្រប់គ្រាន់ ទើបខ្លួនធ្វើសេចក្តីថ្លែងការណ៍តបនូវសំណួរដែលបានចោទឡើង ។ បន្ទាប់មកអង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីសាកសួរជនជាប់ចោទតាមរយៈអង្គជំនុំជម្រះ ដោយហេតុថា ដើមបណ្តឹងរដ្ឋប្បវេណីពុំមានសិទ្ធិសួរជនជាប់ចោទឡើយ ។

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ស្ថានភាពនៃការជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថា នៅពេលនោះពូរបស់ខ្លួនឈ្មោះ ចៅ សាវ ធ្លាប់មានទំនាក់ទំនងល្អជាមួយ ខៀវ សំផន ហើយនៅពេលជម្លៀស ខៀវ សំផន បានផ្ញើសំបុត្រមួយឲ្យ ចៅ សាវ ត្រឡប់មកទីក្រុងភ្នំពេញវិញ ។ ប៉ុន្តែក្រោយពីវិលត្រឡប់ទៅទីក្រុងភ្នំពេញ ចៅ សាវ ក៏បានបាត់ខ្លួន ។ បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណីបានសួរជនជាប់ចោទថា នៅពេលនោះតើជនជាប់ចោទបានជួបពូរបស់ខ្លួនដែរទេ? ហើយពូខ្លួនស្លាប់នៅទីណាដើម្បីខ្លួនទៅធ្វើបុណ្យឲ្យ? ភ្លាមនោះមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានព្យាយាមក្រោកឈរដើម្បីតវ៉ា តែត្រូវបញ្ឈប់ដោយអង្គជំនុំជម្រះ ហើយជនជាប់ចោទបានសួរសំណួរទៅកាន់អង្គជំនុំជម្រះថា “សូមគោរព លោកប្រធាន ខ្ញុំសូមអនុញ្ញាតសួរបញ្ជាក់ ។ តើការឆ្លើយរបស់ខ្ញុំនៅពេលនេះចំពោះតែសំណួរមួយនេះ វាប៉ះពាល់ដល់សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ខ្ញុំទេ? បើមិនប៉ះពាល់ទេ ខ្ញុំឆ្លើយតែឥឡូវនេះបាន” ។ បន្ទាប់មក ចៅក្រម និល ណុន បានឆ្លើយតបថា

នេះជាសិទ្ធិរបស់ជនជាប់ចោទក្នុងការឆ្លើយ ឬមិនឆ្លើយនឹងសំណួរ ដោយសារជនជនជាប់ចោទមិនបានរក្សាសិទ្ធិនៅស្ងៀមនេះដាច់



ជនជាប់ចោទ ខៀវ សំផន នៅក្នុងបន្ទប់សវនាការ
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខាតក្នុងកិច្ចដំណើរការសវនាការលើសំណុំរឿង០០២នេះទាំងមូលឡើយ ។ ភ្លាមៗនោះ ក៏មានប្រតិកម្មពីមេធាវីការពារក្តី ខៀវ សំផន ក្នុងគោលបំណងធ្វើការឆ្លើយតបអ្វីមួយ ប៉ុន្តែស្ថានភាពនេះត្រូវបានអង្គជំនុំជម្រះបញ្ឈប់វិញ ។ ទោះបីជាយ៉ាងណា មេធាវីអន្តរជាតិ អ៊ីនូហ្ស៊ី បានព្យាយាមធ្វើការថ្លែងដែរ ក៏ប៉ុន្តែត្រូវបានអង្គជំនុំជម្រះបញ្ឈប់ដូចគ្នាដែរ ។ បន្ទាប់មក ជនជាប់ចោទមិនបានឆ្លើយតបនឹងសំណួរទេ ថែមទាំងបញ្ជាក់ថា ខ្លួននឹងផ្ទេរសិទ្ធិរបស់ខ្លួនទៅមេធាវីការពារក្តី ហើយខ្លួននឹងធ្វើការឆ្លើយតបនៅពេលដែលមានភស្តុតាងគ្រប់គ្រាន់ ។

### ឃ) ការថ្លែងសេចក្តីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីអង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីទុក្ខសោក របស់ខ្លួន ចៅ នី បានរៀបរាប់ដូចតទៅ ៖

*“សូមជម្រាបលោកប្រធាន! ខ្ញុំសោកស្តាយណាស់ដែលសំណួររបស់ខ្ញុំចង់សួររកអីរបស់ខ្ញុំ គាត់មិនមែន....មិនមែនថា ខៀវ សំផន មិនស្គាល់ទេ ។ ខៀវ សំផន ស្គាល់ ចៅ សាវ ច្បាស់ណាស់ គាត់ធ្លាប់ហូបបាយជាមួយគ្នាទៀត គាត់មិនមែនថា បដិសេធមិនដឹងថា សាកសពរបស់គាត់ស្លាប់នៅទីណាទេ ។ គាត់មិនគួរបដិសេធទេ សំខាន់បំផុត គាត់គ្រាន់តែបង្ហាញថា គាត់ស្លាប់នៅកន្លែងណា? ហើយខ្ញុំនឹងយកធាតុរបស់គាត់យកទៅធ្វើបុណ្យតាមប្រពៃណីខ្មែរវិញតែប៉ុណ្ណឹងទេ ។ អីចឹង! ទុក្ខសោករបស់ខ្ញុំនៅដដែល ទោះបីបានឡើងតុលាការយ៉ាងណាក៏ខ្ញុំមិនអស់ចិត្តទេ ។ តើឲ្យខ្ញុំថ្លែងទុក្ខនឹងទៅប្រាប់អ្នកណា? បើមកដល់តុលាការហើយ តុលាការគ្រាន់តែឲ្យគាត់ឆ្លើយប្រាប់ថា អ៊ំខ្ញុំស្លាប់នៅកន្លែងណា? ក្មួយខ្ញុំស្លាប់ ខ្ញុំមិននិយាយទេ ហើយខ្ញុំមិនចងកំហឹងជាមួយគាត់ទេ ខ្ញុំគ្រាន់តែឲ្យគាត់បង្ហើបរឿង ចៅ សាវ ស្លាប់នៅកន្លែងណា ខ្ញុំនឹងយកធាតុគាត់មកធ្វើបុណ្យតាមប្រពៃណីខ្មែរយើងតែប៉ុណ្ណោះទេ ។ ហើយបើគាត់មិនដែលស្គាល់ ចៅ សាវ ខ្ញុំនឹងយករូបថតឲ្យមើល រូបថត ចៅ សាវ បើលោកភ្លេចមុខ ចៅ សាវ ខ្ញុំយករូបថតឲ្យមើល ហើយលោកអ៊ំមិនគួរបដិសេធទេ ។ ខ្ញុំមានតែប៉ុណ្ណឹងទេលោកប្រធាន” ។*

បន្ទាប់មក មេធាវីអន្តរជាតិ អង់តា ហ្គីសសេ បានលើកឡើងដោយមិនពេញចិត្តថា ការលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងមិនទាក់ទងនឹងអង្គហេតុក្នុងសំណុំរឿង ដោយបង្កើតឲ្យមានបញ្ហាទាក់ទងនឹងតម្លៃនៃភស្តុតាង ។ ជាងនេះទៅទៀត គឺមានកំហុសក្នុងកិច្ចដំណើរការសវនាការ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរដែលនាំកូនក្តីខ្លួនឲ្យជាប់ពាក់ព័ន្ធនឹងបញ្ហា ហើយករណីនេះជាការរំលោភសិទ្ធិនៅស្ងៀមរបស់កូនក្តីខ្លួន ។

ដើម្បីឆ្លើយតបទៅភាគីទាំងអស់ ចៅក្រម ឡាវ៉ែញ បានបញ្ជាក់ថា ការធ្វើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងអង្គហេតុថ្មីអំពីការស្លាប់របស់ពូខ្លួន ប៉ុន្តែបញ្ហានេះនៅតែស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២ដដែល ។ ដូច្នេះភាគីមានសិទ្ធិសាកសួរដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀត ប៉ុន្តែមិនមានភាគីណាមួយលើកឡើងពីបញ្ហានេះទេ ។ ភ្លាមៗនោះ មេធាវីការពារក្តី ខៀវ សំផន បានស្នើសុំពេលដើម្បីចោទសំណួរ ប៉ុន្តែការណ៍នេះត្រូវបានចៅក្រម និល ណុន បញ្ជាក់ថា អង្គជំនុំជម្រះនឹងមិនបន្តសវនាការទៀតទេ ដោយសារដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងរួចហើយ ។ ម្យ៉ាងទៀត ជនជាប់ចោទក៏បានបញ្ជាក់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតបរួចហើយដែរ ។

# សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ទីង សុខា

## ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២

នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង បានបន្តបើកសវនាការលើសំណុំរឿង០០២ ទាក់ទងនឹងអង្គហេតុស្តីអំពីរចនាសម្ព័ន្ធយោធា ដោយធ្វើការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ទីង សុខា ដែលមានរហស្សនាម TCCP-108 ។ សវនាការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីមានការយឺតយ៉ាវ ដោយសារភាគីបានលើកឡើងនូវបញ្ហាមួយចំនួនទាក់ទងនឹងសុខភាពរបស់ជនជាប់ចោទ អៀង សារី ។ បន្ទាប់ពីចំណាយពេលអស់ប្រហែលមួយម៉ោង ក្នុងការលើកអំណះអំណាងរបស់ភាគី ចៅក្រម និល ណុន បានបន្តសវនាការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងផ្ទេរវេទិកាសួរដេញដោលនេះជូនភាគី តាមលំដាប់លំដោយ គឺក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី ។ សវនាការសាកមួយនេះ បានប្រព្រឹត្តទៅក្នុងរយៈពេលមួយថ្ងៃពេញ ។ មេធាវី ការពារក្តីជនជាប់ចោទ អៀង សារី និង ខៀវ សំផន ពុំមានសំណួរសម្រាប់សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីទេ ។ ការសួរដេញដោលនេះ បានផ្តោតសំខាន់ទៅលើស្ថានភាពនៅទីក្រុងភ្នំពេញមុនពេលខ្មែរក្រហមចូលមកដល់, ការជម្លៀសប្រជាជនលើកទីមួយ និងលើកទីពីរ ។ នៅចុងបញ្ចប់នៃកិច្ចដំណើរការសួរដេញដោលនេះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ឱកាសឲ្យថ្លែងអំពីសេចក្តីទុក្ខសោករបស់ខ្លួន ។

### បញ្ហាផ្សេងៗមុនឈានដល់ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី

មុនពេលចាប់ផ្តើម ចៅក្រម និល ណុន បានធ្វើការកត់សម្គាល់លើស្ថានភាពសុខភាពរបស់ អៀង សារី តាមរយៈការពិនិត្យរបស់គ្រូពេទ្យប្រចាំការរបស់ជនជាប់ចោទដោយបានបញ្ជាក់ថា អៀង សារី មានបញ្ហាហេវហត់ ចុកដើមទ្រូង សំពាធមិនលក់ និងក្អួតដែលជាហេតុធ្វើឲ្យជនជាប់ចោទមិនអាចចូលរួមសវនាការដោយផ្ទាល់បាន ។ អាស្រ័យហេតុនេះចៅក្រម និល ណុន បានសម្រេចឲ្យជនជាប់ចោទចូលរួមសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម ។ ក្នុងនោះ មេធាវីអន្តរជាតិការពារក្តី អៀង សារី លោក ម៉ៃឃើល ការណាវ៉ាស បានលើកឡើងថា អៀង សារី នឹងចូលរួមសវនាការនេះដោយផ្ទាល់ ប៉ុន្តែក្នុងករណីដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទទៅចូលរួមសវនាការនៅបន្ទប់ខាងក្រោមនោះ ខ្លួនស្នើសុំឲ្យមានការដាក់អេក្រង់នៅបន្ទប់ខាងក្រោមដើម្បីឲ្យសាធារណៈជនបានឃើញមុខជនជាប់ចោទផ្ទាល់ ។ ជម្រើសផ្សេងទៀត គឺមេធាវីបានស្នើសុំឲ្យជនជាប់ចោទចូលរួមសវនាការដោយផ្ទាល់តែម្តង ។ ចំណែកជម្រើសចុងក្រោយ មេធាវីបានស្នើសុំឲ្យមានសមាជិកមេធាវីម្នាក់ចូលរួមនៅក្នុងបន្ទប់ខាងក្រោមជាមួយជនជាប់ចោទ ដើម្បីថតវីដេអូអំពីស្ថានភាពរបស់ជនជាប់ចោទ ។ ក្រៅពីនោះ មេធាវីការពារក្តីបានបន្តដោយស្នើសុំឲ្យមានការសាកសួរវេជ្ជបណ្ឌិតដើម្បីបញ្ជាក់អំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ ។

សហព្រះរាជអាជ្ញារង វីល្លៀម ស្មីត បានឆ្លើយតបដោយយោងទៅលើការផ្តល់យោបល់របស់វេជ្ជបណ្ឌិត ចន ខាំប៉ែល គឺតម្រូវឲ្យជនជាប់ចោទ អៀង សារី ចូលរួមសវនាការនៅក្នុងបន្ទប់ខាងក្រោម ហើយដោយយោងទៅលើការសម្រេចរបស់វេជ្ជបណ្ឌិតបានបញ្ជាក់ថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ បន្ទាប់មក មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបន្តដោយធ្វើការកត់សម្គាល់លើពីរចំណុច ។ ទី១ គឺទាក់ទងនឹងមូលហេតុនៃការផ្លាស់ប្តូរគោលជំហររបស់ អៀង សារី ដោយដំបូងឡើយ អៀង សារី បានបោះបង់សិទ្ធិចូលរួមដោយផ្ទាល់ ប៉ុន្តែពេលនេះ អៀង សារី បែរជាស្នើសុំចូលរួមដោយផ្ទាល់វិញ ។ ចំណុចទីពីរ គឺមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបញ្ជាក់ថា អៀង សារី ពិតជាមានសម្បទាគ្រប់គ្រាន់ដែលអាចចូលរួមសវនាការបាន ។

មេធាវីអន្តរជាតិ ម៉ៃឃើល កាណាវ៉ាស បានលើកឡើងទាក់ទងនឹងការដែលដាក់ឲ្យ អៀង សារី ចូលរួមសវនាការនៅបន្ទប់ខាងក្រោមដែលមានភ្ជាប់ប្រព័ន្ធសោទស្សន៍នោះ មិនមែនមានន័យថា ជនជាប់ចោទមានលទ្ធភាពអាចចូលរួមសវនាការបាននោះទេក្នុងករណីដែលជនជាប់ចោទសំរាន្តលក់ ។ មេធាវីនៅតែប្រកាន់ជំហររបស់ខ្លួនក្នុងការស្នើសុំឲ្យមានការតែងតាំងមេធាវីម្នាក់ ដើម្បីតាមដានស្ថានភាពរបស់ជនជាប់ចោទពេលកំពុងចូលរួមសវនាការនៅបន្ទប់ខាងក្រោម ដោយយោងទៅលើវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង ។ ចំពោះការលើកឡើងរបស់មេធាវីកាណាវ៉ាស ត្រង់ចំណុចនេះ គឺមានការគាំទ្រពីមេធាវីការពារក្តី នួន ជា គឺលោក អេនឌ្រូ អ៊ីនូហ្វ៊ី ទាក់ទងនឹងបញ្ហាផ្លូវច្បាប់ និងការចូលរួមដោយប្រសិទ្ធភាពរបស់ជនជាប់ចោទ ។


មេធាវីការពារក្តី ម៉ៃឃើល កាណាវ៉ាស
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)


សហព្រះរាជអាជ្ញារងអន្តរជាតិ វីល្លៀម ស្មីត
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដើម្បីឲ្យអង្គជំនុំជម្រះធ្វើការពិភាក្សាដោះស្រាយបញ្ហានេះ ចៅក្រម និល ណុន បានប្រកាសផ្អាកសវនាការរយៈពេល៣០ នាទី ។ ក្រោយមក ចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ បានអានសេចក្តីសម្រេច ដោយយោងទៅលើរបាយការណ៍របស់អ្នកជំនាញដែលបញ្ជាក់ថា អៀង សារី មិនអាចចូលរួមសវនាការដោយផ្ទាល់បានយូរទេ ហើយស្ថានភាពសុខភាពរបស់ជនជាប់ចោទមានការប្រែប្រួលពីពេលមួយទៅពេលមួយ ដូច្នេះអង្គជំនុំជម្រះបានសម្រេចថា :

- មិនចាំបាច់ឲ្យមានការកោះហៅគ្រូពេទ្យមកធ្វើការសាកសួរទេ ដោយសារអង្គជំនុំជំនុំជម្រះបានទទួលរបាយការណ៍ពីគ្រូពេទ្យរួចហើយ ។
- បង្គាប់ឲ្យជនជាប់ចោទ អៀង សារី ចូលរួមសវនាការនៅបន្ទាប់ខាងក្រោមដែលមានរៀបចំឧបករណ៍រួចជាស្រេច ។
- មិនអនុញ្ញាតឲ្យមានការថតវីដេអូពីបន្ទប់របស់ជនជាប់ចោទទេដោយអង្គជំនុំជម្រះបញ្ជាក់ថា រាល់ការតាមដានសុខភាពរបស់ជនជាប់ចោទ គឺជាភារកិច្ចរបស់គ្រូពេទ្យតែប៉ុណ្ណោះ ហើយគ្រូពេទ្យត្រូវរាយការណ៍ជូនអង្គជំនុំជម្រះ ។

បន្ទាប់មក មេធាវី កាណាវ៉ាស បានលើកឡើងបន្តដោយស្នើសុំឲ្យមានមេធាវីថតជាវីដេអូដើម្បីឲ្យមានការកត់ត្រានៅក្នុងប្រតិចារិកដោយមេធាវីបានលើកឡើងនូវហេតុផលថា ក្នុងករណីដែល អៀង សារី សំរាន្តលក់ ព័ត៌មាននោះនឹងត្រូវបានកត់ត្រានៅក្នុងប្រតិចរិក ហើយប្រសិនបើកិច្ចដំណើរនេះមិនមាននៅក្នុងប្រតិចារិកទេ ខ្លួននឹងមិនចូលរួមនៅក្នុងដំណើរការសវនាការនេះទេ ។ មេធាវីបានបន្តទៀតថា សហព្រះរាជអាជ្ញាហាក់បីដូចជាមិនយកចិត្តទុកដាក់ចំពោះសិទ្ធិកូនក្តីខ្លួនទាល់តែសោះ ទើបសហព្រះរាជអាជ្ញាមិនគាំទ្រឲ្យមានការបំពាក់វីដេអូនៅបន្ទប់កូនក្តីខ្លួន ។ សហព្រះរាជអាជ្ញារង វីល្លៀម ស្មីត បានលើកឡើងថា ចំពោះបញ្ហាសុខភាពរបស់ អៀង សារី ត្រូវតែមានការកត់ត្រានៅក្នុងសៀវភៅកត់ត្រាដែលមានរួចជាស្រេច ។ ចំណែកឯការថតវីដេអូវិញ សហព្រះរាជអាជ្ញាបានបដិសេធចំពោះការលើកឡើងរបស់មេធាវីការពារក្តីដែលថា សហព្រះរាជអាជ្ញាមិនមានការបារម្ភអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ ដោយអះអាងថា បញ្ហាសុខភាព គឺជារឿងសំខាន់ដែលអាចនាំឲ្យតុលាការដំណើរការទៅមុខបាន ។ ទោះបីជាយ៉ាងណា ចំណុចនេះត្រូវបានភាគីទាំងពីរលើកឡើងសារជាថ្មី ប៉ុន្តែត្រូវបានសម្របសម្រួលដោយចៅក្រម

អន្តរជាតិ ស៊ីលវៀ ខាតព្រ៉ាយត៍ ដោយបញ្ជាក់ជាថ្មីថា អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមានការថតវីដេអូនោះទេ ហើយអង្គជំនុំជម្រះក៏មិនកែប្រែសេចក្ដីសម្រេចរបស់ខ្លួនកាលពីមុននោះដែរ ។

បញ្ហាមួយទៀតត្រូវបានលើកឡើងដោយមេធាវីអន្តរជាតិ អ៊ីនូស្ស៊ី ជាមេធាវីការពារក្ដី នួន ជា ទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការចោទសួរដើមបណ្ដឹងរដ្ឋប្បវេណីតាមរយៈអង្គជំនុំជម្រះ ។ បញ្ហានេះ បានកើតឡើងនៅពេលចុងបញ្ចប់នៃសវនាការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី ចៅ នី ខណៈពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានស្នើសុំដល់អង្គជំនុំជម្រះ ដើម្បីសាកសួរជនជាប់ចោទ ខៀវ សំផន ទាក់ទងនឹងការចាប់ឪរបស់ខ្លួនយកទៅសម្លាប់ ។ មេធាវីអន្តរជាតិ អ៊ីនូហ្ស៊ី បានបន្តលើកឡើងទាក់ទងនឹងសេចក្ដីសម្រេចរបស់ចៅក្រម និល ណុន ដោយមេធាវី បានរៀបរាប់ថា នៅពេលនោះ ចៅក្រម ឡាវីញ រៀបនឹងឆ្លើយតបជាមួយមេធាវីអន្តរជាតិការពារក្ដី ខៀវ សំផន គឺកញ្ញា អង់គា ហ៊ីសេ ប៉ុន្ដែចៅក្រម ខាតព្រ៉ាយ បាននិយាយជាមួយចៅក្រម និល ណុន ថាឲ្យមេធាវីអង្គុយចុះវិញ ។ មេធាវីបានបន្តថា រាល់ការសម្រេចរបស់អង្គជំនុំជម្រះហាក់ដូចជាមិនមែនជាសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទាំងមូលនោះទេ ។ ឆ្លើយតបនឹងការលើកឡើងនេះ ចៅក្រម និល ណុន បានបញ្ជាក់ថា តុលាការបានបែងចែកឆន្ទានុសិទ្ធិរបស់ប្រធាន និងការសម្រេចជាសមូហភាពច្បាស់លាស់ ហើយលោកបានព្យាយាមអនុវត្តតាមនីតិវិធីច្បាប់ ។ តែទោះជាយ៉ាងនេះក្ដី ចៅក្រម និល ណុន បានថ្លែងអំណរគុណដល់មេធាវីដែលបានកត់សម្គាល់លើបញ្ហានេះ ។

បន្ទាប់ពីបញ្ចប់ការលើកហេតុផលរបស់ភាគី ចៅក្រម និល ណុន បានប្រកាសបន្តសវនាការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីជាបន្តទៀត ។

### ១) ប្រវត្តិសាវតាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទឹង សុខា

ដើមបណ្ដឹងរដ្ឋប្បវេណីមានឈ្មោះ ទឹង សុខា កើតនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៤៧ នៅភូមិស្វាយតានាន់ ឃុំតានេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ហើយសព្វថ្ងៃខ្លួនរស់នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាមន្ត្រីចូលនិវត្តន៍ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តថា ខ្លួនមានឪពុកឈ្មោះ ទឹង គុយ និងម្ដាយ លី ប៉ាច ព្រមទាំងមានកូនពីរនាក់ ។ បន្ទាប់មក លោកប្រធានបានបញ្ជាក់ប្រាប់អំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងអំពីសេចក្ដីទុក្ខសោក និងការបាត់បង់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលចុងបញ្ចប់នៃការសួរដេញដោល ។ បន្ទាប់មក លោកចៅក្រមបានផ្ទេរវេទិកាជូនមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបន្តទៀត ។

### ២) ការសាកសួរសាក្សីដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសាកសួរសាក្សីដោយចៅក្រម និល ណុន សហមេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពេជ្រ អង្គ បាន



ដើមបណ្ដឹងរដ្ឋប្បវេណី ទឹង សុខា (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្ទេរសិទ្ធិក្នុងការសាកសួរសាក្សីជូនមេធាវីជាតិ សំ សុគង់ និងសហមេធាវី អន្តរជាតិ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត ។

#### ក) មេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

មេធាវីជាតិ សំ សុគង់ បានចាប់ផ្ដើមសាកសួរសាក្សីលើបញ្ហាចំនួនបី គឺព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ ការជម្លៀសលើកទី១ និងលើកទី២ ។

#### ក.១) ព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥

ឆ្លើយតបនឹងសំណួររបស់មេធាវីជាតិ សំ សុគង់ ទាក់ទងនឹងព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់

ថា មុនឆ្នាំ១៩៧៥ខ្លួនរស់នៅទីក្រុងភ្នំពេញនៅម្តុំវត្តទួលទំពូង ។ នៅថ្ងៃទី១៦ មេសា មានព្រឹត្តិការណ៍ផ្ទុះគ្រាប់បែក ហើយពេលនោះ បងប្អូនខ្លួនបានរត់ពីទួលគោកមកនៅជុំគ្នា ។ ពេលនោះ ខ្លួននិងបងប្អូនទាំងអស់នាំគ្នាទៅពួននៅក្នុងត្រង់សេដើម្បីលាក់ខ្លួន ។ បន្ទាប់មក នៅថ្ងៃទី១៧ មេសា ពេលព្រឹក មិនទាន់មានការជម្លៀសប្រជាជនទេ ប៉ុន្តែពេលនោះសមាជិកក្នុងគ្រួសារខ្លួនបានបំបែកគ្នា ដោយម្តាយក្មេកខ្លួនបានទៅនៅបឹងកេងកង បងប្រុសទៅនៅទឹកល្អក់ ហើយម្នាក់ៗស្ថិតក្នុងសភាពភ័យស្ញន់ស្ញោ ។ ពេលនោះ ប្អូនស្រីខ្លួនដែលមានផ្ទៃពោះបានមកនៅផ្ទះរបស់ខ្លួន ហើយក្រោយមកខ្លួនមិនដឹងថា មានបងប្អូនណា ទៅនៅកន្លែងណាទៀតទេ ដោយសារស្ថានភាពនៅពេលនោះរញ៉េរញ៉ៃខ្លាំងពេក ។ នៅពេលរសៀល មានយោធាខ្មែរក្រហមចូលមកប្រកាសឲ្យប្រជាជនចេញទៅតែពីរបីថ្ងៃប៉ុណ្ណោះ ហើយមិនបាច់យកឥវ៉ាន់អ្វីទៅច្រើនទេ ។ នៅពេលនោះ ខ្លួនបានសម្រេចចិត្តថា នឹងត្រូវចាកចេញនៅម៉ោង៥រសៀលជាមួយបងប្អូន ។

### ក.២) ការជម្លៀសលើកទី១

ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្មែរក្រហមបានប្រាប់ឲ្យប្រជាជនចេញពីទីក្រុងដើម្បីសម្អាតឲ្យអស់ខ្មាំង ហើយស្រប ពេលនោះប្រជាជនបានជម្លៀសចេញមកបណ្តើរៗហើយ ។ ដើមបណ្តឹងរដ្ឋប្បវេណី បានបន្តថា ខ្លួនបានចេញមកតាមផ្លូវមុន្នីវង្សទៅទិសខាងត្បូង ប៉ុន្តែពេលឆ្លងកាត់សាលាច្បាប់មានមនុស្សច្រើននាក់ដែលនាំឲ្យខ្លួនមានការលំបាកក្នុងការធ្វើដំណើរ ។ ក្នុងពេលបីថ្ងៃនោះ ខ្លួនបានធ្វើដំណើរមិនដឹងទិសដៅពិតប្រាកដឡើយ ។

សំណួរបន្ទាប់របស់មេធាវីជាតិ គឺទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ ដោយដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលធ្វើដំណើរ ខ្លួនមិនឃើញមានការសម្លាប់មនុស្សទេ គ្រាន់តែឮស្នូរកាំភ្លើងនៅកន្លែងឆ្ងាយៗ ។ នៅពេលព្រឹក ខ្មែរក្រហមបានប្រាប់ឲ្យប្រជាជនដើរទៅទិសខាងកើតទាំងអស់គ្នា ហើយនៅពេលនោះក៏មានមនុស្សស្លាប់នៅតាមផ្លូវច្រើនដែរ ។ ទាក់ទងនឹងសេវាកម្មព្យាបាលវិញ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្លួនមិនឃើញមានពេទ្យណាមកព្យាបាលអ្នកជំងឺនៅពេលនោះឡើយ ហើយពេលធ្វើដំណើរតាមផ្លូវ ខ្លួនបានឃើញសាកសពមនុស្សអត់មានក្បាល ហើយមានស្លៀកពាក់ខោអាវកគីរ ។ តាមរយៈឯកសណ្ឋាននេះ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា សាកសពនោះគឺជាអ្នកធ្វើការងារ ឬទាហានមិនមែនជាប្រជាជនធម្មតាទេ ។

ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្លួនបានធ្វើដំណើរទៅដល់ខេត្តតាកែវ នៅភូមិថ្នល់ដាច់ ឃុំក្រាំងលាវ ស្រុកបាទី ។ ពេលទៅដល់ដំបូង ខ្លួនបានជួបសាច់ញាតិ ហើយក៏បានរស់នៅទីនោះលាយឡំជាមួយប្រជាជនផ្សេងទៀតដែលទៅនៅទីនោះមុន ។

### ក.៣) ការជម្លៀសលើកទី២

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ពេលទៅដល់ទីនោះមានការធ្វើប្រវត្តិរូបច្រើនដង ហើយខ្លួនបានរៀបរាប់នៅក្នុងប្រវត្តិរូបនោះថា ខ្លួនមានតួនាទីជាគ្រូបង្រៀនដោយមិនហ៊ានលាក់លៀមអ្វីទេ ។ នៅទីនោះ ខ្លួនធ្វើការងារជាអ្នកជញ្ជូនដីទៅដាក់ស្រែ ។ នៅក្នុងភូមិនោះបានមួយរយៈ ខ្លួនត្រូវបានជម្លៀសជាលើកទី២ ដោយខ្មែរក្រហមប្រាប់ឲ្យទៅនៅភូមិថ្មី នៅខេត្តពោធិ៍សាត់ ។ ពេលទៅដល់ទីនោះ ខ្លួនបានឃើញស្នាមប្រឡាក់ធ្យូងនៅតាមមាត់ស្ទឹងដែលទំនងជានៅទីនោះមានមនុស្សរស់នៅកាលពីមុន ហើយនៅថ្ងៃបន្ទាប់ ខ្លួន និងគ្រួសារត្រូវបានជម្លៀសបន្តទៀត ។

មេធាវី សំ សុគង់ បានបន្តសួរទាក់ទងនឹងការសម្លាប់ក្នុងពេលជម្លៀសជាលើកទី២ ហើយដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ស្ថានភាពនៅក្នុងឡាននោះពិតជាពិបាកដោយសារមានមនុស្សច្រើនពេក ។

ដើមបណ្តឹងបានរៀបរាប់ថា នៅពេលទៅដល់បាត់ដំបង កូនស្រីរបស់ខ្លួនទីពីរបានស្លាប់ដោយសារអត់មានអាហារបរិភោគ និងគ្មានថ្នាំព្យាបាល គឺស្លាប់នៅឆ្នាំ១៩៧៦ ។ បន្ទាប់មកមេធាវីបានសួរបន្តទាក់ទងនឹងការលំបាករបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ជាការឆ្លើយតប ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ចំពោះខ្លួនគឺមានការលំបាកតាំងពីពេលជម្លៀសដោយសារពេលនោះ ខ្លួនបានបែកពីបងប្អូន ហើយពេលទៅនៅបាត់ដំបង ខ្លួនមិនមានស្គាល់នរណាម្នាក់ឡើយ ហើយមិនមានអ្វីហូបរស់នៅក្នុងព្រៃ ។ ជាងនេះទៅទៀត កូន និងឪពុករបស់ខ្លួនបានស្លាប់ជាបន្តបន្ទាប់គ្នា ។ នៅ

ពេលនោះ ស្ថានភាពមនុស្សម្នាក់ៗមើលទៅហាក់បីដូចជាខ្មោច អស់ទៅហើយ ។

### ១) សហមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

សហមេធាវីអន្តរជាតិ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វត បានបន្តការសាកសួរទាក់ទងនឹងអាយុកូនស្រីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានស្លាប់ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា កូនច្បងរបស់ខ្លួននៅពេលនោះ មានអាយុ៦ឆ្នាំ ហើយកូនទី២អាយុ៣ឆ្នាំ ។ ទៅដល់កន្លែងស្នាក់នៅ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ក្នុងរយៈពេលធ្វើដំណើរនោះ គឺមិនមានថ្នាំសង្កូវអ្វីទាំងអស់ ហើយកន្លែងដែលខ្លួនទៅដល់ដំបូងគឺនៅភូមិថ្នល់ដាច់ ចំណែកបងប្អូនផ្សេងទៀតទៅនៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ មេធាវីអន្តរជាតិ បានបន្តសួរអំពីការបែងចែកប្រជាជននៅកន្លែងដែលដើមបណ្ដឹងរដ្ឋប្បវេណីរស់នៅ ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះអ្នកដែលមកពីទីក្រុងភ្នំពេញត្រូវបានហៅថា ប្រជាជន ១៧ មេសា ។ ក្រោយមក ខ្លួនបានទៅនៅភូមិមួយទៀត គឺភូមិ



យុវជនខ្មែរក្រហមកំពុងសែងគ្រាប់ និងបាយស្អុក យកទៅសមរភូមិដើម្បីផ្គត់ផ្គង់យោធាខ្មែរក្រហម (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មេធាវីអន្តរជាតិបានចោទសួរបន្តទាក់ទងនឹងមុខរបររបស់សាក្សីនៅមុនឆ្នាំ១៩៧៥ ។ សាក្សីបានបញ្ជាក់ថា ពេលនោះខ្លួនគឺជានិស្សិតច្បាប់ ហើយប្ដីរបស់ខ្លួនគឺជាសាស្ត្រាចារ្យ ។ ទាក់ទងនឹងការចូលមកដល់ភ្នំពេញរបស់យោធាខ្មែរក្រហម សាក្សីបានបញ្ជាក់ថា យោធាខ្មែរក្រហមគ្រាន់តែប្រាប់ឲ្យប្រជាជនចេញពីទីក្រុងដើម្បីពិនិត្យមើលខ្មាំង ហើយនៅពេលឮដូច្នេះ ខ្លួនក៏នាំគ្នាចេញដោយមិនចង់ឲ្យនៅលាយឡំជាមួយខ្មាំង ។ សហមេធាវីអន្តរជាតិបានបន្តសួរទាក់ទងនឹងរយៈពេលធ្វើដំណើរក្នុងពេលជម្លៀស ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ដោយសារតែការជម្លៀសនោះមិនមានគោលដៅពិតប្រាកដ ខ្លួនបានធ្វើដំណើរជាងដប់ថ្ងៃទើប ត្រពាំងអន្ទុង ជាកន្លែងដែលមានអ្នកចេះដឹងរស់នៅច្រើន ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តថា នៅពេលជម្លៀសលើកទី១ ខ្លួនបានទៅចូលរួមប្រជុំពីរដងដែលនិយាយអំពីជោគជ័យរបស់បក្សដោយមានការសម្ដែងសិល្បៈរាំច្រៀងទៀតផង ។ បន្ទាប់មក ខ្លួនមានការភ័យខ្លាចដោយសារតែខ្មែរក្រហមចាប់ផ្ដើមនិយាយអំពីបរាជ័យរបស់ខ្មាំង ។ ទាក់ទងនឹងការជម្លៀសលើកទី២វិញ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថា អង្គការបានប្រាប់ឲ្យប្រជាជនទៅរស់នៅកន្លែងថ្មីដែលមានបាយហូប ហើយពេលនោះខ្លួនបានរត់ទៅពួនដោយសារតែបងប្អូនខ្លួនមិនចង់ឲ្យចាកចេញ ។ ក្រោយមក យោធាបានមកហៅខ្លួនឲ្យទៅនៅវត្តត្រពាំងប្រាសាទ ហើយ

នៅពេលនោះ ខ្មែរក្រហមសួរខ្លួនថាហេតុអ្វីបានជាមិនព្រមទៅតាមអង្គការ? ប៉ុន្តែពេលនោះខ្លួនបានឆ្លើយតបថា ខ្លួនមិនទៅតាមអង្គការដោយសារអង្គការ គឺជាអង្គការតែមួយប៉ុណ្ណោះ ដូច្នេះនៅទីណាក៏ដូចទីណាដែរ ។ ព្រោះដូច្នេះ យោធាទាំងនោះក៏ឲ្យខ្លួន និងអ្នកផ្សេងទៀតត្រលប់ទៅរស់នៅក្នុងភូមិត្រពាំងអង្គវិញ ។ រស់នៅទីនោះបានតែមួយខែខ្លួនត្រូវបានបញ្ជូនឲ្យទៅនៅបាត់ដំបង ហើយពេលទៅដល់បាត់ដំបង មិនមានអ្នកណាចង់ចុះពីលើឡានទេ ដោយសារនៅទីនោះគឺជាព្រៃ និងមិនមានអ្វីហូបទេ ប៉ុន្តែដោយសារតែខ្លាចខ្មែរក្រហមសម្លាប់ខ្លួន និងអ្នករួមដំណើរបានចុះពីលើឡានទៅរស់នៅក្នុងព្រៃ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅទីនោះខ្លួនមិនមានអាហារហូបចុកទេ គឺមានតែស្លឹកឈើប៉ុណ្ណោះ ។ ដោយសារតែពុំមានផ្ទះនៅ អ្នកដែលត្រូវបានជម្លៀសទៅនៅទីនោះបានចូលទៅក្នុងព្រៃដើម្បីកាប់ស្បូវមកធ្វើខ្ទមសម្រាប់ជ្រកនៅ ។ ក្រោយមក ខ្លួនបានជួបអ្នកដែលធ្លាប់ស្គាល់ម្នាក់បានប្រាប់ថា ម្តាយ និងប្អូនស្រីខ្លួនពីរនាក់ឲ្យមកហៅខ្លួនឲ្យទៅនៅភូមិមួយទៀតជាមួយឪពុកក្មេក គឺភូមិកោះត្រំ ហើយភូមិចុងក្រោយដែលខ្លួននៅ គឺភូមិស្រែអូរ នៅក្នុងស្រុកមោងឫស្សី ។ នៅឆ្នាំ១៩៧៦ កូនស្រីរបស់ខ្លួនឈឺដោយសារជំងឺរាគរុះ និងហើមជើង ដូច្នេះខ្លួនបានយកកូនទៅព្យាបាលនៅពេទ្យមោងឫស្សី ។ ដូច្នេះជំងឺក៏បានប្រសើរឡើង ប៉ុន្តែពេលដែលត្រឡប់មកវិញមិនមានអ្នកនៅមើលថែទាំកូននោះក៏ស្លាប់បាត់ទៅ ។ ចំពោះប្តីខ្លួនវិញ សាក្សីបានរៀបរាប់ទាំងអួលដើមកថា ដោយសារតែមានការភ័យខ្លាចខ្លាំង ប្តីរបស់ខ្លួនចេះតែព្យាយាមសម្លាប់ខ្លួនជាច្រើនដង ដោយមានគ្រាប់បិកគ្ពុកត្រៀមសំរាប់ហូបជានិច្ច ។ ដោយឃើញស្ថានភាពដូច្នេះ ខ្លួនបានយកគ្រាប់ប៉ិគ្គុកនោះទៅចោល និងនិយាយលួងលោមជាការលើកទឹកចិត្ត ។ ប៉ុន្តែក្រោយមក ប្តីរបស់ខ្លួនបានចង-ក សម្លាប់ខ្លួននៅលើផ្ទះទៅវិញ ។ គួរបញ្ជាក់ថា ក្នុងពេលដើមបណ្តឹងរដ្ឋប្បវេណីនិយាយរៀបរាប់អំពីរឿងនេះ ភាគីទាំងអស់នៅក្នុងបន្ទប់សវនាការរួមទាំងអ្នកចូលរួមស្តាប់សវនាការបានស្តាប់យ៉ាងយកចិត្តទុកដាក់ចំពោះស្ថានភាពលំបាករបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

### ៣) ការសាកសួរសាក្សីដោយសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល លីសាក់ បានចាប់ផ្តើមសាកសួរទាក់ទងនឹងការចាប់ខ្លួនទាហាន លន់ នល់ ដោយដើមបណ្តឹងរដ្ឋវេណីបានបញ្ជាក់ថា នៅពេលខ្លួនទៅនៅខេត្តតាកែវ លើកដំបូងមានទាហាន លន់ នល់ ជាច្រើននាក់ទៅហូបបាយ ប៉ុន្តែពីរបីថ្ងៃក្រោយមក ខ្លួនបានឮថា អ្នកទាំងនោះត្រូវបានយកទៅដាក់នៅកន្លែងផ្សេង ។ ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែពីរបីថ្ងៃក្រោយមកបានបន្តរៀបរាប់បន្តថា នៅពេលខ្លួនកំពុងស្ទូង ខ្លួនធ្លាប់បានឃើញ តាម៉ុក ជិះឡានកាត់កន្លែងខ្លួនធ្វើការ ហើយមាននីសារមកជាមួយដែរ ។ សំណួរចុង ក្រោយរបស់តំណាងសហព្រះរាជអាជ្ញា គឺទាក់ទងនឹងការចូលមកនៅភ្នំពេញមុនឆ្នាំ១៩៧៥ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ខ្លួនបានចូលមកនៅភ្នំពេញនៅឆ្នាំ១៩៦៥ ហើយបាននៅរៀន និងធ្វើការនៅទីនោះរហូតដល់ឆ្នាំ១៩៧៥ ទើបខ្លួនធ្វើជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ ហើយនៅពេលនោះខ្លួនមានជីវភាពធូរធា ប៉ុន្តែចូលមកដល់ឆ្នាំ១៩៧៥ អ្វីៗគឺខុសស្រឡះពីមុនទាំងអស់ ។

### ៤) ការសាកសួរសាក្សីដោយមេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិ ហ្សាស្តើ ប៉ៅ បានសាកសួរទាក់ទងនឹងការជម្លៀសនៅឆ្នាំ១៩៧៥ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅពេលនោះមានក្មេងម្នាក់មកស្នាក់នៅរៀននៅផ្ទះរបស់ខ្លួន ហើយមានបងប្អូនផ្សេងទៀតបានមកនៅផ្ទះរបស់ខ្លួននិងជួលផ្ទះអ្នកជិតខាងដើម្បីស្នាក់នៅគេចពីការទម្លាក់គ្រាប់បែក ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះ បងប្អូនដែលមកពីតាមខេត្តនោះបានយកស្បៀងមកខ្លះដែរ ប៉ុន្តែពេលមានការខ្វះខាតបងប្អូនទាំងនោះខំធ្វើការនៅភ្នំពេញបន្ថែមទៀត ។ នៅពេលនោះ ទំនិញនៅលើទីផ្សារមានតម្លៃខ្ពស់រួមទាំងអង្ករ និងប្រេងសាំង ហើយពេលនោះមាន«អ៊ីឡូ»ជាប្លុកដែលបង្កើតដោយអាមេរិកដើម្បីលក់អង្ករ ហើយខ្លួនបានទៅទិញអង្ករនៅទីនោះដែរ ។ មេធាវីបានបន្តសួរទាក់ទងនឹងជនភៀសសឹកដែលចូលមកនៅទីក្រុងភ្នំពេញនៅសណ្ឋាគារកាំបូឌីយ៉ាណា ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្លួនមិនបានឃើញមានអ្នកទាំងនោះទេ ដោយគ្រាន់តែឮតាមម្តាយខ្លួនតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត ខ្លួនបានដឹងថាពេលនោះមានការប្រកាសរកអំណោយសម្រាប់ជួយអ្នកជំងឺ

និងជនភៀសខ្លួនដែរ ប៉ុន្តែខ្លួនមិនបានដឹងពីបញ្ហាជនភៀសខ្លួននោះច្រើនទេ ។

មេធាវីអន្តរជាតិ ហ្សាស្ទើ ប៉ៅ បានបន្តសួរដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងការចែករំលែកស្បៀងឲ្យបងប្អូននៅមុនពេលខ្មែរក្រហមចូលមក ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ពេលនោះខ្លួន និងសាច់ញាតិបានចែករំលែកអាហារគ្នាទៅវិញទៅមកដែរទៅតាមតែអ្វីដែលខ្លួនមាន ។

បន្ទាប់ពីបញ្ចប់ការសាកសួរដោយមេធាវីការពារក្តី នួន ជា ចៅក្រមបានប្រកាសឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបានថ្លែងអំពីទុក្ខសោករបស់ខ្លួនដោយសារមេធាវីជនជាប់ចោទ ខៀវ សំផន និង អៀង សារី មិនមានសំណួរសម្រាប់សាកសួរសាក្សីរូបនេះ ។

## ៥) ការថ្លែងទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី

"ចាស៎ សូមគោរពលោកប្រធាន សូមអគុណសហព្រះរាជអាជ្ញា ព្រមទាំងលោក លោកស្រី មេធាវីទាំងអស់ដែលបានតាមដានសវនាការនៅក្នុងថ្ងៃនេះ ។ ដូច្នេះ ខ្ញុំមានសេចក្តីត្រេកអរដែលលោកប្រធានតុលាការមេត្តាឲ្យខ្ញុំធ្វើសេចក្តីថ្លែងការណ៍ខ្លះអំពីព្យនកម្មដែលខ្ញុំទទួលរងនៅចន្លោះឆ្នាំ១៩៧៥ មកដល់ ឆ្នាំ ១៩៧៩ និងបន្តឡើងដោយរបបខ្មែរក្រហម ។

ខ្ញុំសូមជម្រាបដល់លោកប្រធានថា ពាក្យពេចន៍ទាំងអស់ដែលរៀបរាប់នៅក្នុងសេចក្តីថ្លែងការណ៍នេះ សុទ្ធសឹងជាការពិត សុទ្ធសឹងជាពាក្យសច្ចៈ ដោយគ្មានការបំភ្លើសណាមួយឡើយ ។ ផ្ទុយទៅវិញ គឺខ្ញុំ នាងខ្ញុំទៅវិញទេដែលបានព្យាយាមបំភ្លេចចោលនូវរឿងរ៉ាវជាច្រើន ដោយសារថា ពុំនោះសោតទេ វានឹងវែងពេក វាធ្ងន់ធ្ងរពេក សាហាវពេក និងគួរឲ្យខ្មាសអៀនខ្លាំងណាស់ផង ។

វាគឺជាមហាសោកនាដកម្មដែលគួរឲ្យសោកស្ដាយ ហើយវាពិតជាពិបាកក្នុងការស្វែងរកពាក្យណាមកដាក់ឲ្យសមល្មម ដើម្បីរៀបរាប់ឲ្យសមល្មម ដើម្បីរៀបរាប់អំពីព្រឹត្តិការណ៍ទាំងអស់នោះដែលយើងបានឆ្លងកាត់ ។ វាគឺជារឿងមួយដែលហួសពីការស្រមៃ និងពុំអាចទទួលយកបាន ។ យើងបានខិតខំរបស់ នៅក្រោយឆ្នាំ ១៩៧៩មកទៀត យើងបានជួបជុំសាច់ញាតិរបស់យើងខ្លះ ប៉ុន្តែយើងក៏បានទទួលដំណឹងជា ពិសេសអំពីការបាត់បង់បងប្អូនរបស់យើង ដែលត្រូវបានគេសម្លាប់ វាយធ្វើបាប បង្អត់អាហារ និងធ្វើទារុណកម្មនៅទីកន្លែងផ្សេងៗដែលគេជម្លៀសយកទៅទាំងដំណាក់កាលទី១ និងទាំងដំណាក់កាលទី២ទៅវិញ ។

នៅពេលមានការជម្លៀសពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ មេសា ៧៥ ពេលនោះវាប្រៀបបានទៅ នឹងគ្រាប់បែកខ្យល់ផ្ទុះមកបំបែកក្រុមគ្រួសាររបស់អ្នកភ្នំពេញអ៊ីចឹង ។ ពួកយើងវង្វេងគ្នាពួកយើងត្រូវបែកបាក់គ្នាក្នុងរយៈពេលមួយព្រិចភ្នែក ។ ពួកយើងបែកពីបងប្អូន ពីមិត្តភក្តិ ហើយយើងខ្ញុំបានបាត់បង់នូវទ្រព្យសម្បត្តិទាំងអស់មួយរំពេច ។ យើងបាត់ដំណឹងរបស់ពួកគេរហូតដល់សព្វថ្ងៃនេះ ។

ដំណាក់កាលពី២នៃការជម្លៀស គឺប្រហែលជាខែកញ្ញា ឆ្នាំ ១៩៧៥ ខ្លួនទទេ ឃ្លាតឆ្ងាយពីស្រុកភូមិកំណើត ពីញាតិសន្តាន និងពីមិត្តភក្តិជិតស្និទ្ធ គេបានឲ្យពួកយើងទៅនៅក្នុងព្រៃលិចទឹក មិនស្គាល់ទីតាំង ហើយគ្មានអ្វីហូបទេ គ្មានផ្ទះ គ្មានជម្រក អត់ស្គាល់ភូមិចាស់ណាម្នាក់សោះ ។

កាលពីដំបូង ពួកយើងរស់នៅតាមដងផ្លូវរថភ្លើងនៅគោកត្រាំ ។ ពួកយើងគ្មានសម្ភារៈដើម្បីកាប់គាស់ព្រៃទេ ។ ពេលនោះចំពេលរដូវភ្លៀង ហើយភ្លៀងធ្លាក់យ៉ាងពេញបន្ទុក ។ យើងគ្មានសិទ្ធិដើរហើរទេ ។ ពួកយើងរស់នៅក្នុងចំណោមអ្នកជម្លៀសដូចៗគ្នា ហើយពួកយើងជាអ្នកអត់ដូចគ្នាទៀត ។ ដូច្នេះ ពួកយើង ពួកយើងទាំងអស់គ្នាស្លាប់ដោយគ្មានបាយហូប ។ ស្លាប់ដោយជំងឺគ្មានថ្នាំសង្កូវអ្វីសោះតែម្ដង ។ ដំណាក់កាលនេះ ខ្ញុំកាន់តែមើលឃើញច្បាស់ហើយ គិតថា វាជាវិធីសម្លាប់រង្គាល ជាពិសេសគឺសម្លាប់ជនជម្លៀសពីភ្នំពេញដោយយកទៅចាក់ចោលឲ្យលំបាកវេទនា និងទុកស្លាប់ក្នុងព្រៃនេះតែម្ដង ។

ពួកគេឲ្យយើងស្លាប់ដោយគ្មានចេញឈាម ពួកយើងមានសភាពស្គេកស្គាំង និងស៊ិតក្រញ៉ង់តែម្ដង ។ យើងរស់នៅដូចជាសត្វព្រៃ ស៊ីសត្វម្រឹមព្រះ មានពេលខ្លះស៊ីដីឯចក់ ឬដើមច្រោះស្វា ស៊ីគល់ត្រកួន ឫសកំប្លោក ។ល ។ ...និយាយឲ្យខ្លីឲ្យតែជួបអ្វីក៏ហូបឲ្យតែពេញពោះ ស្លឹកថ្នឹងដែលមានរសជាតិជូរ បែរជាទៅជាផ្អែម ។ យើងឃ្លានស្ទើរស្លាប់ ភ្នែកប្រែល្អក់មានសភាពដូចសាកសព សម្លេងខ្សោយព្ធខ្សាវៗ ។ នេះគឺជាមហាគុកឥតជញ្ជាំងមួយលើសពីសត្វព្រៃនៅភ្នំតាម៉ៅដែលគេចិញ្ចឹមគេឲ្យសាច់ គេឲ្យ

អាហារជានិច្ច ។ វាពិតជាសាហាវឃោរឃៅខ្លាំងណាស់ ។ នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំបានបាត់បង់កូនស្រី បាត់បង់ឪពុកក្មេក ប្អូនថ្លៃពីរនាក់ ប្តីខ្ញុំធ្វើអត្តឃាត កូនស្រីរបស់ខ្ញុំម្នាក់ទៀតបាត់បង់សម្លេងគឺគរ ។

ដូច្នេះដំណាក់កាលទី២នេះគឺ...ការជម្លៀសនេះពិតជាមានការលំបាកខ្លាំងណាស់ ។ ខ្លាំងលើសពីកាលទី១ទៅទៀត ។ ការជម្លៀសទាំងពីរនេះគឺពិតជាមានមានមហាទុក្ខហួសប្រមាណ ។ ពួកយើងមានសភាពទ្រុឌទ្រោមរាងកាយ កម្លាំងខ្សោយ ទាំងស្មារតីទាំងកម្លាំង វាជាមហាទុក្ខសោកដែលបានទុក្ខសោក ដែលបានដក់ទុកនៅក្នុងខួរក្បាលរបស់ខ្ញុំ ។ នៅពេលដែលខ្ញុំបាត់បង់កូនស្រីគឺជាពេលខ្លោចផ្សាបំផុតសម្រាប់ខ្ញុំ ស្ទើរតែធ្វើឲ្យខ្ញុំឆ្កួតវង្វេងស្មារតី ។ កូនខ្ញុំបានស្រែកហៅខ្ញុំពីរម៉ោតប៉ុណ្ណោះមុននឹងផុត ។ មុននឹង១ស្លាប់ ។ ពេលដែលខ្ញុំឃើញគេមករើសយកសាកសពកូនស្រីរបស់ខ្ញុំ មិនដឹងជាគេ...ខ្ញុំមិនដឹងជានិយាយអ្វីកើតឡើយ ខ្ញុំមិនដឹងជារៀបរាប់ប្រាប់ទៅកាន់អ្នកណាឡើយ ពីព្រោះជាការឈឺចាប់របស់...ចំពោះការឈឺចាប់របស់ខ្ញុំនេះ ។ គេដាក់កូនស្រីខ្ញុំក្នុងអង្រឹងតែមួយដែលមានខ្មោចប្រាំបីនាក់ ។ ពេលពេលស្វាមីរបស់ខ្ញុំបានធ្វើអត្តឃាត ខ្ញុំសែនរន្ធត់ខ្លាំងណាស់ ព្រោះឃើញសាកសពគាត់ព្យួរនៅឯដំបូលផ្ទះ យូរបន្ត្រេតក្នុងខ្យល់ ។ ខ្ញុំយំៗដោយគ្មានទឹកភ្នែកហូរ ។ ខ្ញុំចង់យំឲ្យស្រាកស្រាន្តនូវការឈឺចាប់របស់ខ្ញុំខ្លាំងណាស់ ប៉ុន្តែខ្លាចអីនឹងគេដឹង ។ យើងក៏អាចស្លាប់ទៀតដោយគេអាចចោទយើងពីរឿងអ្វីមួយ ។ ខ្ញុំរន្ធត់លើសពេលណាៗទៅទៀត ខ្ញុំស្ទើរតែឆ្កួតទៅហើយ ។ ការឈឺចាប់ទាំងអស់នេះបានដក់ជាប់នៅជាមួយខ្ញុំរហូតដល់ថ្នាក់ខ្ញុំខ្លួនឯងផ្ទាល់ក៏ចង់សម្លាប់ខ្លួនឯងដែរ ខ្ញុំខឹងនឹងខ្លួនឯងដែលអសមត្ថភាពមិនអាចជួយបងប្អូនបាន ។

ពុំមានការសង្ឃឹម...ខ្ញុំមានការអស់សង្ឃឹមជាខ្លាំង ។ កាលពីមុន ខ្ញុំបាននិយាយប្រាប់ខ្លួនឯងថា "ខ្ញុំត្រូវតែធ្វើយ៉ាងណាដើម្បីមើលថែរក្សាកូនរបស់ខ្ញុំឲ្យបានល្អ" ក៏ប៉ុន្តែនៅទីបំផុតកូនរបស់ខ្ញុំស្លាប់នៅនឹងដៃនៅនឹងភ្នែករបស់ខ្ញុំ ។ ខ្ញុំថែមទាំងបានសុំរបស់ខ្ញុំឲ្យសម្លាប់ខ្ញុំទៀតផង ខ្ញុំមិនចង់រស់នៅក្នុងស្ថានភាពលំបាកឃោរឃៅបែបនេះទៀតទេ ។ ប្តីខ្ញុំបានឱបខ្ញុំ ហើយប្រាប់ខ្ញុំថា "ខ្លួនសុទ្ធតែឆ្អឹង" បានន័យថា បន្តិចទៀតគង់តែស្លាប់ដែរ បែបចង់មានប្រសាសន៍អីចឹង ។

សូមលោកប្រធានមេត្តាជ្រាប នេះគ្រាន់តែជារឿងសង្ខេបប៉ុណ្ណោះ ។ ដោយសារថា ខ្ញុំមិនអាចរៀបរាប់សាច់រឿងទាំងអស់នេះនៅពេលនេះបានទេ ។ រួមសេចក្តីមក ស្មារតីរបស់ខ្ញុំមានការប៉ះទង្គិចខ្លាំងបំផុត ។ ខ្ញុំពិតជាមិនចង់រស់នៅក្នុងស្ថានភាពឈឺចាប់ម្តងទៀតទេ ។ ប៉ុន្តែស្លាកស្នាមទាំងអស់នោះមិនអាចរលត់បាត់ពីការចងចាំរបស់ខ្ញុំសោះឡើយ ។ ការចងចាំរបស់មនុស្សមិនមែនដូចជាការលុបសម្លេងពីខ្សែអាត់ ដែលយើងអាចលុបបានដោយងាយៗនោះទេ ។ ខ្ញុំនៅតែដេកស្រក់ទឹកភ្នែក ពេលណាដែលខ្ញុំនឹកដល់កូន នឹកដល់ឪពុកម្តាយដែលបែកទៅ ខ្ញុំនៅតែញ័រចំប្រប់ ។ ពេលខ្លះខ្ញុំយំទោះជានៅកន្លែងណាក៏ដោយ ។ ខ្ញុំបានងាកទៅរកធម៌ព្រះពុទ្ធដើម្បីសម្រាលទុក្ខសោករបស់ខ្ញុំបានតែមួយខណៈៗបានតែប៉ុណ្ណោះ ។ ប៉ុន្តែនិយាយអំពីការបាត់បង់ជាសម្ភារៈវិញ ខ្ញុំបានបាត់បង់ទ្រព្យសម្បត្តិទាំងអស់របស់ខ្ញុំ បូករួមទាំងផ្ទះរបស់ខ្ញុំមួយផង ទាំងអស់មានតម្លៃ៩២៥,១តម្លឹងមាស ។ ខ្ញុំបាត់បង់កូនស្រីរបស់ខ្ញុំ ឪពុកម្តាយ បងប្អូនសរុបចំនួនប្រាំបីនាក់ ។ ពងប្អូនជីដូនមួយសរុមចំនួន២៥នាក់ផុតពូជ ។ ជីទូតមួយសរុបចំនួនប្រាំបីនាក់ ។ មិត្តភក្តិជិតស្និទ្ធសរុបចំនួនប្រាំបីនាក់ ។

ក្រោយពេលចប់របបខ្មែរក្រហម ខ្ញុំស្ទើរតែអស់សមត្ថភាពក្នុងការបំពេញកិច្ចការ ធ្វើការងាររតែដដែលៗ ដោយមិនអាចអភិវឌ្ឍន៍ខ្លួនបាន ។

ខ្ញុំនៅតែយល់សប្តិ៍អាក្រក់ មមើមមាយ ដើមទ្រូងញ័រថប់ដង្ហើម អស់សេចក្តីក្លាហាន ។ ចង់គេង លុះតែមានថ្នាំទើបគេងលក់ ។ ខ្ញុំចង់ឲ្យដំណើរការក្តីនេះអាចឲ្យមនុស្សជំនាន់ក្រោយចងចាំ និងយល់ឲ្យបានច្បាស់អំពីសម័យនោះ ។

នៅទីបញ្ចប់នេះ នាងខ្ញុំសូមលោកប្រធាននៃអង្គជំនុំជម្រះដ៏ស័ក្តិសិទ្ធិ ជួយផ្តល់នូវយុត្តិធម៌ឲ្យដល់នាងខ្ញុំ ដល់ក្រុមគ្រួសារនាងខ្ញុំ និងដល់ជនរងគ្រោះទាំងឡាយ ទាំងអ្នកដែលនៅរស់រានមានជីវិត និងទាំងអ្នកដែលបាត់បង់ជីវិតទៅ ឲ្យគេបានអស់ចិត្តឲ្យបានពេញចិត្ត និងឲ្យបានសុខស្ងប់រៀងទៅ ។ សូមអគុណ ។ សូមជម្រាបលា ។

# ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល និង គីម វ៉ាន់ឌី

## ថ្ងៃទី៥-៦ ខែធ្នូ ឆ្នាំ២០១២

នៅថ្ងៃទី៥-៦ ខែធ្នូ ឆ្នាំ២០១២អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសវនាការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីពីររូប ។ ដើមបណ្តឹងរដ្ឋប្បវេណីទី១មានឈ្មោះ ពេជ ស្រីផល ដែលត្រូវបានដេញដោលអស់រយៈពេលជិតមួយថ្ងៃ ។ ចំណែកដើមបណ្តឹងរដ្ឋប្បវេណីទី២ ឈ្មោះ គីម វ៉ាន់ឌី ដែលត្រូវបានសួរដេញដោលចាប់ពីលាចថ្ងៃទី៥រហូតដល់ថ្ងៃទី៦ ។

សវនាការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបបានផ្តោតជាសំខាន់លើស្ថានភាពរស់នៅរបស់ប្រជាជននៅទីក្រុងភ្នំពេញនៅមុនពេលនៃការជម្លៀស, ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅដំណាក់កាលទី១ និងដំណាក់កាលទីពីរ ។ ការសួរដេញដោល ដោលនេះមានការខុសប្លែកពីការសួរដេញដោលសាក្សី ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកតាំងសំណួរមុន សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីបន្ទាប់ពីបញ្ចប់ការសួរដោញដោលរបស់ប្រធានអង្គជំនុំជម្រះ ។

មុនពេលចាប់ផ្តើមមេធាវីអន្តរជាតិ ម៉ៃឃើល កាណាវ៉ាសបានលើកឡើងទាក់ទងនឹងស្ថានភាពសុខភាពកូនក្តីខ្លួនដែលបញ្ជាក់ថា អៀង សារី មិនអាចមានលទ្ធភាពចូលរួមសវនាការដោយផ្ទាល់នៅបន្ទប់សវនាការដែលតម្រូវឲ្យជនជាប់ចោទចូលរួមសវនាការនៅបន្ទប់ខាងក្រោម ។ ចំណុចមួយទៀត គឺមេធាវី បានបញ្ជាក់ថារាល់ពេលដែលខ្លួនបានក្រោកឈរនិយាយ គឺជាការនិយាយក្នុងនាមជនជាប់ចោទ អៀង សារី តែប៉ុណ្ណោះ មិនមែនក្នុងនាមខ្លួនផ្ទាល់នោះឡើយ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាបានស្នើសុំឲ្យមានការបង្ហាញរបាយណ៍ពីគ្រូពេទ្យឲ្យបានលឿនទាន់ពេលដើម្បីកុំឲ្យមានការយឺតយ៉ាវក្នុងដំណើរការសវនាការ ។ បន្ទាប់មកមេធាវី អាង ឧត្តម បានកត់សម្គាល់លើរបាយការណ៍របស់គ្រូពេទ្យដោយស្នើសុំឲ្យមានការបញ្ជាក់ឲ្យច្បាស់លាស់អំពីបញ្ហាសុខភាពរបស់កូនក្តីខ្លួន ។

បន្ទាប់ពីបញ្ចប់ការពិភាក្សាអំពីបញ្ហាទាក់ទងនឹងរបាយការណ៍សុខភាពរបស់ អៀង សារី ចៅក្រម និល ណុន បានបន្តដោយសាកសួរដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោម ។

### ១) ប្រវត្តិសាវតាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ខ្លួនមានឈ្មោះ ពេជ ស្រីផល កើតនៅថ្ងៃទី២៤ខែតុលា ឆ្នាំ១៩៥២ នៅភូមិស្វាយប៉ោ ឃុំស្វាយប៉ោ ស្រុកត្រពាំងជង ខេត្តពោធិ៍សាត់ ។ សព្វថ្ងៃមានតួនាទីជាជំទប់ទី១ ឃុំត្រពាំងជង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថាខ្លួនមានឪពុកឈ្មោះ ពេជ និល និងម្តាយ កែ គីមអ៊ី ព្រមទាំងមាន


ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

កូនពីរនាក់ ។ បន្ទាប់មក ចៅក្រម និល ណុន បានបញ្ជាក់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលដំណើរការសវនាការ និងសិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការណ៍ ដើម្បីរៀបរាប់អំពីទុក្ខសោកដែលខ្លួនបានជួបប្រទះ ។

### ១.ក) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិ ជេត វ៉ាន់លី បានចាប់ផ្តើមសាកសួរដោយផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ ព្រឹត្តិការណ៍ជម្លៀស

នៅក្នុងដំណាក់កាលទី១ និងដំណាក់កាទី២ ។

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅមុនឆ្នាំ១៩៧៥ ខ្លួនរស់នៅទួលគោក ហើយនៅពេលនោះប្តីរបស់ខ្លួន គឺជាពេទ្យទាហានលន់ នល់ ធ្វើការនៅមន្ទីរពេទ្យកាល់ម៉ែត ។ មុនឆ្នាំ១៩៧៥ ខ្លួនបានផ្លាស់ទីលំនៅមករស់នៅជាមួយអ៊ំនៅឃ្លាំងរំសេវ ។ នៅពេលនោះភ្នំពេញមានសភាពការណ៍វឹកវរ និងមានប្រជាជនច្រើនរស់នៅក្នុងទីក្រុង ទំនិញឡើងថ្លៃ និងមានការផ្ទោងគ្រាប់នាំឲ្យមានមនុស្សរបួសនិងស្លាប់ជាច្រើននាក់ ។ នៅពេលនោះ ឪពុកខ្លួនថា នៅពេលនោះមានយោធាចូលមកដើរជាជួរៗ និងស្រែកនៅតាមផ្លូវថា“ភ្នំពេញបានរំដោះ ហើយប្រទេសយើងបានសន្តិភាពហើយ ! ” ។ ពេលនោះខ្លួន និងប្រជាជនផ្សេងទៀតបានចេញមកស្រែកអបអរដោយលើកទង់ស និងខោអាវពណ៌សរដើម្បីទទួលយោធាខ្មែរក្រហម ។ ពេលនោះទាហានបានប្រកាស តាមមេក្រូឲ្យប្រជាជនចេញពីទីក្រុងឲ្យអស់ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់អាមេរិក ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តទៀតថា ពេលនោះខ្មែរក្រហមបានប្រាប់ឲ្យប្រជាជនចេញពីទីក្រុងតែក្នុងរយៈ



ប្រជាជន និងជនរងគ្រោះនៃរបបខ្មែរក្រហមកំពុងឈរតម្រង់ជួររង់ចាំចូលរួមតាមដានការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម នៅក្នុងសាលសវនាការនៃសាលាក្តីខ្មែរក្រហម (ប្រភពរូបថត : អ.វ.ត.ក)

ពេលបីថ្ងៃតែប៉ុណ្ណោះ ។ នៅពេលនោះ ខ្លួនមានការភ័យខ្លាចដោយសារតែយោធាខ្មែរក្រហមបង្ខំឲ្យប្រជាជនចេញ ហើយបើមិនចាកចេញទេ យោធានឹងបាញ់សម្លាប់ ហើយអ្នកដែលមានស្លៀកឯកសណ្ឋានទាហានត្រូវតែដោះឯកសណ្ឋាននោះចេញ និងទម្លាក់កាំភ្លើងចោល ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះខ្លួន និងគ្រួសារបានយកម្ហូបអាហារ និងសំលៀកបំពាក់ទៅជាមួយខ្លួនតែមួយចំនួនតូចប៉ុណ្ណោះ ហើយធ្វើដំណើរចេញទៅតាមស្ទឹងមានជ័យ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបគឺជាគិញរបស់អាមេរិកបានដើរស៊ើបការណ៍ ហើយបានប្រាប់ឲ្យខ្លួន មានការប្រយ័ត្នប្រយ៉ែង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់បន្ថែមថា នៅពេលនោះមានភ្នាក់ងាររបស់អង្គការសហ-ប្រជាជាតិបានយកស្បៀងមកចែកឲ្យប្រជាជន ។ ចំណែកស្ថានភាពនៅឯមន្ទីរពេទ្យកាល់ម៉ែតវិញ គឺមានអ្នកជំងឺច្រើនណាស់ ហើយនៅពេលនោះជីវភាពរស់នៅរបស់ខ្លួនក៏មិនធូរធារដែរ ដោយសារតែខ្លួនមានបងប្អូនច្រើននាក់ពេក ។ ចំពោះការចូលមកដល់នៃយោធាខ្មែរក្រហមវិញ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់

រាប់បន្តថា នៅពេលនោះ ខ្លួនបានឃើញប្រជាជនជាច្រើននាក់ធ្វើដំណើរចេញមក ហើយពេលមកដល់ពេទ្យរុស្ស៊ីមានអ្នកជំងឺជាច្រើន នាក់ក៏ចេញមកពីមន្ទីរពេទ្យដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តទៀតថា ក្នុងពេលជម្លៀសចេញផុតពីស្ទឹងមានជ័យ ខ្លួនបានឃើញប្រជាជនបីនាក់ត្រលប់មកវិញដោយសារភ្លេចយកលុយ ប៉ុន្តែយោធាមិនឲ្យអ្នកទាំងនោះត្រឡប់មកវិញទេដោយគំរាមបាញ់ទៀតផង ។ បន្ទាប់ពីការជម្លៀសរួចមក យោធាខ្មែរក្រហម បានអំពាវនាវឲ្យប្រជាជនមកកត់ឈ្មោះដោយបញ្ជាក់ថាអ្នកណាដែលធ្លាប់ធ្វើការនៅជំនាន់មុននឹងឆាប់បានចូលទីក្រុងវិញ ហើយនៅពេលនោះមានប្រជាជនច្រើននាក់ណាស់ដែលបានទៅចុះឈ្មោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅពេលជម្លៀសនោះ កូនទី១របស់ខ្លួនបានស្លាប់ដោយសារខ្លួនទាស់សសៃខ្ចី និងពុំមានទឹកដោះបំបៅកូន ។ ឆ្លើយតបនឹងសំណួរបន្ទាប់ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា រាល់សម្ភារៈទាំងអស់ត្រូវបានអង្គការប្រមូលយករួមទាំងលុយ និងមាសទៀតផង ។ ក្រោយមក ខ្លួនបានធ្វើដំណើរទៅដល់ចំការដូង ទើបបានជួបជាមួយប្តីខ្លួន ហើយក៏ធ្វើដំណើរបន្តទៅនៅព្រៃត្រប់ទាំងអស់គ្នា ។ នៅពេលទៅដល់ទីនោះ ខ្លួនត្រូវបានបំបែកឲ្យនៅក្នុងសហករណ៍ដែលមានរៀបចំរួចជាស្រេច ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់បន្ថែមថា នៅពេលកំពុងធ្វើដំណើរនោះ ខ្លួនបានចូលទៅសម្រាកនៅតាមវត្តដែលនៅក្បែរផ្លូវ ប៉ុន្តែនៅទីនោះមានការយាមកាមពីយោធាខ្មែរក្រហម ។ នៅពេលទៅដល់ព្រៃត្រប់ ខ្មែរក្រហមបានសួររកអ្នកដែលធ្វើការនៅជំនាន់ចាស់ ហើយប្រមូលគ្នាបានចំនួន៦០នាក់ដែលនៅក្នុងនោះមានអ៊ំ និងប្អូនជីដូនមួយរបស់ខ្លួនដែរ ។ ពីរថ្ងៃក្រោយមក ខ្មែរក្រហមបានយកឡានមកដឹកអ្នកដែលមានឈ្មោះទាំងនោះយកទៅនៅភ្នំពេញវិញ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា នៅពេលនោះ ឪពុករបស់ខ្លួនបានលួចបើកវិទ្យុស្តាប់ ហើយក្រោយមកខ្មែរក្រហមបានមកហៅឪពុកខ្លួន ព្រមទាំងសមាជិកគ្រួសារទាំងអស់ឲ្យត្រលប់ទៅភ្នំពេញវិញដោយជិះឡានខ្លួនឯង ។ នៅពេលធ្វើដំណើរមកតាមផ្លូវ ឡាននោះក៏អស់សាំង ហើយមានអ្នកបរទេះគោម្នាក់បានមកប្រាប់ឲ្យខ្លួនរត់ចេញកុំឲ្យទៅជាមួយខ្មែរក្រហម ព្រោះអ្នកដែលខ្មែរក្រហមមកហៅនោះ នឹងត្រូវយកទៅសម្លាប់ចោល ។ ពេលនោះខ្លួន និងគ្រួសារក៏បានគេចទៅតាមផ្លូវមួយតាមការប្រាប់របស់អ្នកបរទេះនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ទៀតថា នៅពេលធ្វើដំណើរទៅនោះ ស្រាប់តែទៅដល់បឹងអ្នកតាប្រាំរយ ហើយពេលនោះឪពុកម្តាយ ប្តី បងប្អូន និងក្មួយៗរបស់ខ្លួនបានឆ្លងទៅមុនដោយទុកខ្លួន និងជីដូនឲ្យចាំនៅត្រើយម្ខាងទៀត ។ ភ្លាមនោះ ក៏មានពន្លឺពិលចាំងមក និងឮស្នូរកាំភ្លើងបាញ់នៅម្តុំបឹង ហើយដោយសារតែភាពភ័យខ្លាច ជីដូនខ្លួនក៏បានស្លាប់នៅពេលនោះដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណី បានបន្ថែមថា នៅពេលនោះ ខ្លួន និងប្តីបានអូសសាកសពជីដូនទៅលាក់នៅក្នុងកម្ពោធព្រៃ ហើយដោយសារតែខ្លួនភ័យខ្លាច ក៏សន្លប់បាត់ស្មារតីរហូតដល់យប់ទើបដឹងខ្លួនវិញ ។ ចាប់ពីពេលនោះមក ខ្លួនបានបែកគ្នាពីឪពុកម្តាយ ហើយក៏ត្រឡប់មកក្រោយវិញទៅនៅស្រុកគងពិសីជាមួយឪពុកក្មេក ។ តែក្រោយមកទៀត ខ្លួនក៏បានចាកចេញពីឪពុកក្មេកទៅជាមួយប្តី និងអ្នក១៧មេសាជាច្រើននាក់ទៀតទៅនៅលើភ្នំ ស្វាក់ដើម្បីលាក់ខ្លួន ។ នៅទីនោះពុំមានអាហារបរិភោគទេ គឺមានតែស្លឹកឈើ និងសត្វព្រៃតែប៉ុណ្ណោះ ។ ចំណែកទឹកហូបវិញ គឺពឹងលើទឹកសន្សើមតែប៉ុណ្ណោះ ។ នៅទីនោះបានតែពីរខែ អង្គការបានហៅអ្នកដែលនៅលើភ្នំទាំងអស់នោះឲ្យត្រឡប់មកធ្វើការវិញ ហើយនៅពេលនោះមានអ្នកដែលនៅរស់តែ២០នាក់ប៉ុណ្ណោះ ។ ពេលចុះមកដល់ម្នាក់ៗ នៅសល់តែស្បែកនិងឆ្អឹងតែ ហើយខ្មែរក្រហមបានបញ្ជូនតាមរថភ្លើងជាមួយប្រជាជន១៧មេសាទៅនៅសហករណ៍វត្តហ្លួងខេត្តពោធិ៍សាត់ដែលតម្រូវឲ្យខ្លួនធ្វើការនៅក្នុងក្រុមស្ទូង ហើយប្តីខ្លួនទៅនៅក្នុងក្រុមភ្ជួរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់បន្តថា មានពេលមួយខ្លួនបានទៅលួចបាយ នៅកន្លែងចុងភៅ ហើយក្រោយមកខ្លួនត្រូវបានអង្គការយកទៅធ្វើទារុណកម្មឲ្យបោកស្រូវមួយយប់មួយពាន់កណ្តាប់ និងរែកដីមួយយប់២០០អម្រែករហូតដល់សន្លប់ ប៉ុន្តែខ្មែរក្រហមបានយកទឹកមកជះឲ្យភ្ញាក់ ហើយក្រោយមកខ្លួននៅតែមិនអាចធ្វើការងារនោះបាន ។ ខ្មែរក្រហមបានយកទៅខ្លួនទៅសម្លាប់នៅទួលថ្ម ប៉ុន្តែនៅពេលនោះ ខ្លួនបានជួបជាមួយតាមាន ដែលបានប្រាប់ឲ្យខ្លួនរត់គេចពីការសម្លាប់នោះ ។ ដើមបណ្តឹងរដ្ឋប្បវេណី បានបន្តរៀបរាប់ថា ក្រោយមកទៀតខ្លួនបាន

ឃើញព្រឹត្តការណ៍សម្លាប់ដោយផ្ទាល់ភ្នែក គឺការសម្លាប់បុរសស្ត្រីមួយគូរឈ្មោះសំ និង នី ដែលខ្មែរក្រហមចោទថា ខុស សីលធម៌ ។ នៅពេលនោះ ខ្លួនបានឃើញអ្នកទាំងពីរត្រូវបានខ្មែរក្រហមចងសម្រាតខោអាវ និងវះពោះ បុរសឈ្មោះ សំ ហើយចំណែកនារី នី ត្រូវបានសម្លាប់ដោយអាករ ។ ចំណែកប្តីរបស់ខ្លួនវិញ ត្រូវបានគណៈតំបន់ឈ្មោះ ភួន បញ្ជាឲ្យចាប់យកទៅដាក់នៅក្នុងការដ្ឋានមីងសេក ដែលមានមនុស្សទាំងអស់៧៥នាក់ ។ បន្ទាប់មក ខ្មែរក្រហមបានបិទទ្វារ និងបាញ់ពីក្រៅការដ្ឋាន ។ អ្នកដែលស្លាប់នៅក្នុងព្រឹត្តិការណ៍នោះមានតែពីរនាក់ប៉ុណ្ណោះ ដោយសារអ្នកទោសនាំគ្នាធាក់ជញ្ជាំងរត់ចេញអស់ ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា ខ្លួនធ្លាប់ឮឈ្មោះមេដឹកនាំមួយចំនួនដូចជា អៀង សារី, តាម៉ុក, ខៀវ សំផន និង នួន ជា ជាដើម ។ ចំណែកអ្នកគ្រប់គ្រងនៅកន្លែងខ្លួនរស់ នៅក្នុងខេត្តពោធិ៍សាត់នោះមានដូចជា តាសេម យាយកប យាយយ៉ាន តាមាន និង តាភួន ។

## ១.ខ) ការសាកសួរដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត វែនន័រ បានសាកសួរឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ពីកន្លែងដែលខ្លួនទៅរស់នៅក្នុងខេត្តពោធិ៍សាត់ ហើយដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះខ្លួន បានទៅរស់នៅភូមិព្រៃគ្រប់ ហើយមុនពេលទៅនៅទីនោះខ្លួនបានទៅនៅលើភ្នំស្វក់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់បន្តទាក់ទងនឹងការកោះហៅអ្នក១៧មេសា ឲ្យទៅប្រជុំ ប៉ុន្តែពេលនោះឪពុកខ្លួនមិនបានទៅចូលរួមប្រជុំជាមួយទេ ដោយសារឪពុករបស់ខ្លួនបានដឹងអំពីស្ថានភាពស្រុកទេស ។ ទោះបីជាខ្មែរក្រហម បានប្រកាសប្រាប់ថា អ្នកដែលធ្វើប្រវត្តិរូបរួចនឹងត្រូវបញ្ជូនឲ្យទៅនៅភ្នំពេញវិញក៏ដោយ ខ្លួន និងគ្រួសារមិនបានប្រាប់ពីប្រវត្តិរូបពិតប្រាកដឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា បន្ទាប់ពីធ្វើប្រវត្តិរូបហើយ អ៊ំ និងបងប្អូនជីដូនមួយរបស់ខ្លួនបានត្រឡប់ទៅនៅភ្នំពេញវិញ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តដោយសាកសួរទាក់ទងនឹងទីតាំងសម្លាប់ដែលអ្នកបរទេះគោនោះបានដឹង ។ ជាការឆ្លើយតប ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា អ្នកបរទេះគោនោះមិនបានប្រាប់ខ្លួនពីទីតាំងសម្លាប់មនុស្សនោះទេ ហើយក្រោយមក ខ្លួនក៏មិនដែលបានជួបអ្នកបរទេះនោះទៀតដែរ ។

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងប្រជាជនដែលចុះមកពីលើភ្នំមករកអាហារ ហើយដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលដែលប្រជាជនចុះមករកអាហារ គឺសុទ្ធតែមានឈ្លបនៅយាម ហើយប្រសិនបើអ្នកទាំងនោះលួចរត់ចេញពីលើភ្នំ ឈ្លបនឹងបាញ់សម្លាប់ជាមិនខាន ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងរយៈពេលដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេយកទៅសម្លាប់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ព្រឹត្តិការណ៍នោះបានកើតឡើងពេលខ្លួនទៅដល់ពោធិ៍សាត់ប្រហែលមួយឆ្នាំ ។

## ១.គ) ការសាកសួរដោយមេធាវីការពារក្តី

### ១.គ.១) មេធាវីការពារក្តី នួន ជា

មេធាវីជាតិ សុន អរុណ បានចាប់ផ្តើមការសួរដេញដោលទាក់ទងនឹងការសិក្សារបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្លួនបានរៀនចប់ថ្នាក់ទី១ពីសង្គមនៅឆ្នាំ១៩៧៥ ។ ឪពុករបស់ខ្លួនគឺជាគិញនៅក្នុងអគ្គភាពមួយនៅជិតទាន់ លន់ នល់ ហើយនៅមុនឆ្នាំ១៩៧៥ ខ្លួនបានសម្គាល់ឃើញថា នៅភ្នំពេញមានប្រជាជនរស់នៅច្រើនជាធម្មតា ។ នៅពេលនោះ ខ្លួនក៏មិនដែលបានតាមដានពត៌មានទាក់ទងនឹងស្ថានការណ៍ប្រទេសជាតិ ។ បន្ទាប់មក មេធាវីបានលើកយកសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលធ្វើឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការសម្លាប់ នៅពេលជម្លៀស ។ ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅពេលជម្លៀស យោធាខ្មែរក្រហមបានបាញ់សម្លាប់ប្រជាជនណាដែលរឹងទទឹងមិនព្រមជម្លៀសចេញពីទីក្រុង ។ បន្ទាប់មក មេធាវីបានសាកសួរទាក់ទងនឹងសកម្មភាពដែលឈ្លបបានសម្លាប់ នី និង សំ ដែលត្រូវបានខ្មែរក្រហមចោទថាខុសសីលធម៌ដើម្បីឲ្យសាក្សីបញ្ជាក់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះ ចុងភៅបានឲ្យខ្លួនទៅបេះស្លឹកថ្នឹង ដែលពេលនោះស្រាប់តែខ្លួនបានឮសម្លេងមនុស្សស្រែក ហើយខ្លួនបានទៅលបមើលក៏ឃើញឈ្លបកំពុងតែវះពោះបុរសឈ្មោះ សំ

និងយកកាំបិតទៅសង្កត់លើករនារី នី ។

## ១.គ.២) មេធាវីការពារក្តី អៀង សារី

មេធាវីជាតិ អាង ឧត្តម បានសួរបញ្ជាក់លើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបញ្ជាក់ថា ពេលធ្វើដំណើរតាមរថភ្លើងទៅខេត្តពោធិ៍សាត់នោះ មានប្រជាជនម្នាក់បានបន្ទោរបង់នៅក្នុងទូររថភ្លើង ដោយមិនសុំការអនុញ្ញាតពីឈ្លប ថាតើបុគ្គលនោះត្រូវបានខ្មែរក្រហមសម្លាប់ដែរឬទេ? ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថាព្រឹត្តិការណ៍នោះខ្លួនបានឃើញផ្ទាល់ភ្នែកនៅក្នុងទូររថភ្លើងដែលខ្លួនជិះ ហើយបុគ្គលនោះ ត្រូវបានខ្មែរក្រហមបាញ់សម្លាប់នៅក្នុងទូររថភ្លើងនោះតែម្តង ។

## ១.ឃ) ការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី

ដោយសារមេធាវីជនជាប់ចោទ ខៀវ សំផន មិនមានសំណួរសាកសួរដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រម និល ណុន បានផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការថ្លែងទុក្ខសោករបស់ខ្លួនដូចខាងក្រោម ៖

*"ចាស៎ នាងខ្ញុំសូមគោរពលោកប្រធានតុលាការជាទីគោរព! សូមគោរពលោក លោកស្រីចៅក្រម នៃអង្គអង្គជំនុំជម្រះជាទីគោរព! សូមគោរពអង្គសវនាការទាំងមូលជាទីគោរពចាស៎! នាងខ្ញុំសូមអនុញ្ញាត បង្ហាញអំពីការឈឺចាប់ ព្យសនកម្មដែលនាងខ្ញុំបានទទួលក្នុងរបបពន្លាំ ៨ខែ ២០ថ្ងៃ កន្លងមកនេះចាស៎ ។ ណាងខ្ញុំថ្ងៃនេះក៏មានសំណាងដែរ ដែលបានយកទុកសោកទាំងនោះយកមកបង្ហាញនៅចំពោះមុខ អ.វ.ត.ក ចាស៎ ។ នាងខ្ញុំសូមជម្រាបអស់លោក លោកស្រីឲ្យបានជ្រាបថា ក្នុងរបបពន្លាំ ៨ខែ នៅពេលដែលនាងខ្ញុំត្រឡប់មកវិញ គឺគ្មានសេសសល់អ្វីទេក្រៅពីការឈឺចាប់ចាស!ភាពភ័យខ្លាច ភាពបាក់ស្បាត ការបាត់បង់នូវស្មារតីសតិបញ្ញា ដែលជះឥទ្ធិពលមកលើនាងខ្ញុំរហូតមកដល់ឥឡូវនេះ នៅតែចងចាំមិនភ្លេចទេនូវឧក្រិដ្ឋកម្មនានាដែលបានបង្កវិនាសកម្មដល់គ្រួសារនាងខ្ញុំ ដល់រូបនាងខ្ញុំ ដល់បងប្អូនរួមជាតិខ្មែរទាំងអស់ដែលជាជនរងគ្រោះចាស ។*

*នាងខ្ញុំសូមជម្រាបថា នៅក្នុងសម័យនោះប្អូនប្រុសរបស់នាងខ្ញុំដែលទើបតែអាយុ១៨ឆ្នាំ ដោយសារតែភាពអត់ឃ្លានបានទៅលួចល្ពៅគេមកហូបមួយ ត្រូវបានទិសគេដាក់មកថាកម្មេចគឺយកទៅសម្លាប់ចោលតែម្តងចាស ។ តើឈឺចាប់កម្រិតណា? ចំណុចមួយទៀត ឪពុក ប្អូនស្រី ប្អូនប្រុស មិនបានសម្លាប់មែនក៏ប៉ុន្តែស្លាប់ដោយសារធ្វើការងារធ្ងន់ អត់ចំណីអាហារ អត់ថ្នាំចាស ។ ចំណុចដែលគួរឲ្យនាងខ្ញុំចងចាំមិនអាចភ្លេចបាននោះគឺនារី១៩នាក់ដែលរស់នៅក្នុងសហករណ៍ព្រហស្បតិ៍ក្បាល ត្រូវបានគណៈតំបន់ ឈ្មោះ ភួន គាត់ចាប់រំលោភមួយយប់មួយៗដាក់វេនគ្នា ព្រោះនារីទាំងអស់នោះជាកងពិសេស ហើយរំលោភទាំងអស់គ្រប់១៩ ដល់ចូលវេនមកដល់នារីទី២០ គឺជាមិត្តសម្លាញ់របស់ខ្ញុំ អត់ធ្វើអីនាងកើតចាស៎ ម៉ោង១២យប់នាងត្រឡប់មកវិញនាងរ៉ាយរ៉ាប់សាច់រឿងទាំងអស់នោះប្រាប់ខ្ញុំ ។ តើក្នុងនាមជាស្ត្រីជនរងគ្រោះដែលត្រូវគណៈតំបន់រំលោភ តើឈឺចាប់ប៉ុណ្ណា? បើគិតមកដល់ពេលឥឡូវនេះ បើគិតមកដល់ច្បាប់យើងឥឡូវនេះវិញ តើគេកាត់ទោសយ៉ាងម៉េច? រំលោភតែមួយក៏គ្រប់ដែរ មិនចាំបាច់ដល់២០ទេចាស៎ ។ អាហ្នឹងគឺជាការឈឺចាប់ គឺផ្ទះបញ្ចាំងឲ្យខ្ញុំឃើញឥទ្ធិពលទាំងអស់នោះ ដែលធ្វើឲ្យខ្ញុំឈឺចាប់មិនអាចបំភ្លេចបាន ។*

*ហើយក្នុងនេះដែរ ក៏នាងខ្ញុំសូមជម្រាបអស់លោក លោកស្រីថា ការឈឺចាប់ទាំងអស់នោះ វាមិនអាចសុខទៅបានធ្វើយ៉ាងម៉េចក៏មិនអាចភ្លេចបានដែរ ក៏ប៉ុន្តែមានសំណូមពរចាស មានសំណូមពរថា សុំឲ្យ អ.វ.ត.ក ហ្នឹងមេត្តាផ្តល់ជាសំណង ។ សំណងសមូហភាព ខាងខ្ញុំទទួលហើយក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីតែសូមឲ្យចេញជារូបរាង តើជាស្តូប ឬជាមន្ទីរសុខភាពផ្លូវចិត្តដើម្បីឲ្យពួកយើងខ្ញុំទាំងអស់គ្នា ដែលជាជនរងគ្រោះ ទាំងប្រជាជនខ្មែរ ទាំងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងបានទៅធ្វើពិធីគោរពបូជាទៅតាមបុណ្យប្រពៃណីជាតិដូចជា ភ្ជុំបិណ្ឌ ឬក៏ចូលឆ្នាំ ចាស៎ ហើយដើម្បីឲ្យយើងទាំងអស់គ្នានេះបានស្ងប់អារម្មណ៍ធូរស្រាលនៅក្នុងចិត្ត ។*

*ហើយចំណុចសំខាន់មួយទៀតនោះ នាងខ្ញុំដឹងថា អ្នកណាដែលប្រព្រឹត្តត្រូវតែទទួលទោស ។ ដូច្នេះ សូមឲ្យលោកប្រធានលោកជួយរកយុត្តិធម៌ឲ្យជនរងគ្រោះទាំងអស់ មិនចាំបាច់នាងខ្ញុំទេបើរកឲ្យជនរងគ្រោះទាំងអស់ នាងខ្ញុំក៏ស្ថិតនៅក្នុងចំណោមនៃជនរងគ្រោះទាំងអស់នោះដែរ ។ សូមឲ្យលោកទាំងអស់ដែលបាន*

ប្រព្រឹត្តនៅក្នុងរបបគេហៅថា របបមនុស្សឃាតនោះ របប៣ឆ្នាំ ៨ខែ របបកម្ពុជាប្រជាធិបតេយ្យនោះចាស ដែលពួកគាត់មានផែនការចាសបន្តវិនាសកម្មឲ្យប្រជាពលរដ្ឋស្លាប់យ៉ាងវេទនាល ហើយក៏សូមឲ្យលោកប្រធានតុលាការ លោកផ្តន្ទាទោសឲ្យបាន តឹងរ៉ឹងជាទីបំផុត ហើយដឹងថាអ្នកធ្វើខុសគឺត្រូវតែមានទោស ។ ចាស! នាងខ្ញុំសូមអរគុណ ។

## ២) ប្រវត្តិសាវតាររបស់ដើមបណ្តឹងរដ្ឋប្បវេណី គីម វ៉ាន់ឌី

ជាដំបូង ចៅក្រម និល ណុន បានសួរសំណួរមួយចំនួន ទាក់ទងនឹងប្រវត្តិរូបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ខ្លួនមានឈ្មោះ គីម វ៉ាន់ឌី កើតនៅ



ដើមបណ្តឹងរដ្ឋប្បវេណី គីម វ៉ាន់ឌី
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៦២ នៅស្រុកអង្គរជ័យ ខេត្តកំពត ។ សព្វថ្ងៃខ្លួនរស់នៅឃុំព្រែកទ្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងមានមុខរបរស៊ីឈ្នួលនៅក្រុមហ៊ុន ។ ឪពុកឈ្មោះ កែម អ៊ែល ម្តាយឈ្មោះ អ៊ឹ យឿន និងប្រពន្ធ ឈ្មោះ ឈួន ស្រីមុំ ។ លោកមានកូន៦នាក់ ។ បន្ទាប់មក លោកប្រធានបានបញ្ជាក់អំពីសិទ្ធិ និងករណីកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមសវនាការ និងសិទ្ធិក្នុងការសម្តែងនូវទុក្ខសោករបស់ខ្លួនដែលបាន បាត់បង់សាច់ញាតិ និងទ្រព្យសម្បត្តិនៅក្នុងរបបខ្មែរក្រហម ។

## ២.ក) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសាកសួររបស់ចៅក្រម និល ណុន សហមេធាវីនាំមុខជាតិតំណាងដើមបណ្តឹង រដ្ឋប្បវេណី ពេជ្រ អង្គ បាន ជម្រាបអង្គជំនុំជម្រះក្នុងការប្រគល់សិទ្ធិជូនមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទី ស្រ៊ីណា ក្នុងការសួរដេញដោល ។

### ២.ក.១) ស្ថានភាពមុនពេលជម្លៀស

មេធាវីជាតិ ទី ស្រ៊ីណា បានចាប់ផ្តើមសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងទីលំនៅរបស់សាក្សីនៅក្នុងរបប លន់ នល់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅក្នុងរបប លន់ នល់ ខ្លួនរស់នៅភូមិជ្រោយចង្វារ ស្រុកមុខកំពូល ខេត្តកណ្តាល ។ នៅពេលនោះមានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងទ័ពខ្មែរក្រហមដែលបណ្តាលឲ្យមានគ្រោះថ្នាក់ដល់អ្នកដែលរស់នៅជិតនោះដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តរៀបរាប់ថា តំបន់ដែលខ្លួនរស់នៅគឺមានតែទាហាន លន់ នល់ តែប៉ុណ្ណោះ ហើយ ដោយសារតែស្ថានភាពរស់នៅទីនោះកាន់តែលំបាកខ្លួនបានមករស់នៅផ្ទះឪពុកមារដែលជាទាហានសក្តិ៥ នៅទីក្រុងភ្នំពេញ ។ នៅទីនោះបានតែប៉ុន្មានថ្ងៃក្រោយមកយោធាខ្មែរក្រហមបានចូលមកដល់ ។

### ២.ក.២) ទិដ្ឋភាពពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការជម្លៀសក្រោយមក ទៀត

ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ពេលខ្មែរក្រហមចូលមកដល់ផ្ទះឪពុកមារ ខ្លួននឹកស្មានថា ឪពុកមារបើកឡានមកដល់ផ្ទះវិញ ប៉ុន្តែភ្លាមនោះ ខ្លួនបានឮស្នូរកាំភ្លើង ហើយពេលខ្លួនចេញមកមើលនៅខាងក្រៅស្រាប់តែឃើញឪពុកមារស្លាប់ក្នុងសំលៀកបំពាក់ប៉ារ៉ា ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា អ្នកដែលបាញ់នោះ គឺជាយោធាខ្មែរក្រហមដោយសារខ្លួនបាន ឃើញយោធាម្នាក់ដើរចេញក្រៅជួរពេលកំពុងធ្វើដំណើរនៅក្នុងទីក្រុង ហើយខ្លួនបានឮយោធាម្នាក់នោះនិយាយថា "ហ្នឹងហើយពួកក្បត់" ។ ក្រោយមក មានយោធាខ្មែរក្រហមពីរនាក់ស្លៀកសម្លៀកបំពាក់ខ្មៅបានជិះម៉ូតូប្រកាសឲ្យប្រជាជនចាកចេញពីទី ក្រុងភ្នំពេញក្នុងរយៈពេលបីថ្ងៃ ហើយបន្ទាប់មកមានទាហានមួយក្រុមទៀតបានប្រាប់ឲ្យប្រជាជនឆាប់ចេញឲ្យលឿន ក្រែងយន្តហោះទម្លាក់គ្រាប់បែក ។ នៅពេលនោះ ខ្លួន និងក្រុមគ្រួសាររបស់ឪពុកមារបានធ្វើដំណើរចេញមកតាមផ្លូវជាតិលេខ ៦ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តរៀបរាប់អំពីទិដ្ឋភាពក្នុងពេល

ជម្លៀស ដោយបញ្ជាក់ថា ខ្លួនបានឃើញមនុស្សច្រើនកកកុញ ហើយពិបាកក្នុងការធ្វើដំណើរ ។ មានអ្នកជំងឺជាច្រើនយួរទាំងសឺរ៉ូមជាប់នឹងដៃ ប៉ុន្តែខ្លួនមិនហ៊ានមើលយូរទេ ធ្វើយ៉ាងម៉េចឲ្យតែដើរទៅបានលឿន ។ នៅពេលនោះមានយោធាឈរនៅតាមដងផ្លូវស្លៀកឯកសណ្ឋានខ្មៅ និងកាន់កាំភ្លើងគ្រប់ដៃ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តរៀបរាប់ថា នៅពេលជម្លៀសនោះខ្លួនបានឃើញយោធាបាញ់សម្លាប់បុរសម្នាក់ដោយសារតែបុរសនោះបានសុំអនុញ្ញាតដើរបកក្រោយទៅរកកូនប៉ុន្តែត្រូវបានខ្មែរក្រហមបាញ់សម្លាប់តែម្តង ។

បន្ទាប់មក មេធាវីបានបន្តសួរទាក់ទងនឹងការធ្វើដំណើររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ជាការឆ្លើយតប ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ពេលនោះខ្លួនបានធ្វើដំណើរតាមផ្លូវជាតិលេខ៦ និងស្នាក់នៅក្រោមដើមឈើនៅកំពង់ចម្លងរហូតដល់ព្រឹកឡើងទើបឆ្លងស្ពានទៅត្រើយម្ខាងទៀតនៅភូមិទួល ។

ពេលទៅដល់ទីនោះ ខ្លួន និងគ្រួសារបានសុំអ្នកមូលដ្ឋានដើម្បីនៅជាមួយ ប៉ុន្តែអ្នកនៅទីនោះមិនឲ្យស្នាក់នៅទេ ដោយសារតែគ្រួសារខ្លួនជាប្រជាជន១៧មេសា ។ ក្រោយមកខ្លួន និងក្រុមគ្រួសារត្រូវបានបញ្ជូនឲ្យទៅនៅខេត្តកំពតជាស្រុកកំណើតរបស់ឪពុកម្តាយខ្លួនវិញ ។ នៅទីនោះ ប្រជាជនត្រូវបានបែងចែកឲ្យនៅផ្សេងគ្នា ដូចជាប្រជាជន១៧មេសាត្រូវរស់នៅភូមិផ្សេង និងប្រជាជន១៨ដែលជាអ្នកមូលដ្ឋានត្រូវរស់នៅភូមិផ្សេង ។ នៅពេលនោះ ប្រជាជន១៨មិនរាក់ទាក់ជាមួយប្រជាជន១៧មេសាទេ ។ ប្រជាជន១៧ មេសា គឺត្រូវបានគ្រប់គ្រងដោយប្រធានភូមិឈ្មោះ នៅ ។ នៅទីនោះ ឪពុកម្តាយខ្លួនត្រូវបានបែងចែកឲ្យទៅកាប់ដីធ្វើស្រែនៅស្រុកប៉ាឡេឡៃ ដោយម្នាក់ៗត្រូវកាប់ដីទំហំ១០ម៉ែត្របួនជ្រុង ហើយទទួលបានអង្ករមួយកំប៉ុង ឬពីរកំប៉ុងទៅតាមចំនួនសមាជិកគ្រួសារ ។ ដោយសារឪពុកម្តាយខ្លួនមិនអាចកាប់ដីបាន ប្រធានភូមិបានបែងចែកជាគ្រួសារវិញដោយមួយគ្រួសារត្រូវកាប់១២ម៉ែត្របួនជ្រុង និងទទួលបានអង្ករ ពីរកំប៉ុង ។ ទាក់ទងនឹងការចាប់ឪពុករបស់ខ្លួនវិញ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា មានថ្ងៃមួយ ក្រោយពេលហូបបាយល្ងាចឈ្លបខ្មែរក្រហមបានប្រាប់ថា ថ្ងៃស្អែកខ្មែរក្រហមនឹងចុះឆែកឆេរតាមផ្ទះ ហើយនៅពេលនោះ ខ្មែរក្រហមបានឆែកឃើញរូបថតឪពុកខ្លួនតឺនុយឯកសណ្ឋានជើងទឹក ឈរថតនៅលើកប៉ាល់ ។ នៅថ្ងៃបន្ទាប់ ឪពុករបស់ខ្លួនត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅភូមិឡាំដាំ នៅខេត្តកោះកុង ។ ដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់ថា ក្រោយមកពួកឈ្លបបានមកសួរចម្លើយខ្លួនអំពីប្រវត្តិគ្រួសារ ហើយខ្លួនបានប្រាប់ឈ្លបទាំងនោះថា ឪពុករបស់ខ្លួនមានមុខរបរជាអ្នកធាក់ស៊ីក្លូ ប៉ុន្តែឈ្លបទាំងនោះបាននិយាយថា ខ្លួននិយាយកុហក និងបានចាប់ខ្លួនយកទៅដាក់ច្រវ៉ាក់ជើងព្រមទាំងវាយធ្វើទារុណកម្មអស់រយៈពេលមួយសប្តាហ៍ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា ថ្ងៃមួយមានឈ្លបពីរនាក់កាន់កាំភ្លើងគ្រប់ដៃបានមកចាប់ឪពុកខ្លួនយកទៅសម្លាប់ ហើយម្តាយរបស់ខ្លួនត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅទំនប់ព្រែកផ្តៅទាំងសរសៃខ្ចី ។ បីខែក្រោយមក ប្អូនរបស់ខ្លួនដែលទើបនឹងកើតនោះក៏បានស្លាប់បាត់ទៅ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបនឹងសំណួរបន្ទាប់របស់មេធាវីទាក់ទងនឹងការស្លាប់របស់ប្រជាជននៅកន្លែងដែលខ្លួនរស់នៅថា នៅទីនោះមានប្រជាជនស្លាប់ច្រើនដោយសារជំងឺ ហើយអ្នកខ្លះទៀតត្រូវបានសម្លាប់ដោយសារលួចស្រូវរបស់អង្គការ ។

បន្ទាប់មក មេធាវីជាតិ ទី ស៊្រីណា បានបន្តសំណួរថា តើដើមបណ្តឹងរដ្ឋប្បវេណីបានឃើញមេដឹកនាំខ្មែរដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា មានថ្ងៃមួយ មានការបញ្ចាំងកុនដែលមានការចូលរួមពីប្រជាជនទាំងអស់ ប៉ុន្តែដោយសារមនុស្សច្រើនកុះករពេកខ្លួនមិនបានឃើញ និងស្តាប់ឮច្បាស់ថា កុននោះនិយាយពីរឿងអ្វីឡើយគ្រាន់តែខ្លួនបានឮថា«យើងទទួលបានជ័យជម្នះហើយ!» ។ បន្ទាប់មក មេធាវីបានបន្តសំណួរថា តើប្រជាជន១៧មេសាដែលភាគច្រើនប្តីត្រូវបានគេ សម្លាប់នោះត្រូវបញ្ជូនទៅនៅខេត្តពោធិ៍សាត់មែនដែរឬទេ? ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅពេលនោះ មានប្រជាជន១៧មេសាខ្លះ និងប្រជាជន១៨ខ្លះ ប៉ុន្តែប្រជាជន១៧មេសាត្រូវធ្វើដំណើរដោយថ្មើរជើង ចំណែកឯប្រជាជន១៨គឺធ្វើដំណើរដោយជិះរថយន្ត ។

## ២.១) ការសាកសួរដោយតំណាងសហព្រះរាជអាជ្ញា

បន្ទាប់ពីបញ្ចប់ការសាកសួររបស់មេធាវីតំណាងដើមបណ្តឹង

រដ្ឋប្បវេណី ចៅក្រម និល ណុន បានផ្ទេរវេទិកាជូនតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការសាកសួរ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ថារីក បានចាប់ផ្តើមសាកសួរដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបញ្ជាក់ឡើងវិញទាក់ទងនឹងការធ្វើដំណើររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើដំណើរមកពីស្រុកកំណើតនៅស្រុកមុខកំពូលទៅនៅផ្ទះឪពុកមាររបស់ខ្លួននៅសន្ធរម៉ុក ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរទាក់ទងនឹងតួនាទី និងស្ថានភាពរបស់ឪពុកមារដើមបណ្តឹងរដ្ឋប្បវេណីនៅពេលយោធាខ្មែរក្រហមចូលមកដល់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ឪពុកមាររបស់ខ្លួនឈ្មោះ កែម អ៊ែល មានតួនាទីជាទាហានជើងទឹកសក្តិប្រាំ ប៉ុន្តែខ្លួនមិនដឹងថា ឪពុកមារបានទៅច្បាំងនៅទីណាទេ ។ ចំណែកការចាប់ឪពុករបស់ខ្លួនវិញ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ពេលចាប់ទៅដំបូង ខ្លួនបានសួរប្រធានភូមិថា តើចាប់ឪពុកខ្លួនយកទៅណា? ហើយប្រធានភូមិបានបញ្ជាក់ថា ចាប់យកទៅវត្តទួងស្គរនៅក្នុងស្រុកឈូក ។ ពេលនោះខ្លួនគិតថា បើចាប់ទៅវត្តនោះពិតជាមិនមានអ្វីកើតឡើងចំពោះឪពុកខ្លួនទេ ។ ប៉ុន្តែក្រោយមក ខ្លួនបានទៅបេះផ្លែ ក្រឡាញ់ ក៏បានឃើញខោអាវ និងមួករបស់ឪពុកខ្លួនត្រូវបានចងជាប់នឹងដើមដូង ។ ជាចុងក្រោយ តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងការសម្លាប់អ៊ំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅខែខសកាឆ្នាំ១៩៧៥ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា អ៊ំរបស់ខ្លួនឈ្មោះ ហង់ ជាមេឃុំនៅជំនាន់ លន់ នល់ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅខេត្តកំពត ហើយខ្លួនបានដឹងរឿងនេះច្បាស់ដោយសារតែខ្លួនបានសួរទាហានរណសិរ្សម្នាក់ឈ្មោះ ណូ ។ ម្យ៉ាងទៀត ម្តាយរបស់ខ្លួនក៏បានទៅស្រាវជ្រាវរកផ្ទះជីដូន និងឪពុកមារ ប៉ុន្តែជាលទ្ធផល ម្តាយខ្លួនរកមិនឃើញបងប្អូននៅទីនោះឡើយ ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីដោយតំណាងសហព្រះរាជអាជ្ញារួចមក អង្គជំនុំជម្រះបានផ្ទេរវេទិការសាកសួរជូនមេធាវីការពារក្តីទាំងបីក្រុម ប៉ុន្តែមិនមានមេធាវីក្រុមណាមួយ មានសំណួរដើម្បីសាកសួរដើមបណ្តឹងរដ្ឋប្បវេណីទេ ដូច្នេះអង្គជំនុំជម្រះបានផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីថ្លែងអំពីទុក្ខសោករបស់ខ្លួនចំពោះការបាត់បង់ទាំងឡាយនៅក្នុងរបបខ្មែរក្រហម ។

## ២.ត) ការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី

សូមថ្លែងអំណរគុណចំពោះលោកប្រធាន ដែលបានផ្តល់ឱកាសឲ្យខ្ញុំ និងថ្លែងទុក្ខវេទនាដែលខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំបានទទួល ។ ក្នុងរបបខ្មែរក្រហម តទៅនេះ ខ្ញុំសូមរៀបរាប់ជូនលោកប្រធាន លោក លោកស្រីចៅក្រម អំពីទុក្ខវេទនា ដែលរូបខ្ញុំ និងក្រុមគ្រួសារខ្ញុំបានទទួលរងទុក្ខ រងទោសនៅក្នុងរបបខ្មែរក្រហម សូមលើអំពីទុក្ខវេទនាផ្លូវកាយ ។ រូបខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំត្រូវចាកឆ្ងាយពីផ្ទះសម្បែង ដីធ្លី ទ្រព្យរបស់ និងចំណេះដឹងរបស់ខ្ញុំក៏ដូចជាប្រជាជនដទៃទៀតដែរ ។ ដោយសារតែខ្មែរក្រហមនេះហើយបានធ្វើឲ្យបានធ្វើទារុណកម្មលើរូបខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំចាកឆ្ងាយពីផ្ទះសម្បែង ។ បង្ខំឲ្យរូបខ្ញុំ ក្រុមគ្រួសារខ្ញុំធ្វើការធ្ងន់ធ្ងរហួសកម្លាំង បង្អត់អាហារ មិនឲ្យហូបឆ្អែត ក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ ។ ធ្វើឲ្យបងប្អូនស្រីរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំជាច្រើននាក់ស្លាប់ដោយសារតែបង្អត់អាហារយ៉ាងវេទនា ។ ពួកគេបានសម្លាប់ឪពុក បងប្រុស ឪពុកមា ម្តាយមីង ព្រមទាំងសាច់ញាតិជាច្រើនទៀត ដោយអយុត្តិធម៌គួរឲ្យអាសូរជាទីបំផុត ។ សព្វថ្ងៃនេះ ធ្វើឲ្យម្តាយរបស់ខ្ញុំក្លាយជាស្ត្រីមេម៉ាយ រីឯរូបខ្ញុំក្លាយជាកូនកំព្រារហូតមកដល់សព្វថ្ងៃនេះ ។ ពេលខ្ញុំគិត ពេលខ្ញុំអង្គុយគិតម្តងៗ រឿងហ្នឹងវាហាក់បីដូចជានៅថ្មីៗ ធ្វើឲ្យអារម្មណ៍របស់ខ្ញុំពុះកញ្ជ្រោល ខ្ញុំចូលបម្រើជួរកងទ័ពដើម្បីសងសឹកតែលទ្ធផលវាមិនបាន វាមិនអាចធ្វើទៅបាន ។ ធ្វើឲ្យខ្ញុំត្រូវនិរទេសខ្លួនដើម្បីលក់កម្លាំងពលកម្មបានប្រាក់បន្តិចបន្តួចទុកសម្រាប់ចិញ្ចឹមជីវិតរហូតដល់សព្វថ្ងៃ ទម្រាំថ្ងៃអស្តង្គតរបស់ខ្ញុំ ។ សូមលោកប្រធាន លោក លោកស្រីចៅក្រមមេត្តាជួយរកភាពយុត្តិធម៌ ដាក់ទោសទណ្ឌឲ្យសមនឹងអ្វីដែលរូបខ្ញុំបានបាត់បង់សាច់ញាតិ ក៏ដូចជាអ្នកដទៃ ដែលមានរឿងដូចខ្ញុំឲ្យបានស័ក្តិសមដែលលោកប្រធាន លោក លោកស្រីចៅក្រមធ្វើទៅបាន ។

ជាចុងបញ្ចប់ សូមថ្លែងអំណរគុណដល់លោកប្រធាន លោក លោកស្រីចៅក្រម ពុកម៉ែ បងប្អូនដែលមានវត្តមាននៅទីនេះឲ្យជួបតែសេចក្តីសុខគ្រប់ពេលវេលា ។ សូមអរគុណ សូមអរព្រះគុណ ។



ខៀវ សំផន (រូបស្តាំបង្អស់) កំពុងអមដំណើរប្រធានាធិបតីនៃប្រទេសភូមា នេ វីន (រូបឆ្វេងបង្អស់) ធ្វើទស្សនកិច្ចជុំវិញទីក្រុងភ្នំពេញនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ ជួន ប្រសិទ្ធ (រូបទី២បន្ទាប់ពី នេ វីន) គឺជាកម្មាភិបាលនៅក្រសួងការបរទេស និងជាអ្នកបកប្រែភាសាពីអង់គ្លេសមកខ្មែរ ។

(ប្រភពរូប ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនការស្តាប់សក្ខីកម្មសាក្សី ហ៊ុន ឈុនលី

## ថ្ងៃទី៦-៧ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២

នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកោះអញ្ជើញសាក្សីមួយរូបទៀត ដែលមានឈ្មោះ ហ៊ុន ឈុនលី ដើម្បីស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុស្តីពីការជម្លៀសប្រជាជននៅតំណាក់កាលទី១ និងដំណាក់កាលទី២ និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាននៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សី ហ៊ុន ឈុនលី គឺជាអតីតគ្រូពេទ្យមួយរូបប្រចាំនៅមន្ទីរពេទ្យយោធាខេត្តបាត់ដំបង ដែលធ្លាប់បានបម្រើការនៅក្នុងរដ្ឋការ លន់ នល់ និងបន្ទាប់មកក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ត្រូវបានខ្មែរក្រហមហៅឲ្យជួយកិច្ចការខាងវេជ្ជសាស្ត្ររយៈពេលជិត១ឆ្នាំ មុនពេលខ្មែរក្រហមផ្លាស់ឲ្យទៅធ្វើស្រែចម្ការដូចប្រជាជនផ្សេងទៀត ។ សាក្សី ឈុនលី ធ្លាប់បានសរសេរសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតគ្រូពេទ្យម្នាក់នៅសម័យខ្មែរក្រហម" ដែលបានរៀប រាប់លម្អិតអំពីបទពិសោធន៍ និងជីវិតផ្ទាល់ខ្លួននៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ សៀវភៅនេះគឺជាភស្តុតាងដែលត្រូវបានអង្គជំនុំជម្រះដាក់ចូលទៅក្នុងសំណុំរឿង០០២ ហើយដែលត្រូវបានភាគីយកមកសួរដេញដោលសាក្សីនៅក្នុងសវនាការ ។ សាក្សីរូបនេះ គឺជាបុគ្គលទី២ ដែលមានតួនាទីជាគ្រូពេទ្យ បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ដែលបានចូលមកផ្តល់សក្ខីកម្មក្នុងសវនាការនៅចំពោះមុខអង្គជំនុំជម្រះ ។

ដូចជាសាក្សីមុនៗដែរ ការសួរដេញដោលសាក្សី ហ៊ុន ឈុនលី ចាប់ផ្តើមដោយសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងបន្ទាប់មកមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។

ការផ្តល់សក្ខីកម្មរបស់សាក្សី ហ៊ុនឈុនលី បានចំណាយពេល៣ថ្ងៃ គឺនៅថ្ងៃទី៦-៧ និងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ ដោយមានការចូលរួមពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី ប្រជាជន សិស្សនិស្សិត និងអ្នកសង្កេតការណ៍អំពីកិច្ចដំណើរការនីតិវិធី ប្រមាណ ៨០០នាក់ មកពីរាជធានីភ្នំពេញ ខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តកំពង់ចាម ។

### ១) ប្រវត្តិសាវតាររបស់សាក្សី ហ៊ុន ឈុនលី

នៅមុនពេលប្រគល់វេទិកាជូនភាគីដើម្បីសាកសួរដេញដោលប្រធានអង្គជំនុំជម្រះ គឺចៅក្រម និល ណុន បានសាកសួរអំពីប្រវត្តិសាវតាររបស់សាក្សី ហ៊ុន ឈុនលី ។ ឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះសាក្សី ហ៊ុន ឈុនលី បានរៀបរាប់ថា សព្វថ្ងៃលោកមានអាយុ៧៨ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ សព្វថ្ងៃមានទីលំនៅសង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ និងមានតួនាទីជាគ្រូពេទ្យ ប៉ុន្តែចូលនិវត្តន៍តាំងពីឆ្នាំ២០០៤ ។ សាក្សីមានឪពុកឈ្មោះ ហ៊ុន គៀន និងម្តាយ សាយ យុន និងភរិយា ជាមួយនឹងកូនពីរនាក់ ។



សាក្សី ហ៊ុន ឈុនលី (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គជំនុំជម្រះបានជម្រាបអំពីសិទ្ធិ និងករណីកិច្ចដែលសាក្សីត្រូវមាននៅអំឡុងពេលនៃសវនាការ ។ ខុសប្លែកពីសាក្សីមុនៗ

សាក្សី ឈុនលី មិនធ្លាប់បានធ្វើកិច្ចសម្ភាសន៍ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ។

## ២) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

### ក) តំណាងសហព្រះរាជអាជ្ញាជាតិ វើង ហ៊ត់

មុនពេលចាប់ផ្តើម តំណាងសហព្រះរាជអាជ្ញាជាតិ វើង ហ៊ត់ បានស្នើសុំអង្គជំនុំជម្រះ ដាក់ជូនសៀវភៅមួយក្បាលនិពន្ធដោយ ហ៊ិន ឈុនលី ដែលមានចំណងជើងថា "ជីវិតគ្រូពេទ្យម្នាក់នៅសម័យខ្មែរក្រហម"ជូនអង្គជំនុំជម្រះ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា បានចាប់ផ្តើមសួរសំណួរដំបូងទាក់ទងនឹងការបោះពុម្ព និងការនិពន្ធសៀវភៅរបស់សាក្សី ។ ហ៊ិន ឈុនលី បានបញ្ជាក់ថា សៀវភៅ "ជីវិតគ្រូពេទ្យម្នាក់នៅសម័យខ្មែរក្រហម" ត្រូវបានបោះពុម្ពចំនួនពីរលើក ដោយមានអត្ថាធិប្បាយអំពីបទពិសោធន៍ដែលខ្លួនបានជួបប្រទះដោយផ្ទាល់នៅក្នុងជីវិតក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបន្ថែមថា ការនិពន្ធសៀវភៅនេះ គឺពឹងផ្អែកលើការរំឭកឡើងវិញទាំងស្រុងអំពីព្រឹត្តិការណ៍សំខាន់ៗ ដែលខ្លួនបានជួបប្រទះ ដោយសារតែសៀវភៅកំណត់ត្រាដែលខ្លួនបានកត់ត្រាទុកនៅក្នុងសម័យនោះ ត្រូវបានដុតបំផ្លាញចោលទៅហើយ ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងតួនាទីនៅមុនពេលនៃរបបខ្មែរក្រហម សាក្សីអះអាងថា ខ្លួនធ្លាប់បានបម្រើការនៅមន្ទីរពេទ្យយោធានៅខេត្តបាត់ដំបងក្នុងរដ្ឋការនៃរបប លន់ នល់ រយៈពេលជាង២ឆ្នាំ ។

### ក.១) ការសម្លាប់មន្ត្រីក្នុងរបប លន់ នល់

ទាក់ទងនឹងព្រឹត្តិការណ៍នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាក្សី ឈុនលី បានពិពណ៌នាថា នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្លួនបានឮការផ្សព្វផ្សាយតាមវិទ្យុជាតិថា ឧត្តមសេនីយ៍ ម៉ី ស៊ីចន និង លន់ ណុន (ប្អូនប្រុសរបស់ លន់ នល់) បានប្រកាសចុះចាញ់ និងបញ្ជាឲ្យទាហានទាំងអស់ទម្លាក់អាវុធចុះ ។ ប៉ុន្តែខ្មែរក្រហមបានប្រកាសថា "យើងឈ្នះដោយការតស៊ូប្រដាប់អាវុធ មិនមែនដោយការចរចារទេ" ។

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរ ដោយស្នើឲ្យសាក្សីធ្វើការបញ្ជាក់ចំពោះផ្នែកមួយនៃសៀវភៅរបស់សាក្សីត្រង់ចំណុចនៃការផ្សព្វផ្សាយរបស់ខ្មែរក្រហម ។ ផ្នែកនោះបានសរសេរថា ៖

"នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៥ គឺថ្ងៃទី៣ ខ្មែរក្រហមបានផ្សព្វផ្សាយឲ្យដឹងថា ជនជាតិវៀតណាម យួនទាំងអស់ត្រូវត្រឡប់ទៅប្រទេសយួនវិញ ។ នៅថ្ងៃដដែលមានបទបញ្ជាពីថ្នាក់លើឲ្យគ្រប់នាយទាហាន លន់ នល់ ចាប់ពីអ្នកដែលមានឋានៈអនុសេនីយ៍ត្រី បានមកប្រមូលផ្តុំនៅសាលាបឋមសិក្សាសោហ៊ីជិតស្ពានថ្មី ។ ទាហានទាំងអស់សុទ្ធតែមកដៃទទេ គ្មានអាវុធជាប់ខ្លួន ហើយស្នាក់នៅទាំងយប់ទាំងថ្ងៃនៅកន្លែងប្រមូលផ្តុំ ។"

សាក្សីបញ្ជាក់ថា ខ្មែរក្រហមមិនបានប្រើប្រព័ន្ធផ្សព្វផ្សាយជាផ្លូវការទេ ប៉ុន្តែការផ្សព្វផ្សាយនោះមានប្រសិទ្ធភាព ។ លោកបានបន្តថា ទាហានក្នុងរដ្ឋការ លន់ នល់ ដែលមានឋានន្តរសក្តិចាប់ពីសក្តិ១ ឡើងទៅត្រូវបានខ្មែរក្រហមប្រកាសថា ឲ្យទៅចូលរួមទទួលសម្តេច សីហនុ ប៉ុន្តែអ្នកទាំងនោះត្រូវបានដឹកយកទៅសម្លាប់ទាំងអស់ ។ រីឯទាហានដែលមានឋានន្តរសក្តិទាបជាងនេះ គឺមិនត្រូវបានយកទៅសម្លាប់ទេ ប៉ុន្តែ ត្រូវបាននាំយកទៅដាំបន្លែនៅខេត្តប៉ៃលិន ត្រង់អូរពងមាន់ ។

ឆ្លើយតបនឹងសំណួរទាក់ទងនឹងការងារនៅមន្ទីរយោធានៅខេត្តបាត់ដំបង សាក្សីបានបញ្ជាក់ថា នៅរយៈពេលប៉ុន្មានថ្ងៃក្រោយការទទួលជ័យជម្នះ ខ្មែរក្រហមបានចាប់ផ្តើមសកម្មភាពសម្លាប់ពេទ្យយោធាដែលធ្លាប់បម្រើការនៅក្នុងរបប លន់ នល់ ដែលមានឋានន្តរសក្តិចាប់ពីសក្តិ១ ឡើងទៅ ។ ចាប់ពីឆ្នាំ១៩៧៧ ពេទ្យស៊ីវិលក៏បានក្លាយទៅជាគោលដៅក្នុងការនាំយកទៅសម្លាប់ដែរ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានសួរថា តើខ្មែរក្រហមបានផ្សព្វផ្សាយការអំពាវនាវរបស់ ខ្លួនឲ្យទាហាន លន់ នល់ មកចូលរួមទទួលសម្តេចសីហនុតាមរយៈអ្វី? សាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងថា តើខ្មែរក្រហមផ្សព្វផ្សាយការអំពាវនាវនេះតាមរយៈអ្វីទេ ប៉ុន្តែនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ អតីតទាហានក្នុងរដ្ឋការ លន់ នល់ ទាំងអស់នៅបាត់ដំបង បានជឿចំពោះសេចក្តីអំពាវនាវរបស់ខ្មែរក្រហមឲ្យទៅចូលរួមទទួលសម្តេចសីហនុ នៅភ្នំពេញ ។ ប៉ុន្តែក្រោយមកអ្នកទាំងនោះត្រូវបានដឹងថា ខ្មែរក្រហមបានដឹកនាំយកទៅសម្លាប់នៅភ្នំតាផ្ទេរ ។

### ក.២) ការជម្លៀសប្រជាជននៅបាត់ដំបង

ទាក់ទងនឹងការជម្លៀសប្រជាជន សាក្សី ហ៊ុន ឈុនលី បានបញ្ជាក់ថា នៅខេត្តបាត់ដំបង ការជម្លៀសប្រជាជន បានធ្វើឡើងគ្រប់ទីកន្លែង ប៉ុន្តែពុំមានឃើញមនុស្សស្លាប់នៅតាមផ្លូវទេ ។ សាក្សីបានបន្ត ថា ខ្លួនឃើញមានការបាញ់កាំភ្លើងនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ ដើម្បីឲ្យប្រជាជនចាកចេញពីទីលំនៅរបស់ខ្លួន ។ ចំពោះការជម្លៀសព្រះសង្ឃចេញពីវត្ត សាក្សីបានអះអាងថា នៅក្រោយឆ្នាំ១៩៧៦ ចាប់ផ្តើមមានការបណ្តេញព្រះសង្ឃឲ្យចាកចេញពីវត្ត ។ លោកបន្តថា អ្នកជំងឺចាស់ក្មេង គឺពុំត្រូវបានលើកលែងទេ អ្នកទាំងនោះសុទ្ធតែត្រូវបានជម្លៀសចេញពីទីក្រុងទាំងអស់ ។ ចំពោះអាចារ្យ សាន និង ស៊ីវ ហេង ដែលជាឪពុកមារបស់ នួន ជា ត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់ចោលភ្លាមៗនៅប៉ៃលិន ក្រោយពេលខ្មែរក្រហមចូលដល់បាត់ដំបងនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ។

### ក.៣) ជំហរខ្មែរក្រហមចំពោះសាសនា

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា វើង ហ៊ិត ទាក់ទងនឹងជនជាប់ចោទ ខៀវ សំផន សាក្សី ឈុនលី បានបញ្ជាក់ថា ខ្លួនធ្លាប់ស្គាល់ ខៀវ សំផន ដំបូងនៅទីក្រុងភ្នំពេញ គឺនៅពេលដែល ខៀវ សំផន ធ្វើជានាយកកាសែត ឡុបសេវ៉ាទ័រ ដែលសរសេរជាភាសាបារាំង ។ មានពេលមួយនោះកម្មាភិបាលខ្មែរក្រហមបានហៅខ្លួន និងប្រជាជនផ្សេងទៀត ឲ្យស្តាប់វិទ្យុដែលថ្លែងដោយសម្តេចនរោត្តម សីហនុ និង ខៀវ សំផន ទាក់ទងនឹងរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលលើកឡើងអំពីសិទ្ធិក្នុងការគោរពសាសនា ថាប្រជាជនទាំងពីរភេទ មានសិទ្ធិគោរពឬមិនគោរពសាសនា ។ ចំពោះការប្រកាសរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងសិទ្ធិរបស់ប្រជាជនក្នុងការជឿ ឬមិនជឿលើសាសនាណាមួយ សាក្សីអះអាងថា បន្ទាប់ពីឆ្នាំ១៩៧៦ ព្រះសង្ឃទាំងអស់ត្រូវបានបណ្តេញចេញពីវត្ត រីឯព្រះវិហារសាសនាគ្រិស្តមួយនៅបាត់ដំបង ត្រូវបានខ្មែរក្រហមវាយកម្ទេចចោល ហើយប្រធាននៃវិហារនោះឈ្មោះ ទេព ប៊ូអ៊ឹម ក៏ត្រូវបានយកទៅសម្លាប់ចោលដែរ ។

### ខ) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ បានបន្តសាកសួរទាក់ទងនឹងព្រឹត្តិការណ៍ជម្លៀសប្រជាជននៅខេត្តបាត់ដំបងនៅក្នុងអំឡុងពេលនៃខែមេសា ឆ្នាំ១៩៧៥ ដោយផ្អែកលើសៀវភៅដែលសាក្សីបានសរសេរដើម្បីបញ្ជាក់បន្ថែម ។

ឈុនលី បានបញ្ជាក់ថា នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង៨ព្រឹក បុគ្គលិកពេទ្យរបស់ខ្មែរក្រហមបានហៅពេទ្យទាហានដែលធ្លាប់បម្រើការនៅក្នុងរបប លន់ នល់ ចំនួន១៣នាក់ ដែលមានឋានន្តរសក្តិចាប់ពីសក្តិ១ឡើងទៅ ឲ្យទៅប៉ៃលិន និងបានបញ្ជាឲ្យអ្នកទាំងនោះចុះពីលើឡាន ហើយបាញ់សម្លាប់ចោលតែម្តង ។ សាក្សីបានសង្កត់ធ្ងន់ថា នេះគឺជាអ្វីដែលខ្លួនមិនអាចបំភ្លេចបាន ។

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានស្នើសាក្សីឲ្យធ្វើការបញ្ជាក់បន្ថែមទាក់ទងនឹងការបាត់ខ្លួន ស៊ីវ ហេង ដោយសារខ្មែរក្រហមចាប់ ។ សាក្សីបានបញ្ជាក់ថា ក្នុងឋានៈជាបញ្ញវន្តមួយរូប ខ្លួនបានដឹងពីដំណឹងនេះ



វត្តបឹងវ៉ែ ក្នុងឃុំក្រោលគោ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដែលរងការបំផ្លិចបំផ្លាញដោយសាររបបខ្មែរក្រហម ។ រូបនេះថតនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ។(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយសារក្រោយព្រឹត្តិការណ៍ចុះចូលជាមួយនឹងសម្តេច សីហនុ, ស៊ីវ ហេង ត្រូវបានព្រះអង្គតែងតាំងជាយោធាសក្តិ៥ ។

ចំពោះការលើកឡើងអំពីការចាញ់បោកខ្មែរក្រហមនៅក្នុងសៀវភៅរបស់ខ្លួន សាក្សីបានពន្យល់ថា គឺដោយសារតែខ្លួនគិតថា ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម គឺជាបុគ្គលដែលស្អាតស្អំ និងស្នេហាជាតិ ។ សាក្សីបានពន្យល់ថា ខ្លួនបានសម្រេចចិត្តមិនរត់ចេញពីកម្ពុជាទៅប្រទេសថៃ ដោយសារចង់នៅបម្រើប្រទេស



យោធាខ្មែរក្រហមកំពុងហ៊ីកហ៊ឺនក្បួនយុទ្ធសាស្រ្តត្រៀមប្រយុទ្ធនៅសមរភូមិ (ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាតិជាមួយបុគ្គលដែលខ្លួនគិតថាស្អាតស្អំ ប៉ុន្តែខ្លួនមានការខកចិត្តយ៉ាងខ្លាំងចំពោះអ្វីដែលខ្មែរក្រហមបានប្រព្រឹត្ត ។

## ១.១) រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមរបស់របបខ្មែរក្រហម

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា ថារីក បានបន្តសួរទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមរបស់ខ្មែរក្រហម ដោយស្នើឲ្យសាក្សីធ្វើការបញ្ជាក់ ។ ឈុនលី បានពន្យល់តាមការយល់ដឹងរបស់ខ្លួនថា រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមរបស់ខ្មែរក្រហម គឺមានភូមិ និងឃុំ ដែលមានប្រធានភូមិ/ឃុំមួយ និងមានអនុប្រធានពីររូប ប៉ុន្តែពុំមានស្នាក់ការអ្វីឡើយ គឺយកផ្ទះប្រជាជនធ្វើជាស្នាក់ការ ។ ទាក់ទងនឹងឈ្លប សាក្សីអះអាងថា ឈ្លប គឺជាកូនប្រជាជន ប៉ុន្តែមានចិត្តមោះមុតក្នុងការប្រយុទ្ធ ហើយឈ្លបទាំងនោះអាចលួចស្តាប់ការទាក់ទងរបស់ប្រជាជន ។

## ១.២) ប្រជាជនចាស់ និងប្រជាជនថ្មី

ពាក់ព័ន្ធនឹងការបែងចែករវាងប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី ឬអ្នក១៧មេសា សាក្សីបានបញ្ជាក់ការបែងចែកនេះ គឺជាការរើសអើងរបស់ខ្មែរក្រហម មិនមែនជាការបែកចែករបស់ប្រជាជនកម្ពុជាទេ ។ ខ្មែរក្រហមធ្វើអ្វីៗសុទ្ធតែអវិជ្ជមាន និងដើម្បីបំផ្លាញប្រទេសជាតិ ដែលផ្ទុយពីការគិតសង្ឃឹមរបស់ប្រជាជន ។ សាក្សី ឈុនលី បន្តថា ខ្មែរក្រហមមិនចូលចិត្តអ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់ ឬបញ្ញវន្តទេ ។ អ្នកដែលពាក់វ៉ែនតាត្រូវបានខ្មែរក្រហមចាត់ទុកថាជាបញ្ញវន្ត ដូច្នេះខ្លួន(សាក្សី) ត្រូវបង្ខំចិត្តឈប់ពាក់វ៉ែនតា ទោះបីជាភ្នែកមើលពុំច្បាស់ក៏ដោយ ។

### ១.៣) ការអប់រំសតិអារម្មណ៍

ចំពោះការណែនាំឲ្យមានការលះបង់កម្មសិទ្ធិឯកជន និងកម្មសិទ្ធិសតិអារម្មណ៍ សាក្សីបានបញ្ជាក់ថា សមមិត្ត ស៊ូ បានប្រាប់ប្រជាជនថា អង្គការមិនចំណាយពេល៧ឆ្នាំដើម្បីបណ្តុះបណ្តាលវេជ្ជបណ្ឌិតទេ គឺអង្គការចំណាយពេលត្រឹមតែ៧ថ្ងៃតែប៉ុណ្ណោះដើម្បីបណ្តុះបណ្តាលពេទ្យ ។ សាក្សីបានបន្តទៀតថា នេះគឺជាគោលនយោបាយមួយរបស់ខ្មែរក្រហមដើម្បីសម្លាប់ប្រជាជន ។ ភ្លាមៗនោះ មេធាវីជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោក សុន អរុណ បានជំទាស់ និងស្នើកុំឲ្យសាក្សីឆ្លើយដោយសន្និដ្ឋាន ។ ឆ្លើយតបនឹងការជំទាស់នេះ អង្គជំនុំជម្រះបានបង្គាប់ឲ្យសាក្សីមិនត្រូវឆ្លើយសំណួរដោយធ្វើសេចក្តីសន្និដ្ឋាន និងបង្ហាញពីការយល់ឃើញផ្ទាល់ខ្លួន គឺត្រូវឆ្លើយត្រឹមតែអ្វីដែលសហព្រះរាជអាជ្ញាសួរប៉ុណ្ណោះ ។



កម្មាភិបាលពេទ្យខ្មែរក្រហមកំពុងវះកាត់អ្នកជំងឺ
(ថតដោយ ហ្វូណា ប៊ីយស្រ្តូង នៅខែសីហា ឆ្នាំ១៩៧៨) (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

សាក្សី ហ៊ិន ឈុនលី បានបន្តទៀតថា រឿងមួយដែលខ្លួនមិនអាចបំភ្លេចបានក្នុងមួយជីវិត គឺនៅពេលខ្លួនឃើញនារីម្នាក់ត្រូវបានខ្មែរក្រហមចាក់ថ្នាំសណ្តំដើម្បីធ្វើពិសោធន៍ និងក្រោយមកត្រូវបានយកដាក់ចូលក្នុងឡដើម្បីដុតទាំងរស់ ។ សាក្សីបានបញ្ជាក់ថា ខ្លួនបានឮប្រធានមន្ទីរពេទ្យឈ្មោះ ដុន ចេញបញ្ជាដោយផ្ទាល់ឲ្យកូនចៅរបស់ខ្លួនសម្លាប់នារីម្នាក់នោះចោល ។ សាក្សីបានបន្ថែមថា ខ្លួនធ្លាប់បានធ្វើការជាពេទ្យនៅក្នុងរបបខ្មែរក្រហមរយៈពេល ១៦ខែ ប៉ុន្តែមិនមានតួនាទីអ្វីឡើយ ហើយខ្មែរក្រហមពុំដែលបញ្ជាឲ្យខ្លួនព្យាបាលដល់ជនស៊ីវិលទេ គឺឲ្យព្យាបាលតែយោធាខ្មែរ-ក្រហមតែប៉ុណ្ណោះ ទោះបីជាជនស៊ីវិលមានជំងឺក៏ដោយ ។ ក្រោយមកខ្លួនត្រូវបានខ្មែរក្រហមផ្លាស់ឲ្យទៅធ្វើស្រែរហូតដល់ពេលរបបខ្មែរក្រហមដួលរលំ ។

### ១.៤) លក្ខណៈពិសេសនៃភូមិវិត្តគរក្នុងរបបខ្មែរក្រហម

ទាក់ទងនឹងប្រជាជនដែលរស់នៅភូមិវិត្តគរ នៅខេត្តបាត់ដំបង តំណាងសហព្រះរាជអាជ្ញាបានដកស្រង់ឃ្លាមួយដែលសាក្សីបានសរសេរនៅក្នុងសៀវភៅរបស់ខ្លួន ។ នៅត្រង់ឃ្លានោះបានសរសេរថា ៖

"ក្រោមរបបខ្មែរក្រហម ឃុំវិត្តគរ ទទួលបាននូវការប្រព្រឹត្តមួយពិសេសខុសពីឃុំផ្សេងៗ ដែលប្រជាជនមានស្ថានភាពយ៉ាប់យ៉ឺន ។ ហើយខាងអ្នកវិត្តគរនេះ បានទទួលរបបអាហារគ្រប់គ្រាន់ ។ នៅពេលប្រជាជននៅឃុំដទៃនោះកំពុងតែអត់អាហារ របបអាហារនៅឃុំវិត្តគរ មិនផ្លាស់ប្តូរនោះទេ ។ ម្តាយរបស់ នួន ជា ទទួលបាននូវការប្រព្រឹត្តល្អគ្រប់គ្រាន់ ហើយគាត់ទទួលបាននូវអង្ករ ស្ករ និងគ្រឿងឧបត្ថម្ភផ្សេងទៀតគ្រប់គ្រាន់" ។

ឆ្លើយតបនឹងសំណើរបស់តំណាងសហព្រះរាជអាជ្ញាដែលស្នើសុំការបញ្ជាក់អំពីចំណុចនេះ សាក្សី ហ៊ិន ឈុនលី បានពិពណ៌នាថា ខ្លួនធ្លាប់ស្គាល់ភូមិវិត្តគរចាប់តាំងពីឆ្នាំ១៩៦៧ គឺនៅពេលដែលខ្លួនបានទៅធ្វើការនៅទីនោះ ហើយខ្លួនក៏ធ្លាប់ព្យាបាលជំងឺជូនសមាជិកគ្រួសាររបស់ នួន ជា ដែរ ។ សាក្សីបានបង្ហាញ អំពីចំណាប់អារម្មណ៍របស់ខ្លួនថា ប្រជាជនរស់នៅភូមិវិត្តគរទទួលបានការយកទុកដាក់ជាងទីកន្លែងផ្សេងៗទៀតនៅទូទាំងប្រទេស ហើយរបបអង្ករប្រចាំថ្ងៃសម្រាប់ប្រជាជនម្នាក់ គឺ១កំប៉ុងកន្លះ

ទោះបីជាកន្លែងផ្សេងទៀតកំពុងខ្វះខាតក៏ដោយ ។

សាក្សីរូបនេះបានបញ្ជាក់ជាចុងក្រោយថា បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ គ្រូពេទ្យដែលធ្លាប់ធ្វើការនៅបាត់ដំបងមានតែពីររូបប៉ុណ្ណោះដែលនៅរស់រានមានជីវិត ។ ទីមួយគឺរូបសាក្សីផ្ទាល់ និងទីពីរ គឺលោក អ៊ុន ស៊ី ដែលបានចាកចេញទៅរស់នៅប្រទេសកាណាដា ។

### ៣) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក វ៉ែន ពៅ បានចាប់ផ្តើមសួរសាក្សីរំឭកឡើងវិញអំពីព្រឹត្តិការណ៍មុនឆ្នាំ ១៩៧៥ នៅខេត្តបាត់ដំបង ។ បន្ទាប់មកលោកមេធាវីបានបន្តសាកសួរទាក់ទងនឹងអ្នកជំងឺដែលនាំយកមកព្យាបាលនៅមន្ទីរពេទ្យបាត់ដំបងក្នុងអំឡុងពេលសាក្សីកំពុងបម្រើការនៅទីនោះ ថាតើជាអ្នកជំងឺធម្មតា ឬអ្នកដែលទទួលរងរបួស? សាក្សី ហ៊ិន ឈុនលី បានបញ្ជាក់ថា អ្នកដែលរងរបួសភាគច្រើន គឺជាទាហាននៃរបបលន់ នល់ ។ អ្នកជំងឺនៅទីនោះត្រូវបានបែងចែកជាបីប្រភេទ គឺអ្នកជំងឺដែលមានរបួសស្រាល មធ្យម និងធ្ងន់ ។ យោធារងរបួសទាំងអស់នោះត្រូវបានបញ្ជូនមកពីសមរភូមិមោងឫស្សី ព្រៃស្វាយ និងតាប៉ុន ។

មេធាវី វ៉ែន ពៅ បានបន្តសួរទាក់ទងនឹងការជម្លៀសអ្នកជំងឺចេញពីមន្ទីរពេទ្យ និងការជម្លៀសប្រជាជនចេញពីទីក្រុងបាត់ដំបង ដោយសួរថាតើសាក្សីមានធ្លាប់ដឹងថាមានប្រជាជនត្រូវបានសម្លាប់ដោយសារការពុំព្រមចាកចេញដែរឬទេ? សាក្សីបញ្ជាក់ថា ខ្លួនគិតថា មិនមានប្រជាជនណាម្នាក់ហ៊ានជំទាស់នឹងបញ្ជាឲ្យចេញពីទីក្រុងរបស់ខ្មែរក្រហមទេ ហើយសាក្សីក៏ពុំធ្លាប់ឃើញមានការសម្លាប់ប្រជាជននៅពេលជម្លៀសដែរ ។ សាក្សីបានបន្ថែមថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅក្រុងបាត់ដំបង ត្រូវបានជម្លៀសចេញ ក្រោយមកទើបមានប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញទៅដល់បាត់ដំបងតាមរយៈរទេះភ្លើង ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោល មេធាវី វ៉ែន ពៅ បានផ្ទេរវេទិកាជូនសហភាគាអន្តរជាតិ គឺមេធាវី អេលីហ្សាប៊ែត ស៊ីម៉ុនណូហូត ដើម្បីបន្តចោទសួរសាក្សី ។ ទាក់ទងនឹងការបណ្តេញជនជាតិវៀតណាមចេញពីប្រទេសកម្ពុជា ឈុនលី បានពិពណ៌នាថា ខ្លួនធ្លាប់បានឃើញមានទូកជាច្រើនដឹកជនជាតិវៀតណាមទាំងក្មេង ទាំងចាស់ ទាំងប្រុសទាំងស្រី អមដោយទូករបស់យោធាខ្មែរក្រហមធ្វើដំណើរតាមទន្លេមេគង្គ ប៉ុន្តែខ្លួនពុំបានដឹងថា ខ្មែរក្រហមដឹកអ្នកទាំងនោះយកទៅណាទេ ។ សាក្សីក៏បានលើកអំពីករណីជាក់ស្តែងមួយទាក់ទងនឹងជនជាតិខ្មែរដែលមានជាប់សាច់ឈាមជាមួយនឹងវៀតណាម គឺមានឪពុកជាខ្មែរ និងម្តាយជាវៀតណាមត្រូវបានខ្មែរក្រហមយកទៅសម្លាប់ទាំងគ្រួសារ ។

### ៤) ការសួរដេញដោលដោយមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម

#### ក) ក្រុមមេធាវីការពារក្តី នួន ជា

#### ក.១) មេធាវីជាតិ

មេធាវីជាតិការពារក្តីជនជាប់ចោទ នួន ជា គឺមេធាវី សុន អរុណ បានចាប់ផ្តើមសំណួរពាក់ព័ន្ធនឹងកាលបរិច្ឆេទពិតប្រាកដនៃការចូលមកដល់នៃយោធាខ្មែរក្រហមនៅទីក្រុងបាត់ដំបង ។ សាក្សីបានបញ្ជាក់ថា នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្លួនពុំទាន់ឃើញមានយោធាខ្មែរក្រហមចូលដល់ទីក្រុងបាត់ដំបងទេ ។ បន្ទាប់មកនៅរសៀលម៉ោងបីថ្ងៃដដែល យោធាខ្មែរក្រហមបានចូលដល់ទីក្រុងបាត់ដំបង ។

ចំពោះសំណួរទាក់ទងនឹងគ្រួសាររបស់ជនជាប់ចោទ នួន ជា មេធាវី សុន អរុណ បានសួរថា តើសាក្សីធ្លាប់ស្គាល់ នួន ជា ច្បាស់លាស់ដែរឬទេ? សាក្សីបានបញ្ជាក់ថា គ្រួសាររបស់ នួន ជា ជាគ្រួសារល្អ ហើយម្តាយរបស់ នួន ជា ជាមនុស្សដែលគួរឲ្យគោរព ប៉ុន្តែខ្លួនពុំស្គាល់ នួន ជា ទេ ហើយក៏ពុំបានដឹងថា នួន ជា មានតួនាទីជាអ្វីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ បន្ទាប់មកមេធាវី អរុណ បានបន្តសួរទៀតថា តើសាក្សីមានដឹងថា នួន ជា ធ្លាប់បានបញ្ជាឲ្យកម្មាភិបាលណាម្នាក់យកមនុស្សទៅដាក់គុក ឬយកទៅសម្លាប់ដែរឬទេ? សាក្សីបានឆ្លើយថា ខ្លួនពុំបានដឹងអំពីបញ្ហានេះទេ ។ ចំពោះឃ្លាដែលសាក្សីបានសរសេរនៅក្នុងសៀវភៅរបស់ខ្លួនទាក់ទងនឹងតួនាទីរបស់ នួន ជា ថាជាបងធំទី២ មេធាវីបានសួរថា តើសាក្សីដឹងថា នួន ជា ជាបងធំទី២ដោយវិធីណា? ហ៊ិន ឈុនលី

បានបញ្ជាក់ថា ខ្លួនបានឮពីអ្នកដែលធ្លាប់ស្គាល់និយាយតៗគ្នាថា នួន ជា គឺជាបងទី២ ។

### ៤.ក.២) មេធាវីអន្តរជាតិ

បន្ទាប់មកមេធាវីអន្តរជាតិ ហ្សាស្តេ ប៉ោ បានបន្តពីសហភាគីរបស់ខ្លួនដើម្បីចោទសួរសាក្សីទាក់ទងនឹងការកត់ត្រាអំពីកំណត់ហេតុក្នុងអំឡុងពេលនៃរបបខ្មែរក្រហមថា ហេតុអ្វីបានជាសាក្សីធ្វើការកត់ត្រាកំណត់ហេតុនៅពេលនោះ? សាក្សីបានបញ្ជាក់ថា ក្នុងនាមខ្លួនជាបញ្ញវន្តមួយរូប ការកត់ត្រាអំពីព្រឹត្តិការណ៍គឺជារឿងសំខាន់ណាស់នៅក្នុងជីវិត ប៉ុន្តែដោយសារនៅក្នុងសម័យខ្មែរក្រហម កម្មាភិបាលខ្មែរក្រហមតែងតែចុះមកធ្វើការឆែកឆេរផ្ទះ ហេតុនេះខ្លួនក៏បានសម្រេចចិត្តដុតសៀវភៅកំណត់ហេតុនោះចោលតែម្តង ដោយសារការព្រួយបារម្ភ ។ ក្រោយមកខ្លួនបានព្យាយាមរំឭកការចងចាំឡើងវិញដើម្បីសរសេរកំណត់ហេតុនោះនៅក្រោយរបបខ្មែរក្រហម និងបន្ទាប់មកនៅក្នុងឆ្នាំ ២០០៦ ខ្លួនបានព្យាយាមចងក្រងកំណត់ហេតុនោះដើម្បីបោះពុម្ពជាសៀវភៅ ។ មេធាវី ហ្សាស្តេ ប៉ោ បានបន្តសួរទាក់ទងនឹងប្រភពដែលសាក្សីប្រើប្រាស់ដើម្បីចងក្រងធ្វើជាសៀវភៅ ។ ឆ្លើយតបនឹងសំណួរនេះ ឈុនលី បានបញ្ជាក់ថា សៀវភៅដែលខ្លួនសរសេរ គឺផ្អែកលើបទពិសោធន៍នៃជីវិតផ្ទាល់ខ្លួនស្ទើរតែទាំងស្រុង ។ មេធាវី ហ្សាស្តេ បានបន្តសួរទៀតថា តើសាក្សីធ្លាប់អានសៀវភៅប្រវត្តិសាស្ត្រអំពីកម្ពុជាប្រជាធិបតេយ្យ ឬអំពីរបបខ្មែរក្រហមដែរឬទេ? សាក្សីបានអះអាងថា ខ្លួនពិតជាធ្លាប់បានអានសៀវភៅប្រវត្តិសាស្ត្រមួយចំនួន ក្រោយពេលនៃការដួលរលំនៃរបបខ្មែរក្រហមមែន ដូចជាសៀវភៅដែលសរសេរដោយអតីតភរិយារបស់ សួង ស៊ីគឿន ដែលជាជនជាតិបារាំង និងសៀវភៅ "អ្នកទោសនយោបាយ" ដែលជាព្រះរាជនិពន្ធរបស់សម្តេចព្រះនរោត្តម សីហនុ ជាដើម ។ បន្ទាប់មកមេធាវីបានសួរទៀតថា តើការអានសៀវភៅទាំងនេះ អាចជះឥទ្ធិពលដល់ការសរសេរសៀវភៅដែលនិយាយពីបទពិសោធន៍របស់សាក្សីដែរឬទេ? ឈុនលី បានបញ្ជាក់ថា ការអានសៀវភៅទាំងនោះពុំបានជះឥទ្ធិពលមកលើការសរសេរសៀវភៅរបស់ខ្លួនទេ ព្រោះសៀវភៅរបស់ខ្លួនរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះ ។

សូមបញ្ជាក់ថា ការសួររបស់មេធាវីការពារក្តី នួន ជា ចំពោះការនិពន្ធ និងចងក្រងសៀវភៅរបស់សាក្សីនេះ គឺដោយសារមេធាវីការពារក្តីចង់បង្ហាញថា ប្រសិនបើការសរសេររបស់សាក្សី ហ៊ុន ឈុនលី ពឹងផ្អែកភាគច្រើនលើសៀវភៅរបស់អ្នកប្រវត្តិសាស្ត្រ នោះសក្ខីកម្មរបស់សាក្សីក្នុងសវនាការមិនអាចយកជាការបានឡើយ ។

ទាក់ទងនឹងការសម្លាប់មនុស្ស សាក្សីបញ្ជាក់ថា ខ្លួនពុំធ្លាប់ឃើញមានការសម្លាប់មនុស្សដោយផ្ទាល់នោះទេ ហើយខ្លួនក៏មិនធ្លាប់ឃើញមានការកាប់សម្លាប់ចំពោះទាហាន លន់ នល់ ដែរ ។

បន្ទាប់មកមេធាវី ហ្សាស្តេ បានបន្តសួរទាក់ទងនឹងការបាត់ខ្លួនរបស់ ស៊ីវ ហេង និងអាចារ្យ សាន ដោយបានចោទសួរថា តើសាក្សីដឹងអំពីការបាត់ខ្លួនអ្នកទាំងពីរនេះដោយរបៀបណា? សាក្សីបានបញ្ជាក់ថា ខ្លួនបានដឹងអំពីការបាត់ខ្លួននេះតាមរយៈការនិយាយពីមាត់មួយទៅមាត់មួយ ម្យ៉ាងវិញទៀតខ្លួនក៏ធ្លាប់បានជួបជាមួយនឹងប្រពន្ធរបស់ ស៊ីវ ហេង ដោយផ្ទាល់ដែរ ។ ទាក់ទងនឹងការបាត់ខ្លួនអាចារ្យ សាន សាក្សីអះអាងថា គឺមានការបញ្ជាឲ្យចាប់ខ្លួនពីថ្នាក់លើ ។ បន្ទាប់មកមេធាវីបន្តសួរថា តើនរណាជាម្នាក់លើ? សាក្សីបានស្នើឲ្យមេធាវីសួរទៅខ្មែរក្រហមវិញ ដោយសារពាក្យថាថ្នាក់លើ គឺជាភាសាដែលខ្មែរក្រហមតែងតែប្រើប្រាស់ ដើម្បីដោះសារយករួចខ្លួន ។ ដូច្នេះមិនមាននរណាម្នាក់ដឹងថា ថ្នាក់លើជានរណានោះទេ ។

ទាក់ទងនឹងការវះកាត់ដើម្បីធ្វើពិសោធន៍ ដែលសាក្សីបានលើកឡើងក្នុងការឆ្លើយតបជាមួយនឹងសហព្រះរាជអាជ្ញា និងបានសរសេរនៅក្នុងសៀវភៅរបស់សាក្សី មេធាវី ហ្សាស្តេ ចោទសួរថា តើសាក្សីធ្លាប់បានឃើញ ឬមួយធ្លាប់បានចូលរួមនៅក្នុងការវះកាត់ដើម្បីធ្វើពិសោធន៍ក្នុងអំឡុងពេលនៃរបបខ្មែរក្រហមដែរឬទេ? ហ៊ុន ឈុនលី បានអះអាងថា ខ្លួនពុំដែលធ្លាប់បានឃើញការវះកាត់ដោយផ្ទាល់ទេ ហើយក៏ពុំធ្លាប់ចូលរួមនៅក្នុងការវះកាត់នោះដែរ ពីព្រោះលោកពុំមែនជាពេទ្យណាហ្នឹងទេ ។

ទាក់ទងនឹងសាកសពដែលត្រូវបានប្រទះឃើញក្នុងរណ្តៅកប់សាកសពរួមនៅខេត្តបាត់ដំបង មេធាវី ហ្សាស្តេ បានចោទសួរ

ឈុនលី ថា តើសាក្សីជឿជាក់ដែរឬទេថា សាកសពទាំងអស់ដែលសាក្សីបានឃើញនៅក្នុងរណ្តៅសាកសពនោះសុទ្ធតែជាប្រជាជនដែលស្លាប់ដោយសាររបបខ្មែរក្រហមទាំងអស់? ឬជាប្រជាជនដែលស្លាប់នៅក្នុងសម័យក-៥រាប់សិបម៉ឺននាក់ ហើយត្រូវបានយកទៅកប់នៅក្នុងរណ្តៅសាកសពរួមនោះដែរ? មេធាវី ហ្សាស្តេ អះអាងថា ខ្លួនសួរសំណួរនេះគឺយោងលើរបាយការណ៍ដែលរកឃើញដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងសាកសពដែលត្រូវបានកប់នៅក្នុងរណ្តៅសាកសពរួម ។ ប៉ុន្តែសំណួរនេះត្រូវបានសាក្សីបដិសេធមិនឆ្លើយតប ដោយអះអាងថា សំណួរដែលមេធាវី ហ្សាស្តេ បានចោទសួរ គឺមិនមានការជាប់ពាក់ព័ន្ធនឹងអង្គហេតុនៃសវនាការ ហើយសាក្សីបានសួរអង្គជំនុំជម្រះដែរថា តើខ្លួនអាចឆ្លើយតបនឹងសំណួរនេះបានដែរឬទេ? បើសិនជាអង្គជំនុំជម្រះអនុញ្ញាតខ្លួននឹងឆ្លើយតបនឹងសំណួររបស់មេធាវី ។ ភ្លាមៗនោះ ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានបង្គាប់មិនឲ្យសាក្សីឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តីទេ ដោយសារវិសាលភាពនៃសវនាការ គឺកាត់សេចក្តីតែលើអង្គហេតុទាំងឡាយដែលកើតឡើងនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ ។ មេធាវី ហ្សាស្តេ បានព្យាយាមពន្យល់អង្គជំនុំជម្រះអំពីគោលបំណងនៃការសួរសំណួររបស់ខ្លួនថា មូលហេតុដែលខ្លួនសួរសំណួរនេះ គឺដោយសារតែសាក្សីធ្លាប់បានសរសេរនៅក្នុងសៀវភៅរបស់ខ្លួនទាក់ទងនឹងសាកសពដែលត្រូវបានរកឃើញនៅក្នុងឆ្នាំ១៩៨២ ហើយនៅក្នុងសម័យក-៥ក្រោយរបបខ្មែរក្រហមដួលរលំ ក៏មានការស្លាប់មនុស្សរាប់សិបម៉ឺននាក់ ហើយយកទៅកប់នៅក្នុងរណ្តៅសាកសពរួមនៅក្នុងខេត្តបាត់ដំបងដែរ ។ ដូច្នេះខ្លួនចង់សួរបញ្ជាក់សាក្សីឲ្យកាន់តែច្បាស់បន្ថែមទៀតថា តើសាកសពដែលត្រូវបានរកឃើញ នៅក្នុងរណ្តៅសាកសពរួមទាំងនោះសុទ្ធតែអ្នកដែលស្លាប់ដោយសារខ្មែរក្រហម ឬមានមួយចំណែកផ្សេងទៀតដែលស្លាប់នៅក្នុងសម័យក-៥ ។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះបានបង្គាប់ឲ្យមេធាវី ហ្សាស្តេ ប្តូរសំណួររបស់ខ្លួនទៅប្រធានបទផ្សេង ។

បន្ទាប់មក មេធាវី ហ្សាស្តេ ប៉ោ បានបន្តចោទសួរសាក្សីជាច្រើន សំណួរទាក់ទងនឹងសម័យក-៥ ប៉ុន្តែសំណួរទាំងអស់នោះត្រូវបានអង្គជំនុំជម្រះបង្គាប់មិនឲ្យសាក្សីឆ្លើយតប ដោយផ្តល់ហេតុផលថា សំណួរទាំងនោះមិនមានជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះលើកយកមកជំនុំជម្រះ ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះបានកាត់ផ្តាច់មីក្រូរបស់មេធាវី ហ្សាស្តេ ជាញឹកញាប់ ។

## ១) ក្រុមមេធាវីការពារក្តី ខៀវ សំផន

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន លោកស្រី អង់តា ហ្គីសសេ បានចាប់ផ្តើម សំណួរដំបូងរបស់ខ្លួនទាក់ទងនឹងជនជាប់ចោទ ខៀវ សំផន ថាតើសាក្សីធ្លាប់ស្គាល់ ខៀវ សំផន ដែរឬទេ? សាក្សីបានអះអាងថា ដូចអ្វីដែលខ្លួនបានបញ្ជាក់ជូនតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីរួចមកហើយថា ខ្លួនធ្លាប់ស្គាល់ ខៀវ សំផន ក្នុងឋានៈ ខៀវ សំផន ជាបញ្ញវន្តមួយរូប និងជានាយកកាសែត



ខៀវ សំផន ក្នុងដំណើរទស្សនកិច្ចទៅបរទេស ដោយមាននិស្សិតខ្មែរនៅបរទេសរង់ចាំទទួលស្វាគមន៍ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡឺបសេវ៉ាទ័រ និងជាមន្ត្រីមួយរូបដែលត្រូវបានទទួលស្គាល់ថា "ស្អាតស្អំ" ។ ប៉ុន្តែខ្លួនពុំធ្លាប់បាននិយាយជាមួយនឹង ខៀវ សំផន ទេ ។ សាក្សីបន្តថា ខ្លួនចូលចិត្តអានកាសែតនេះ ដោយសារតែកាសែតនេះជាផ្តោតសំខាន់លើផ្នែកនយោបាយ និងជីវភាពអ្នកក្រីក្រ ។ សាក្សីបន្តថា កាសែត ឡឺបសេវ៉ាទ័រ ជាកាសែតបើកចំហរដែលទទួលបានការអនុញ្ញាតពីរដ្ឋ ។

មេធាវីជាតិការពារក្តី ខៀវ សំផន គឺលោក គង់ សំអុន បានបន្តពីសហភាគីរបស់ខ្លួន ដោយបន្តចោទសួរទាក់ទងនឹងកាសែត ឡឺបសេវ៉ាទ័រ ដែលត្រូវបានអះអាងថាជាកាសែតឆ្វេងនិយមដែលសរសេរច្រើនអំពីបញ្ហាសង្គម ។ លោកមេធាវីបានស្នើសាក្សី ហ៊ិន ឈុនលី ឲ្យជួយពន្យល់អំពីពាក្យថា ឆ្វេងនិយម ។ សាក្សីបានបញ្ជាក់ថា ឆ្វេងនិយម គឺសំដៅលើទស្សនៈលំអៀងទៅខាងកុម្មុយនីស្ត ។ មូលហេតុដែលខ្លួនយល់ឃើញដូច្នេះ ដោយសារតែកាសែតនេះជាកាសែតដែលប្រឆាំងនឹងអយុត្តិធម៌សង្គម ។ ចំពោះសំណួរទាក់ទងនឹងអាកប្បកិរិយារបស់ ខៀវ សំផន សាក្សីបានបញ្ជាក់ថា ក្នុងឋានៈជាយុវជនមួយរូប លោកមានការគោរពចំពោះ ខៀវ សំផន ដែលជាមនុស្សសាមញ្ញ ជិះម៉ូតូ និងស្អាតស្អំមិនពុករលួយ រហូតដល់ពេលដែល ខៀវ សំផន បានបាត់ខ្លួន ។ មេធាវីបានសួរថា តើសាក្សីដឹងអំពីការបាត់ខ្លួន ខៀវ សំផន ដោយរបៀបណា? ឈុនលី បានពន្យល់ថា ខ្លួនបានដឹងមិនត្រឹមតែការបាត់ខ្លួនរបស់ ខៀវ សំផន ទេ សូម្បីតែ ហ៊ូ យន់ និង ហ៊ូ នឹម ក៏ខ្លួនបានទទួលដំណឹងថាបានបាត់ខ្លួនដែរ ។ ក្រោយមកទើបខ្លួនបានដឹងថា ខៀវ សំផន បានរត់ចូលព្រៃនៅក្រោយពេលរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ប៉ុន្តែលោកមិនបានដឹងអំពីមូលហេតុដែលនាំឲ្យ ខៀវ សំផន រត់ចូលព្រៃទេ ។

បន្ទាប់មកមេធាវី គង់ សំអុន បានបន្តសួរទាក់ទងនឹងព្រះអង្គម្ចាស់ ភូរីស្សារា ដែលមានតំណែងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីស្នើឲ្យ ឈុនលី ធ្វើការបញ្ជាក់អំពីតួនាទីរបស់ព្រះអង្គ ។ សាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់បានជួបជាមួយនឹងទ្រង់ ភូរីស្សារា នៅក្នុងឆ្នាំ១៩៧៦ ពេលដែលខ្លួនរស់នៅខេត្តបាត់ដំបង ។ នៅពេលនោះព្រះអង្គបានប្រាប់ខ្លួនថា ក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងរបបខ្មែរក្រហម ប៉ុន្តែព្រះអង្គពុំមានតួនាទី និងអំណាចអ្វីទាំងអស់ គឺជារដ្ឋមន្ត្រីមានតែឈ្មោះ ។

តាមការសង្កេត ការចោទសួរសំណួរទាំងនេះរបស់មេធាវីការពារក្តី ខៀវ សំផន គឺដើម្បីបង្ហាញឲ្យឃើញដូចអ្វីដែល ខៀវ សំផន ធ្លាប់បានអះអាងថា ថ្វីត្បិតតែខ្លួនមានតួនាទីជាប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែខ្លួនពុំមានតួនាទី ឬសិទ្ធិអំណាចអ្វីឡើយ ។

## ក) ក្រុមមេធាវីការពារក្តី អៀង សារី

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ការណាវ៉ាស បានចាប់ផ្តើមសំណួរដំបូងរបស់ខ្លួនដោយផ្តោតជាសំខាន់លើប្រវត្តិសាវតារ និងគុណវុឌ្ឍិរបស់សាក្សី ឈុនលី ក្នុងឋានៈលោកជាវេជ្ជបណ្ឌិត ។ ឆ្លើយតបនឹងសំណួរនេះសាក្សីបានរៀបរាប់លម្អិតអំពីប្រវត្តិនៃការសិក្សា និងបទពិសោធន៍ការងាររបស់ខ្លួន ដូចអ្វីដែលខ្លួនបានឆ្លើយតបចំពោះសំណួរមុនៗរបស់ភាគី ។



សាក្សី ហ៊ិន ឈុនលី កំពុងលើកបង្ហាញសៀវភៅដែលខ្លួនបាននិពន្ធទាក់ទងនឹងរបបខ្មែរក្រហម (ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មកមេធាវី ការណាវ៉ាស បានសួរសាក្សីថា តើសាក្សីធ្លាប់បានទៅធ្វើការស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ? ឈុនលី បានបញ្ជាក់ថា ខ្លួនពុំធ្លាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ប៉ុន្តែធ្លាប់បានប្រគល់សៀវភៅរបស់ខ្លួនចំនួនពីរក្បាលជូនមជ្ឈមណ្ឌលឯកសារនេះ ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងការអានសៀវភៅរបស់សាក្សីក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ឈុនលី បាន បញ្ជាក់ថា នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្លួនធ្លាប់អានសៀវភៅប្រវត្តិសាស្ត្រដែលសរសេរជាភាសាបរទេសចំនួនបីក្បាល ។ ទីមួយគឺ សៀវភៅសរសេរជាភាសាបារាំង "ប្រវត្តិសាស្ត្រនៃប្រទេសរុស្ស៊ី" ទីពីរសៀវភៅសរសេរជាភាសាអង់គ្លេស "បរិលោក" និងសៀវភៅចុងក្រោយ គឺ

សរសេរដោយ ថម សយយ័រ ។ ចំណែកឯសៀវភៅដែលខ្លួនបានអាននៅក្រោយរបបខ្មែរក្រហមដួលរលំ រួមមានសៀវភៅ "ឆ្ងាយហួសដើនមេឃ" របស់លោកស្រី ឡូរ៉េន ពិច និងសៀវភៅ "អ្នកទោសខ្មែរក្រហម" ដែលជាព្រះរាជនិពន្ធរបស់សម្តេចព្រះនរោត្តម សីហនុ ។ សាក្សីបញ្ជាក់ថា ក្រៅពីនេះខ្លួនពុំដែលបានអានសៀវភៅផ្សេងឡើយ ។

មេធាវី កាណាវ៉ាស បានបន្តសួរទាក់ទងនឹងពាក្យសម្តីដែល ហ៊ុន ឈុនលី លើកឡើងថា ខ្លួនធ្លាប់លួចស្តាប់វិទ្យុសំឡេងសហរដ្ឋអាមេរិកក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ សាក្សីបានអះអាងថា ខ្មែរក្រហមមិនអនុញ្ញាតឲ្យនរណាម្នាក់ស្តាប់វិទ្យុទេ ប៉ុន្តែការដែលខ្លួនអាចស្តាប់គឺដោយសារតែខ្លួនយកវិទ្យុដែលមានទំហំធំល្មមនោះមកដាក់នៅក្នុងថង់ដែលមានមុងខ្នើយ ហើយយកមកបន្ទំធ្វើជាខ្នើយដេកដើម្បីបើកស្តាប់ ដោយដោតជាមួយនឹងកាសស្តាប់សំឡេងដើម្បីកុំឲ្យឮចេញមកក្រៅ ។ សាក្សីបានទទួលស្គាល់ថា ទង្វើរលួចអានសៀវភៅ និងលួចស្តាប់វិទ្យុនាពេលនោះ គឺជាការប្រថុយជីវិត ប៉ុន្តែដោយសារតែខ្លួនស្រេកឃ្លានចង់ស្តាប់ ចង់ដឹងព័ត៌មាន និងស្រេកឃ្លានចំពោះការអាន ។

ទាក់ទងនឹងការសរសេរសៀវភៅរបស់សាក្សី មេធាវី កាណាវ៉ាស បានសួរថា ក្រោយរយៈពេល ២៥ឆ្នាំសាក្សីមិនបានរៀបចំសរសេរកំណត់ត្រាឡើងវិញ បន្ទាប់ពីខ្លួនបានដុតចោលនោះទេ តើសាក្សីអាចសរសេរសៀវភៅមួយក្បាលដោយគ្រាន់តែព្យាយាមចងចាំអំពីព្រឹត្តិការណ៍ដែលខ្លួនធ្លាប់បានជួបប្រទះដោយរបៀបណាទៅ? ឈុនលី បានពន្យល់ថា ការឆ្លងកាត់បទពិសោធន៍នៅក្នុងជំនាន់ ប៉ុល ពត មិនអាចធ្វើឲ្យខ្លួនបំភ្លេចបានទេ ។ ចំណុចនេះហើយដែលជំរុញឲ្យខ្លួនមានបំណងសរសេរសៀវភៅជានិច្ច ។

សំណួរចុងក្រោយរបស់មេធាវី កាណាវ៉ាស បានផ្តោតជាសំខាន់លើផ្នែកមួយនៃសៀវភៅរបស់សាក្សីដែលរៀបរាប់អំពីវគ្គរៀនសូត្រនយោបាយដុសលាងខួរក្បាលនៅប្រទេសវៀតណាម នៅក្នុងអំឡុង ឆ្នាំ១៩៨៦ និងផ្នែកដែលពាក់ព័ន្ធនឹងការចង់លេបត្របាក់ទឹកដីប្រទេសកម្ពុជាដោយប្រទេសវៀតណាម ដើម្បីឲ្យសាក្សីពន្យល់ឲ្យបានច្បាស់ ។ ផ្នែកនោះបានសរសេរថា ៖

«នៅថ្ងៃបន្ទាប់ វិទ្យុកម្ពុជាបានប្រកាសឈ្មោះប្រទេសថ្មី គឺ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយមានកិច្ចព្រមព្រៀងរយៈពេល២៥ឆ្នាំជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ។ នៅក្នុងបញ្ហានេះ វាធ្វើឲ្យមានការប៉ះពាល់ដល់អារម្មណ៍របស់ខ្ញុំ គោលនយោបាយរបស់ប្រទេសកម្ពុជា ប្រជាជនកម្ពុជា ត្រូវបានធ្លាក់ចូលទៅក្នុងអន្ទង់នៃស្ថានភាពប្រហាក់ហែលគ្នា គឺវាមិនខុសពីអ្វីដែលយើងហៅថា ចុះទឹកក្រពើឡើងលើខ្លានោះឡើយ ។ គឺថា របបត្រូវ បានដឹកនាំដោយក្រុមពួកកុម្មុយនីស្ត ហើយប្រើប្រាស់របបកុម្មុយនីស្តដដែល ដែលគេប្រើប្រាស់ដើម្បីលេបទឹកដីកម្ពុជា គឺរបបនេះមកជំនួសរបបកុម្មុយនីស្តខ្មែរក្រហម ។ តាមពិតទៅស្ថានភាពកម្ពុជានៅក្នុងរបបខ្មែរក្រហម គឺវាហាក់បីដូចជា ធ្ងន់ធ្ងរពេកសម្រាប់វៀតណាម ។ ប្រសិនបើមិនមានរណសិរ្សរួបរួមជាតិកម្ពុជា វៀតណាមក៏មិនបង្កើតរណសិរ្សសង្គ្រោះជាតិ កម្ពុជា ហើយវៀតណាមក៏មិនមានលេសដើម្បីចូលមកឈ្លានពានប្រទេសកម្ពុជាដើម្បីបង្កើតរបបថ្មី បង្កើតជាសាធារណរដ្ឋប្រជាមានិតកម្ពុជាដើម្បីគ្រប់គ្រងដោយវៀតណាមនោះទេ ។ វាហាក់ដូចជាមានការប្លែកគ្នាបន្តិច ប៉ុន្តែអ្វីៗគឺដូចតែគ្នា ។ តើការស្រមើស្រមៃដ៏យូរលង់របស់ ហូជីមិញ អាចក្លាយជាការពិតដែរឬទេ? តើកម្ពុជាឈានទៅរកអ្វី? កូនចៅយើងនឹងមានអនាគតភ្លឺថ្លាឬទេ? ហើយសន្ធិសញ្ញា២៥ឆ្នាំមានន័យយ៉ាងដូចម្តេច? បើវាធ្វើឡើងរវាងអ្នកជួយ និងអ្នកសុំគេជួយដូច្នេះ?»

បន្ទាប់មកមេធាវី កាណាវ៉ាស បានសួរថា តើសាក្សីបានសរសេរឃ្លាទាំងអស់នេះនៅក្នុងសៀវភៅរបស់ខ្លួនដែរឬទេ? ហ៊ុន ឈុនលី អះអាងថា ឃ្លាទាំងអស់ខាងលើគឺខ្លួនបានសរសេរពិតមែន ។ ដោយភ្ជាប់នូវចម្លើយនេះ មេធាវីបានសួរបន្ថែមទៀតថា ហេតុអ្វីបានជាសាក្សីមានអារម្មណ៍ថាវៀតណាមលេបត្របាក់ផ្នែកខ្លះនៃប្រទេសកម្ពុជា ក្រោយកម្ពុជាត្រូវបានរំដោះ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបាននិយាយដោយសំដីមួយៗថា ៖ «នេះយល់ថាជាការធម្មតាទេ ប្រទេសមួយដែលមានបរទេសចូលមករំលំរបបមួយទៀត គឺដោយសារគេមានមូលហេតុច្បាស់លាស់ ។ ហើយដូចខ្ញុំសរសេរក្នុងសៀវភៅនេះដែរថា "ខ្មែរក្រហមគឺមានទំនាស់ជាមួយវៀតណាម ប៉ុន្តែខ្មែរក្រហមពេលដែលមាន

ទំនាស់ជាមួយវៀតណាមសម្លាប់ប្រជារាស្ត្រឯង" ។ ខ្ញុំសរសេរដែរថា "នរណាដែលមិនស្រឡាញ់ប្រទេសកម្ពុជា ប៉ុន្តែនរណាដែលមិនបន់ស្រន់ឲ្យខ្មែរក្រហមរលំរលាយ" ។ នេះខ្ញុំបានសរសេរអ៊ីចឹងបាទ ។"

មេធាវី កាណាវ៉ាស បានបញ្ជាក់នូវសំណួររបស់ខ្លួនម្តងទៀតថា តើអ្វីជាជំនឿរបស់សាក្សីដែលថា វៀតណាមលេបត្របាក់ប្រទេសកម្ពុជា? ប៉ុន្តែសំណួរដែលមេធាវីសួរបញ្ជាក់សារជាថ្មីនេះ ត្រូវបានជំទាស់ដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ ដោយផ្តល់ហេតុផលថា ការសួរសំណួរនេះមិនមានជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះលើកយកមកជំនុំជម្រះនៅក្នុងសវនាការ ដែលផ្តោតលើអង្គហេតុក្នុងចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ។ ឆ្លើយតបនឹងការជំទាស់នេះ មេធាវីកាណាវ៉ាស បានអះអាងថា អ្វីដែលខ្លួនសួរគឺមានការជាប់ពាក់ព័ន្ធដោយសារសាក្សីរូបនេះបានសរសេររៀបរាប់អំពីផែនការយូរអង្វែងរបស់ ហូជីមិញ ហើយប្រវត្តិសាស្ត្របានបង្ហាញថា វៀតណាមបានលេបត្របាក់កម្ពុជា ដែលនេះក៏ជាការភ័យខ្លាចមួយរបស់ខ្មែរក្រហមដែរ ។ បន្ទាប់ពីបានពិភាក្សាគ្នា អង្គជំនុំជម្រះបានសម្រេចយល់ស្របចំពោះការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា និងស្នើឲ្យមេធាវីប្តូរសំណួររបស់ខ្លួន ។



មន្ទីរពេទ្យមួយក្នុងរបបខ្មែរក្រហម ។ កម្មាភិបាលពេទ្យពីររូបកំពុងកូរថ្នាំ ។
(ថតដោយ ហ្គូណា ប៊ឺយស្ត្រួង នៅខែសីហា ឆ្នាំ១៩៧៨) (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មេធាវី កាណាវ៉ាស ហាក់បីដូចជាបានសម្តែងនូវការមិនពេញចិត្តរបស់ខ្លួនចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហានេះ ដោយស្នើសុំឲ្យអង្គជំនុំជម្រះបំភ្លឺឲ្យបានច្បាស់ ថាតើសហព្រះរាជអាជ្ញាអាចនិយាយអំពីភស្តុតាងទាក់ទងនឹងវៀតណាម ប៉ុន្តែមេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យនិយាយ ។ មេធាវីអះអាងទៀតថា ប្រសិនបើអង្គជំនុំជម្រះសម្រេចដូច្នេះ គឺមានន័យថាអង្គជំនុំជម្រះកំពុងប្រើប្រាស់ស្តង់ដារពីរចំពោះភាគីដែលរារាំងមិនឲ្យមេធាវីការពារក្តីលើកឡើងអំពីបរិបទនយោបាយ ឬបរិបទប្រវត្តិសាស្ត្រនៅក្នុងតុលាការមួយនេះ ។ អង្គជំនុំជម្រះបានឆ្លើយតបនឹងការលើកឡើងរបស់មេធាវី កាណាវ៉ាស ថាការសម្រេចរបស់អង្គជំនុំជម្រះ គឺផ្អែកតាមករណីជាក់លាក់នៃសំណួរនីមួយៗដែលសួរ និងការជំទាស់ដែលមានលក្ខណៈជាក់លាក់ ។

អង្គជំនុំជម្រះបានពន្យល់ទៀតថា ហ៊ុន ឈុនលី គឺមិនមែនជាអ្នកជំនាញផ្នែកប្រវត្តិសាស្ត្រទេ ។ ការណ៍ដែលអង្គជំនុំជម្រះកោះហៅសាក្សីរូបនេះមកផ្តល់សក្ខីកម្មក្នុងសវនាការ គឺក្នុងគោលបំណងស្តាប់អ្វីដែលសាក្សីបានដឹង បានឮ និងបានឃើញដោយផ្ទាល់នូវអង្គហេតុនៃការអនុវត្តគោលនយោបាយជម្លៀស និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋានតែប៉ុណ្ណោះ ។ បន្ទាប់មកមេធាវីការពារ កាណាវ៉ាស បានបញ្ចប់ការសួរដេញដោលរបស់ខ្លួន ។

ការផ្តល់សក្ខីកម្មរបស់សាក្សី ហ៊ុន ឈុនលី បានបញ្ចប់នៅព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ បន្ទាប់មក អង្គជំនុំជម្រះបានបន្តស្តាប់សក្ខីកម្មរបស់សាក្សីមួយរូបទៀត ដែលមានឈ្មោះ ខាំ ផាន់ ហៅ ផាន វ៉ាន ។

# សវនាការស្តាប់សក្ខីកម្មសាក្សី ផាន វ៉ាន

## ថ្ងៃទី១១-១៤ ខែធ្នូ ឆ្នាំ២០១២

កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបន្តបើកសវនាការសួរដេញ ដោលសាក្សី១រូបដែលមានឈ្មោះ ផាន វ៉ាន និងដើមបណ្តឹងរដ្ឋប្បវេណីជនជាតិបារាំង ១រូបឈ្មោះ ដេនីស អាហ៊ុងសូ ។ សវនាការនេះធ្វើឡើងឆ្លាស់គ្នាដោយថ្ងៃទី១១នេះ ការសួរដេញដោលសាក្សីធ្វើឡើង នៅពេលរសៀល និងនៅថ្ងៃបន្តបន្ទាប់ គឺធ្វើឡើងនៅពេលព្រឹកវិញ ។ ចំពោះការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី គឺធ្វើឡើងតាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសបារាំង ។ នៅក្នុងអំឡុងពេលសវនាការនេះមានប្រជាជនចំនួន១០០នាក់ដែលមកពីខេត្តកំពង់ធំ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩០នាក់ ដែលមកពីខេត្តចំនួន១០ផ្សេងគ្នា បានចូលរួមផ្ទាល់នៅក្នុងបន្ទប់សវនាការ ។ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអាននិងស្វែងយល់ ការសរសេររបាយការណ៍នេះត្រូវបានផ្តោតលើការកាត់ផ្តាច់សក្ខីកម្មនីមួយៗចេញពីគ្នាដូចខាងក្រោម ។ ដោយឡែកការសួរដេញដោលសាក្សី ផាន វ៉ាន ផ្តោតជាសំខាន់លើរបៀបបកប្រែសារទូរលេខខ្មែរក្រហម ការងារបើកបរនៅទីក្រុងភ្នំពេញ និងការចូលរួមក្នុងកិច្ចប្រជុំផ្សេងៗរបស់សាក្សី ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ នៅក្នុងការសួរដេញដោលសាក្សីតាមនីតិវិធីគឺ ប្រធានអង្គជំនុំជម្រះ ជាអ្នកចាប់ផ្តើមមុន ហើយបន្តបន្ទាប់មកគឺសហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយគឺមេធាវីការពារក្តី ។ ចំណែកឯការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីវិញ គឺមានការខុសគ្នាបន្តិចនៅត្រង់ថាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសួរមុនសហព្រះរាជអាជ្ញា ។

### ១) ប្រវត្តិសាវតាររបស់សាក្សី ផាន វ៉ាន

ឆ្លើយតបនឹងសំណួររបស់ចៅក្រម និល ណុន សាក្សីបានបញ្ជាក់ថា ខ្លួនមានឈ្មោះ ផាន វ៉ាន និងមានឈ្មោះដើម ខាំ ផាន់ សព្វថ្ងៃមានអាយុ ៥៣ ឆ្នាំ ប្រកបរបរធ្វើចំការនៅស្រុកម៉ាឡៃ ។ ឪពុកឈ្មោះ ឡាំង និងម្តាយឈ្មោះ ខាំ កន និងប្រពន្ធឈ្មោះ ហ៊ុន ឆវី ព្រមទាំងមានកូនបីនាក់ ។ សាក្សី បានបន្តថា ខ្លួនមានលទ្ធភាពអាចអាន និងសរសេរភាសាខ្មែរបានខ្លះៗ ។ បន្ទាប់មក ចៅក្រម និល ណុន បានសួរទាក់ទងនឹងការផ្តល់បទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ហើយសាក្សីបានបញ្ជាក់ថា ខ្លួនបានផ្តល់បទសម្ភាសន៍ចំនួនបីដងជាមួយសហចៅក្រមស៊ើបអង្កេតនៅស្រុកម៉ាឡៃ ។



សាក្សី ផាន វ៉ាន (ប្រភព: មជ្ឈមណ្ឌលឯកសារកម្ពុជា)

### ២) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ ដឺវ៉ាល់ដេស្នាឯល បានចាប់ផ្តើមការសួររបស់ខ្លួនដែលពាក់ព័ន្ធនឹងរយៈពេលមុនឆ្នាំ១៩៧០ ។ ឆ្លើយតបនឹងតំណាងសហព្រះរាជអាជ្ញា សាក្សីបានរៀបរាប់ថា ក្នុងអំឡុង ឆ្នាំ១៩៧០ ខ្លួនរស់នៅខេត្តមណ្ឌលគិរី ហើយបានរៀននៅក្នុងព្រៃជាមួយឪពុកម្តាយរបស់ខ្លួន ។ កាលណាខ្លួននៅចាំឈ្មោះ តាថងស៊ុ តាយ៉ា តាឡាំង និងតាវ៉ង់ ហៅវី និងឪពុករបស់ខ្លួនដែលជាអ្នកចូលរួមក្នុងចលនាតស៊ូនយោបាយនៅក្នុងព្រៃ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញា

អន្តរជាតិបានបន្តសួរទាក់ទងនឹងស្ថានភាពចាប់ពីឆ្នាំ១៩៧០ រហូតដល់ដើមឆ្នាំ១៩៧៤ ។ សាក្សីបានបញ្ជាក់ថា នៅមុនឆ្នាំ ១៩៧០ ខ្លួនមិនធ្លាប់បានជួប នួន ជា, អៀង សារី និង ខៀវ សំផន ឡើយ ហើយខ្លួនក៏មិនចាំច្បាស់អំពីទីតាំងមន្ទីរប-២០ដែរ ដោយគ្រាន់តែប្រហែលៗថា មន្ទីរនោះស្ថិតនៅក្នុងស្រុកស្ទឹងត្រង់ ។ សាក្សីបានបន្ថែមថាក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៤ ខ្លួនបានរៀនសូត្រ និងធ្វើជាអ្នករត់សំបុត្រឲ្យមេដឹកនាំខ្មែរក្រហមមួយចំនួនដូចជា នួន ជា, ហ៊ូ នឹម, ហ៊ូ យន់ និង ប៉ុល ពត នៅមន្ទីរប-២០ និងនៅភ្នំពេញបន្តទៀតគឺនៅពេលដែលមេដឹកនាំទាំងនោះរស់នៅក្នុងផ្ទះជាមួយគ្នា ។ សាក្សីបានបន្តថា ខ្លួនទើបតែបានដឹងនៅពេលក្រោយថា មន្ទីរប-២០គឺជាកន្លែងរបស់គណៈមជ្ឈិម និងមានការប្រជុំមេដឹកនាំជាន់ខ្ពស់នៅទីនោះ ។ សាក្សីក៏បានបញ្ជាក់ទៀតថា ឪពុករបស់ខ្លួនគឺជាគណៈតំបន់ ១០៥ដែលមានឈ្មោះហៅក្រោឡាំង និង ហម ប៉ុន្តែឈ្មោះទាំងនេះ ពុំមាននៅក្នុងសារទូរលេខឡើយ ។ តំបន់១០៥ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិម ដែលការរាយការណ៍ផ្សេងៗគឺធ្វើជូនមជ្ឈិមផ្ទាល់ តាមរយៈសារទូរលេខ ។

## ក) ការជម្លៀសប្រជាជន

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ ដឺវ៉ាល់ បានបន្តសំណួររបស់ខ្លួន ទាក់ទងនឹងការជម្លៀសប្រជាជន ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានរៀបរាប់ថា នៅពេលនោះពុំមានការជម្លៀសប្រជាជនពីភ្នំពេញទៅខេត្តមណ្ឌលគិរីទេ ។ ប៉ុន្តែ ពីឆ្នាំ ១៩៧៧ រហូតដល់ឆ្នាំ១៩៧៩មានការជម្លៀសប្រជាជនឲ្យមកនៅស្រុកកោះញែកដើម្បីធ្វើស្រែ ។ ប៉ុន្តែសាក្សីមិនបានស្គាល់អ្នកដែលចេញបញ្ជាក្នុងការជម្លៀសប្រជាជននោះទេ ។ តំណាងព្រះរាជអាជ្ញាបានបន្តសួរបញ្ជាក់ទាក់ទងនឹងទីតាំងនៃមន្ទីរបញ្ជាការកងពល៩២០ នៅភ្នំក្រោល ដែលស្ថិតនៅចម្ងាយប្រហែល៧គីឡូពីមន្ទីរប-២០ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា មន្ទីរក-១៧ និងតំបន់១០៥ គឺជាកន្លែងតែមួយគ្រាន់តែការហៅ មានលក្ខណៈខុសគ្នាតែប៉ុណ្ណោះ ហើយមានការបែងចែកជាផ្នែកៗ ។ មន្ទីរក-១៧មានការបែងចែកជាមន្ទីរសន្តិសុខ និងមន្ទីរដែលមើលការខុសត្រូវរួមមួយ ។

## ខ) កិច្ចប្រជុំផ្សេងៗ

តំណាងសហព្រះរាជអាជ្ញាបានបន្តសំណួររបស់ខ្លួនទាក់ទងនឹងកិច្ចប្រជុំនៅមន្ទីរក-១៧ ហើយសាក្សីបានឆ្លើយតបថា ខ្លួនពុំបានចូលរួមនៅក្នុងកិច្ចប្រជុំនោះទេ ដោយខ្លួនគ្រាន់តែបានដឹងថាអ្នកចូល រួមប្រជុំនោះគឺមានគណៈស្រុក និងសមាជិកមកពីស្រុកផ្សេងៗគ្នាដែលប្រជុំស្ទើរតែរាល់ខែ ។ អ្នកចូលរួមភាគច្រើន គឺជាកម្មាភិបាលបក្សដែលមកពីតំបន់១០៥ ។ នៅទីនោះមានការរៀបឲ្យមានការប្រជុំស្វ័យទិតៀនជាប្រចាំ ហើយខ្លួនក៏ធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំនោះដែរ ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងសន្និបាតរបស់បក្ស សាក្សីបានជម្រាបថា ខ្លួនធ្លាប់បានចូលរួម ក្នុងសន្និបាតបក្សនៅស្តាតអូឡាំពិចដែលរៀបចំដោយមន្ទីរ៨៧០ ។

## គ) ការបកប្រែសារទូរលេខ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរសាក្សីអំពីទំនាក់ទំនងរវាងតំបន់១០៥ និងគណៈមជ្ឈិមក្នុងអំឡុងពេលបំពេញការងារជាអ្នកបកប្រែសារទូរលេខជាមួយឪពុករបស់ខ្លួនដោយលើកយកសេចក្តីថ្លែងការណ៍ដែលសាក្សីបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា ក្រោយពេលចេញពីមន្ទីរប-២០ ខ្លួនធ្វើជាអ្នកបកប្រែសារទូរលេខ និរសា អ្នកបើកឡាននិងជាកងការពារឪពុករបស់ខ្លួនពេលធ្វើការនៅភ្នំក្រោល ។ ទាក់ទងនឹងការងារផ្នែកសារទូរលេខនេះ សាក្សីបានបញ្ជាក់ថា នៅទីនោះមានទាំងអ្នកទទួលទូរលេខ និងអ្នកបកប្រែ ។ សាក្សីបានបន្ថែមថា អ្នកដែលមានសិទ្ធិប្រើប្រាស់សារទូរលេខនៅតំបន់ ១០៥គឺមានតែឪពុករបស់ខ្លួនតែប៉ុណ្ណោះ ហើយពេលខ្លះខ្លួនត្រូវទៅបើកឡានជូន ឪពុកទៅកន្លែងផ្សេងៗ ដូច្នេះបងស្រីរបស់ខ្លួនឈ្មោះ សុវណ្ណ ហាន បានមកជំនួសការងារខ្លួនម្តងម្កាល ។ សាក្សីបានបញ្ជាក់ថា នៅពេលបំពេញកាងារនៅក្នុងបក្សឪពុកខ្លួនមិនដែលហៅខ្លួនថា កូនទេ គឺហៅថា “ក្លួយ”ដូចអ្នកផ្សេងទៀតដែរ ។

## ឃ) ការបោសសម្អាតនៅក្នុងបក្ស

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងទាក់ទងនឹងការសម្រេចចាប់ខ្លួនជនជាតិវៀតណាមនៅស្រុកកែវសីមា និងស្រែព្រះដោយកងទ័ពនៅតំបន់១០៥ ។ ឆ្លើយតបនឹងសំណួរនេះ

សាក្សីបានបំភ្លឺថា នៅពេលនោះការប្រយុទ្ធជាមួយវៀតណាមបានកើតឡើងជាប្រចាំនៅតាមព្រំដែន ហើយសេចក្តីសម្រេចផ្សេងៗត្រូវធ្វើឡើងដោយថ្នាក់លើ ។ សាក្សីបានបន្តទៀតថា ខណៈដែលខ្លួនធ្វើការនៅក្នុំក្រោល ខ្លួនពុំធ្លាប់ឃើញសេចក្តីសម្រេចអំពីការចាប់ខ្លួនមនុស្សឡើយ គឺមានតែអ្នកដែលត្រូវបានបញ្ជូនឲ្យទៅរៀនសូត្រតែប៉ុណ្ណោះ ។ ចំពោះការរៀនសូត្រផ្សេងៗ នួន ជា គឺជាអ្នកដែលទទួលខុសត្រូវក្នុងការកោះហៅកម្មាភិបាលដើម្បីចូលរួមសិក្ខាសាលាឬកិច្ចប្រជុំផ្សេងៗ ។ សាក្សីអះអាងថា កន្លងមក ក្រោយពេលដែលមានការបញ្ជូនទៅរៀនសូត្រ គឺអ្នកទាំងនោះមិនដែលត្រឡប់មកវិញទេរួមទាំងឪពុករបស់ខ្លួនផង ។ ក្រោយពេលដែលឪពុករបស់ខ្លួនស្លាប់ សាក្សីបានទៅធ្វើជាអ្នកដាំដំណាំវិញ ហើយក្រោយមកទើប អៀង ធីរិទ្ធ បានហៅខ្លួនឲ្យទៅបើកឡាននៅ មន្ទីរក-២ដែលមាន អៀង ធីរិទ្ធ ជាប្រធានមន្ទីរនោះ ។ ក្រោយមកសាក្សីបានដឹងថា អៀង ធីរិទ្ធ បានទៅជួបមេដឹកនាំខ្មែរក្រហមមួយចំនួនដូចជា ប៉ុល ពត, នួន ជា, អៀង សារី, ខៀវ សំផន, សុន សេន និងមេដឹកនាំផ្សេងៗទៀតនៅមន្ទីរក-៣ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹង សិទ្ធិអំណាចរបស់ អៀង ធីរិទ្ធ ថាតើ អៀង ធីរិទ្ធ មានសិទ្ធិដក កោះហៅប្រជុំ និងតាមដានបុគ្គលិកមន្ទីរពេទ្យដើម្បី ស្វែងរកខ្មាំងស៊ីរូងផ្ទៃក្នុងដែរឬទេ? ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា អៀង ធីរិទ្ធ គឺជាអ្នកទទួលខុសត្រូវនៅក្រសួងសង្គមកិច្ច ប៉ុន្តែរាល់ការសម្រេចផ្សេងៗត្រូវតែមានបញ្ជាពីថ្នាក់លើ ។

### ៣) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិ សំ សុគង់ បានចាប់ផ្តើមសួរសាក្សីទាក់ទងនឹងពេលវេលាដែលសាក្សីបានរត់ចូលព្រៃ ប៉ុន្តែសាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួននៅក្មេងមិនអាចចាំពីមូលហេតុ និងព្រឹត្តិការណ៍នានានៅក្នុងព្រៃនោះបានទេ។ បន្ទាប់មក មេធាវីបានសួរទាក់ទងនឹងមន្ទីរប-២០ ហើយសាក្សីបានឆ្លើយតបថា ក្រោយពេលរដ្ឋប្រហារឆ្នាំ១៩៧០ មេដឹកនាំខ្មែរក្រហមមួយចំនួនតែងតែមកប្រជុំគ្នានៅមន្ទីរប-២០ ដែលមានទីតាំងនៅខេត្តរតនគិរី ។ នៅទីនោះ ខ្លួនបានរៀនបកប្រែសារទូរលេខ និងបានរៀនសូត្រអំពីគោលនយោបាយរបស់បក្សខ្លះៗដែរ ប៉ុន្តែខ្លួនពុំបានចាំពីសេចក្តីលម្អិតនៃគោលនយោបាយនោះទេ ។

បន្ទាប់មក មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អ៊ីស្សាបែល ដៀវ៉ង់ បានបន្តការសាកសួរដេញដោលដោយឲ្យសាក្សីផ្តល់ព័ត៌មានអំពីស្ថានភាពនៅទីក្រុងភ្នំពេញក្នុងអំឡុងដើមឆ្នាំ១៩៧៥ ។ ជាការឆ្លើយតបសាក្សីបានលើកឡើងថា នៅពេលនោះទីក្រុងមានសភាពស្ងាត់ជ្រងំនៅពេលយប់ ហើយប្រជាជនមិនហ៊ានដើរចេញក្រៅផ្តេសផ្តាសឡើយ ។ បន្ទាប់មក មេធាវីបានសួរអំពីស្ថានភាពនៅទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៨ វិញ គឺនៅពេលដែលសាក្សីបើកឡានឲ្យ អៀង ធីរិទ្ធ ហើយសាក្សីបានបញ្ជាក់ថា នៅពេលនោះ មិនមានម៉ូតូបើកបរច្រើនទេ គឺមានតែកម្មករមួយចំនួន និងបុគ្គលិកដែលធ្វើការនៅតាមក្រសួង និងមន្ទីរផ្សេងៗតែប៉ុណ្ណោះ ។ សាក្សីបានបន្ថែមថា ក្នុងពេលបំពេញការងារជាអ្នកបើកឡាន សាក្សីពុំមានសិទ្ធិនិយាយស្តីជាមួយបុគ្គលិកនៅផ្នែកសង្គមកិច្ចផ្សេងទេ ប៉ុន្តែអាចនិយាយលេងតិចតួចតែប៉ុណ្ណោះដែលមិនពាក់ព័ន្ធនឹងការងារ ។ នៅមន្ទីរ ឬក្រសួងសង្គមនោះមានកិច្ចប្រជុំចំនួនពីរប្រភេទ គឺកិច្ចប្រជុំធម្មតាដែលហៅថាប្រជុំតៀន និងស្វ័យទិតៀនដែលអ្នកផ្សេងជាអ្នកកសាង ហើយសាម៉ីខ្លួនត្រូវប្តេជ្ញាថានឹងកែប្រែខ្លួន ។ មេធាវីអន្តរជាតិបានសួរសំណួរបន្ទាប់ទាក់ទងនឹងការបាត់ខ្លួនបុគ្គលិកនៅមន្ទីរពេទ្យខ្មែរ-សូវៀត ប៉ុន្តែសំណួរនេះត្រូវបានជំទាស់ពីមេធាវីការពារក្តី អៀង សារី គឺលោក អាង ឧត្តម ដោយលើកឡើងថា សំណួរនេះមិនពាក់ព័ន្ធ ។

### ៤) ការសួរដេញដោលដោយចៅក្រម ហ្សង់ម៉ាក ឡាវើញ

បន្ទាប់ពីបញ្ចប់ការសាកសួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រម ហ្សង់ម៉ាក ឡាវើញ បានចាប់ផ្តើមតាំងសំណួរទាក់ទងនឹងការស្លាប់របស់ឪពុកសាក្សី ហើយសាក្សីបានបញ្ជាក់ថា ក្រោយពេលដែលឪពុកខ្លួនត្រូវបានសម្លាប់ ខ្លួនបានឃើញសាកសពឪពុកនៅក្បែរគ្នានឹងសាកសពរបស់ពូខ្លួនដែរ ។ ប៉ុន្តែសាក្សីបានលើកឡើងថា ខ្លួនមិនសូវយល់ពីមូលហេតុនៃការស្លាប់របស់អ្នកទាំងពីរនោះទេ ដោយសារព័ត៌មានដែលខ្លួនទទួលបាននោះមិនច្បាស់លាស់ ។ ព័ត៌មាននោះបានបញ្ជាក់ថា ឪពុក និងពូរបស់ខ្លួនស្លាប់ដោយសារបាញ់គ្នាដែលជាហេតុធ្វើឲ្យខ្លួនមិនជឿ ។ ក្រោយពេលឪពុករបស់ខ្លួនស្លាប់ សាក្សីបានបន្តរស់នៅ

ជាមួយ អៀង ធីរិទ្ធ នៅឃុំអារីក្សត្រមួយរយៈទៀត ។ សាក្សីបានបន្តទៀតថា លេខាភូមិភាគឦសានឈ្មោះ យ៉ា ដែលត្រូវជាសាច់ញាតិរបស់ខ្លួន ប៉ុន្តែខ្លួនមិនដឹងថា យ៉ា មាន ឈ្មោះមួយទៀតថា ណៃ សារ៉ាន នោះទេ ។ ក្រោយមក យ៉ា ត្រូវបានប្រកាសថាជាជនក្បត់ និងជាខ្សែសម្ងាត់របស់វៀតណាម ។ ជាចុងក្រោយ ចៅក្រម ឡាវែរ៉ា បានលើកយកសារទូរលេខមួយចំ នួនមកសាកសួរដើម្បីឲ្យសាក្សីបញ្ជាក់ពីឈ្មោះអ្នកសរសេរសារ នោះប៉ុន្តែសំណួរភាគច្រើនត្រូវបានសាក្សីបដិសេធថា ខ្លួនមិនបានដឹងរឿង និងមិនស្គាល់បុគ្គលដែលមានឈ្មោះនៅក្នុងសារទាំងនោះ ។

## ៤) ការសួរដេញដោលដោយក្រុមមេធាវីការពារក្ដី

### ក) ក្រុមមេធាវីការពារក្ដី នួន ជា

មេធាវីអន្តរជាតិ អេនឌ្រូ អ៊ីនូហ្វ៊ី បានចាប់ផ្តើមសួរទាក់ទងនឹងទីលំនៅបច្ចុប្បន្នរបស់សាក្សីសំណួរមួយចំនួនទាក់ទងនឹងការគ្រប់គ្រងរបស់ តាសារុន ដែលបានជំនួសការងាររបស់ឪពុកខ្លួនជាលេខាតំបន់១០៥ ។ សាក្សីបានរៀបរាប់ថា ក្នុងអំឡុងពេលគ្រប់គ្រងរបស់ឪពុកខ្លួន គឺពុំមានការកាប់សម្លាប់ប្រជាជនកើតឡើងទេ ប៉ុន្តែនៅពេលដែល តាសារុន មកកាន់កាប់បន្ត ក៏ចាប់ផ្តើមមានការចាប់ខ្លួនប្រជាជនទាំងគ្រួសារៗ ប៉ុន្តែសាក្សីពុំបានដឹងថា ប្រជាជនដែលត្រូវបានចាប់ខ្លួននោះត្រូវបាននាំយកទៅសម្លាប់នៅទីណាទេ ។ មេធាវីអន្តរជាតិបានបន្តសួរទាក់ទងនឹងឈ្មោះ ហម ហើយសាក្សីបានបញ្ជាក់ថា ហម គឺជាឈ្មោះហៅក្រៅរបស់ឪពុកខ្លួនជាភាសាឡាវ ។ មេធាវីបានសួររំឭកអំពីវិន័យទាំង១២ប្រការ ប៉ុន្តែសាក្សីបានបំភ្លឺត្រង់ចំណុចនេះថា ប្រជាជនម្នាក់ៗមិនពេញចិត្តចំពោះវិន័យទាំងនោះទេ ប៉ុន្តែពុំមាននរណាម្នាក់ហ៊ានតវ៉ានោះឡើយ ដោយសារខ្លាចបក្សចោទថាក្បត់ ។ បន្ទាប់មក មេធាវី អេនឌ្រូ អ៊ីនូហ្វ៊ី បានសុំឲ្យសាក្សីធ្វើការប្រៀបធៀបពីការដឹកនាំរបស់ តាសារុន និង ខាំ ភួន ជាឪពុករបស់ សាក្សី ។ ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា ខ្លួនមិនអាចធ្វើការប្រៀបធៀបបានទេ ប៉ុន្តែខ្លួនគ្រាន់តែដឹងថា ក្រោយពេល តាសារុន មកគ្រប់គ្រងក៏មានការបាត់ខ្លួនប្រជាជនជាបន្តបន្ទាប់ ។ ដោយផ្អែកលើការយល់ដឹងរបស់ខ្លួន អ្នកដែលមានឋានៈត្រឹមភូមិភាគតែងតែគោរពតាមបញ្ជារបស់ថ្នាក់លើជានិច្ច ដោយពុំមាននរណាអាចសម្រេចតាមការយល់ឃើញរបស់ខ្លួនបានទេ ហើយនៅពេលនោះបុគ្គលគ្រប់រូបត្រូវតែកម្រិតនូវសិទ្ធិសេរីភាពរបស់ខ្លួន ។ មេធាវីអន្តរជាតិបានបន្តសួរទាក់ទងនឹងការផ្តល់សក្ខីកម្មរបស់ តាសារុន ថាតើអ្វីដែល តាសារុន បានឆ្លើយនោះពិតជាត្រឹមត្រូវដែរឬទេ? ហើយថាតើសក្ខីកម្មរបស់សាក្សីនៅពេលនេះជាការពិតដែរឬទេ? ពាក់ព័ន្ធនឹងករណីនេះ សាក្សីបានបញ្ជាក់ថា ខ្លួនពុំបានដឹងថា តាសារុន



យុវជនកងចល័តកំពុងហូបបាយរួមក្នុងរោងបាយស្ថិតនៅក្នុងខេត្តតា[...] ទៅជនបទ ក្នុងខែសីហា ឆ្នាំ១៩៧៨ (ថតដោយ ហ្គូណា ថិយស្រ្ត[...]

បានមកផ្តល់សក្ខីកម្មនៅក្នុងតុលាការទេ ហើយសក្ខីកម្មរបស់ខ្លួនក៏ពុំមានការនិយាយបំផ្លើសពីការពិតដែរ ។ សាក្សីបានបន្ថែមថា ការពិតមានមនុស្សជាច្រើនបានបាត់ខ្លួនមែន ។ មេធាវី អ៊ីនូហ្វ៊ី បានបន្តទៀតថា តើមានមូលហេតុអ្វីដែលលោក សៅ សារុន (តាសារុន) បដិសេធចំពោះ ការបាត់ខ្លួនប្រជាជនទាំងគ្រួសារនៅតំបន់១០៥? តើការឆ្លើយនេះដើម្បីរួចផុតពីភាពទទួលខុស

ត្រូវមែនដែរឬទេ? សាក្សីបានឆ្លើយតបថា ខ្លួនបានដឹងអំពីការបាត់ខ្លួនប្រជាជនពិតប្រាកដមែន ប៉ុន្តែខ្លួនមិនបានដឹងថា គាសារុន មានជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួននោះមែនឬយ៉ាងណា ហើយក៏ពុំបានដឹងថា គាសារុន បានទទួល បញ្ជាពីបុគ្គលណាមួយនោះដែរ ។ ជាការពិត នៅពេលនោះសូម្បីតែមនុស្សដែលស្មោះត្រង់ក៏ត្រូវបានចាប់ខ្លួនដែរ ។ មេធាវីបានអានអត្ថបទចំនួនបីរបស់មជ្ឈ



ំកែវ អំឡុងពេលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូប្រទេស ស៊ុយអែដ ង នៅខែសីហា ឆ្នាំ១៩៧៨) (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មណ្ឌលឯកសារកម្ពុជា ប៉ុន្តែអត្ថបទទាំងនោះត្រូវបានអង្គជំនុំជម្រះបដិសេធចោល និងមិនអនុញ្ញាតមឲ្យសាក្សីឆ្លើយតបនូវសំណួរទាំងឡាយទាក់ទងនឹងអត្ថបទនោះដោយផ្តល់ហេតុផលថា សំណួរទាំងនោះអាចនាំឲ្យសាក្សីធ្វើការសន្និដ្ឋានដែលចេញពីការយល់ដឹងជាអត្តនោម័តរបស់សាក្សី ។

មេធាវីបានសួរសាក្សីអំពីទំនាក់ទំនងរវាង នួន ជា ជាមួយក្រុមគ្រួសាររបស់សាក្សី ប៉ុន្តែ សាក្សីបានជម្រាបថា ខ្លួនមិនបានដឹងពីរឿងនោះច្រើនទេ ។ បន្ទាប់មក មេធាវីបានព្យាយាមសួរដេញ ដោលអំពីការទាក់ទងគ្នារវាង នួន ជា និងឪពុករបស់សាក្សី អំពីការជម្លៀស និងការផ្លាស់ទីលំនៅប្រជាជននៅតាមតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនពុំបានដឹងអំពីការផ្លាស់ទីលំនៅទាំងនោះទេ ។ លោកមេធាវីបានសួរពីឈ្មោះ គាត ឈន់ និង ស គឹមល្អុត ថាតើសាក្សីបានដឹងថា គាត ឈន់ ជាអ្នកណាដែរឬទេ? សាក្សីបានឆ្លើយបញ្ជាក់ថា ខ្លួនមិនដឹងពីមូលហេតុអ្វីនោះទេ ។ មេធាវីបានបញ្ជាក់ជាថ្មីថា បុគ្គលដែលខ្លួនលើកឡើងនោះសព្វថ្ងៃ គឺជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ។ សាក្សីនៅតែរក្សាជំហរដដែលថា ខ្លួនពុំចាំទេ ។ ក្រោយមក មេធាវីបានបន្តសួរទាក់ទងនឹងលោក ខៀវ កាញារីទ្ធ ពីមូលហេតុដែលលោកបដិសេធមិនព្រមចូលមកផ្តល់សក្ខីកម្មនៅក្នុងតុលាការ? ភ្លាមនោះចៅក្រម និល ណុន បានបង្គាប់មិនឲ្យសាក្សីឆ្លើយតបនឹងសំណួរទេដោយសារសំណួរនេះមិនពាក់ព័ន្ធ ។ មេធាវីបន្តសួរម្តង ហើយម្តងទៀតទាក់ទងនឹងចលនាក-៥ ដែលជាអង្គហេតុមួយផ្សេងទៀតមិនពាក់ព័ន្ធនៅក្នុងកិច្ចដំណើរការនីតិវិធី ។

ដោយសារតែកិរិយារឹងទទឹងរបស់មេធាវីអន្តរជាតិ អ៊ីណូហ្ស៊ី ទាក់ទងនឹងការតាំងសំណួរដែលមិនទាក់ទងនឹងអង្គហេតុ ចៅក្រម និល ណុន បានបង្គាប់ឲ្យមេធាវីចាកចេញពីបន្ទប់សវនាការបន្ទាប់ពីចៅក្រមជំនុំជម្រះបានពិភាក្សាគ្នារួចមក ។

បន្ទាប់មក ចៅក្រម និល ណុន បានផ្ទេរវេទិកាសាកសួរសាក្សីបន្តទៀតទៅមេធាវីជាតិ សុន អរុណ ។ មេធាវី សុន អារុណ បានចាប់ផ្តើមសំណួរបន្តពីសហភាគីរបស់ខ្លួន ទាក់ទងនឹងអាយុជាក់លាក់នៅពេលសាក្សីចូលរួមបដិវត្តន៍ ។ បន្ទាប់មក មេធាវីជាតិបានសួរឲ្យសាក្សីបញ្ជាក់អំពីសារទូរលេខ ហើយសាក្សីបានបញ្ជាក់ថា សារទូរលេខទាំងនោះគឺពិតជាសារទូរលេខនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពិតប្រាកដមែន ។

## ៥.២) ក្រុមមេធាវីការពារក្តី ខៀវ សំផន

មេធាវីជាតិការពារជនជាប់ចោទ ខៀវ សំផន គឺលោក គង់ សំអុន បានបន្តការសួរសំណួរទាក់ទងនឹងមន្ទីរក-១៧ នៅតំបន់ ១០៥ និងការរៀនសូត្ររបស់សាក្សីនៅមន្ទីរប-២០ ទាំងការ

រៀនអក្សរខ្មែរផង ។ សាក្សីបញ្ជាក់ថា នៅឆ្នាំ១៩៧៨ដល់ ១៩៧៧ ខ្លួនបាននៅធ្វើការជាអ្នកបកប្រែសារទូរលេខ ជាមួយឪពុករបស់ខ្លួននៅមន្ទីរក-១៧ ។ ចំណែកបទពិសោធជាអ្នកបកប្រែសារទូរលេខនៅមន្ទីក-១៧វិញ គឺពុំមានសារទូរលេខណាមួយដែលបង្ហាញពីបញ្ជាឲ្យចាប់ខ្លួនបុគ្គលណាមួយឡើយ ប៉ុន្តែមានមនុស្សមួយចំនួនត្រូវបានហៅឲ្យទៅធ្វើការ ហើយក្រោយមកអ្នកទាំងនោះក៏បានបាត់ខ្លួនជារៀងរហូត ។

បន្ទាប់មកមេធាវី អាកទូរ វែកគែន បានបន្តសួរសំណួរពីសហភាតារបស់ខ្លួនទាក់ទងនឹងការផ្តល់សក្ខីកម្ម នៅចំពោះមុខចៅក្រមស៊ើបអង្កេតកន្លងមក និងអំឡុងពេលដែលសាក្សីបម្រើការជាអ្នកបកប្រែសារទូរលេខនោះ ។ សាក្សីបានរៀបរាប់ថា នៅពេលនោះ ខ្លួនធ្លាប់ឃើញមានសារដែលជាបញ្ជារបស់ ហែម ទាក់ទងនឹងការបញ្ជូនស្រូវ ។ ចំណែកបញ្ហាសន្តិសុខវិញ គឺពុំមានការពាក់ព័ន្ធនឹង ខៀវ សំផន ទេហើយសារដែលឆ្លើយឆ្លងជាមួយ ហែម គឺធ្វើឡើងជាលក្ខណៈបើកចំហរ ដោយពុំមានប្រើលេខសម្ងាត់អ្វីឡើយ ។ ឆ្លើយតបនឹងសំណួររបស់មេធាវី ដែលមានប្រើពាក្យថា "ផ្ញើជូនមន្ទីរ៨៧០ ជាទីស្នេហា" សាក្សីបានបញ្ជាក់ថា ការប្រើឃ្លានេះពុំមែនសំដៅតែទៅលើ ប៉ុល ពត ម្នាក់ប៉ុណ្ណោះទេ គឺសំដៅទៅលើមេដឹកនាំរួមដែលនៅធ្វើការនៅទីនោះ ។


ប្រជាជនកម្ពុជាកំពុងលើកទំនប់ក្នុងខេត្តកំពង់ស្ពឺ (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ក) ក្រុមមេធាវីការពារក្តី អៀង សារី

មេធាវីអន្តរជាតិ ម៉ៃឃើល កាណាវ៉ាស បានចាប់ផ្តើមសំណួរទាក់ទងនឹងភាពខុសគ្នារវាងឆ្នាំកំណើត របស់សាក្សីដែលខុសគ្នាមួយឆ្នាំ ។ សាក្សីបានបំភ្លឺថាបញ្ហានេះកើតឡើងដោយសារការធ្វើអត្តសញ្ញាណប័ណ្ណតែប៉ុណ្ណោះ ប៉ុន្តែឆ្នាំកំណើតច្បាស់លាស់គឺខ្លួនកើតនៅអំឡុងឆ្នាំ១៩៦០ ។ បន្ទាប់មក មេធាវីបានបន្តសួរទាក់ទងនឹងការបម្រើការងារជាអ្នកបើកបររថយន្តជូនមេដឹកនាំខ្មែរក្រហម ទៅចូលរួមការប្រជុំនានានៅក្នុងទីក្រុងភ្នំពេញ ។ សាក្សីបានបញ្ជាក់ថា ខ្លួនមានភារកិច្ចត្រឹមតែជូនមេដឹកនាំទាំងនោះទៅកន្លែងប្រជុំតែប៉ុណ្ណោះ ចំណែកសមាភាពអ្នកចូលរួមប្រជុំ និងខ្លឹមសារប្រជុំយ៉ាងណានោះ ខ្លួនពុំបានដឹងទេ ។ មេធាវីបានសួរអំពីការងាររបស់ឪពុកសាក្សី និងការប្រជុំសម្ងាត់នានា ប៉ុន្តែសាក្សីបានបញ្ជាក់ថា ពេលនោះខ្លួនពុំបានដឹងទេអំពីការប្រជុំទាំងនោះ ដោយសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បក្សបានប្រើពាក្យថា "ការងារនរណា អ្នកនោះដឹង" មិនត្រូវដឹងការងាររបស់អ្នកដទៃទេ ។ ដូច្នេះកិច្ចការរបស់ឪពុកខ្លួន ខ្លួនពុំធ្លាប់បានសួរនោះឡើយ ។ បន្ទាប់មកទៀតមេធាវីក៏បានសួរសាក្សីអំពីការផ្តល់បទសម្ភាសន៍រវាងសាក្សីនៅចំពោះមុខចៅក្រមស៊ើបអង្កេត ដែលមានការកែតម្រូវក្នុងពេលកំពុងសម្ភាសន៍នោះបន្តិចបន្តួច ។ ត្រង់ចំណុចនេះសាក្សីបានទទួលស្គាល់ថា សហចៅក្រមស៊ើបអង្កេតពិតជាបានសួរសំណួរមួយចំនួនដើម្បីរំឭកដល់ការចងចាំរបស់ខ្លួន ប៉ុន្តែពុំមានការផ្តល់ឯកសារដើម្បីឲ្យខ្លួនពិនិត្យនោះឡើយ ។

ការសួរដេញដោលសាក្សី ផាន វ៉ាន បានបញ្ចប់ក្រោយពេលក្រុមការពារក្តីជនជាប់ចោទ អៀង សារី បញ្ចប់សំណួររបស់ខ្លួន ។

# សវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ដេនីស អាហ៊ុងសូ
## ថ្ងៃទី១១-១៤ ខែធ្នូ ឆ្នាំ២០១២

### ១) ប្រវត្តិសាវតាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដេនីស អាហ៊ុងសូ

ជាការចាប់ផ្ដើមចៅក្រម និល ណុន បានសួរសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិសាវតាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី អាហ៊ុងសូ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថាខ្លួនមានឈ្មោះ ដេនីស អាហ៊ុងសូ កើតនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៤៤ ក្នុងទីក្រុងភ្នំពេញ ។ សព្វថ្ងៃរស់នៅផ្នែកខាងត្បូងនៃប្រទេសបារាំង ជាមន្ត្រីនៅក្រសួងការបរទេសដែលចូលនិវត្តន៍ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្ថែមថា ខ្លួនមានឪពុកឈ្មោះ ម៉ូរីស លូស្យាង ជាជនជាតិបារាំង និងម្ដាយឈ្មោះ ទ្រូង ធីឡេ និងស្វាមីឈ្មោះ រ៉ូប៉ែ អែកម៉ាន ជាជនជាតិចិន ។ បន្ទាប់មកចៅក្រម និល ណុន បានបញ្ជាក់ប្រាប់ពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងសេចក្ដីទុក្ខសោកដែលបណ្ដាលមកពីការបាត់បង់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

### ២) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

មេធាវីជាតិ សំ សុគង់ បានចាប់ផ្ដើមតាំងសំណួរមួយចំនួនដែលទាក់ទងនឹងស្ថានភាពមុនការ ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

#### ក) ស្ថានភាពមុនថ្ងៃ១៧មេសា ១៩៧៥

ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅមុនថ្ងៃ១៧ ខែមេសា ខ្លួនរស់នៅទីក្រុងភ្នំពេញ នៅលើផ្លូវក្បែរយោធាជិតពេទ្យចិន ។ ពេលនោះលោកស្រីជាលេខានៅក្នុងក្រុមហ៊ុនជាច្រើន ហើយនៅចុងឆ្នាំ១៩៧៣ ខ្លួនធ្វើការខាងផ្នែកវប្បធម៌ឲ្យស្ថានទូតបារាំង ។ នៅពេលដែលសម្ដេច ព្រះនរោត្ដម សីហនុ ត្រូវបានទម្លាក់ពីអំណាចហើយ សេនាប្រមុខ លន់ នល់ ឡើងកាន់អំណាចជំនួសវិញ គឺនៅពេលនោះ កម្ពុជាចាប់ផ្ដើមមានសង្គ្រាមស៊ីវិល ។ ការរស់នៅកាន់តែលំបាកទៅៗរហូតដល់ឆ្នាំ១៩៧២ ទើបខ្លួនបានធ្វើការនៅរោងចក្រផលិតទឹកដោះគោប៉ុន្តែមានការលំបាកដោយសារតែពុំមានរូបធាតុដើមគ្រប់គ្រាន់ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តថា នៅពេលនោះខ្លួនបានទទួលព័ត៌មានតាមរយៈភ្នាក់ងារសារព័ត៌មានបារាំងថា ខ្មែរក្រហមទៅដល់ណាកំទេចនៅទីនោះ ហើយចំនួនប្រជាជនភៀសខ្លួនមកពីតាមជនបទមកភ្នំពេញក៏មានចំនួនច្រើនដែរ ។



ដើមបណ្ដឹងរដ្ឋប្បវេណី ដេនីស អាហ៊ុងសូ ក្នុង នៅក្នុងអំឡុងពេលនៃសវនាការកាត់ទោស ប៉ុល ពត និង អៀង សារី ក្នុងឆ្នាំ១៩៧៩ (ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

#### ខ) ស្ថានភាពនៅពេលជម្លៀសប្រជាជន

នៅថ្ងៃទី១៧ ខែមេសា ខ្លួនបានរៀបចំចេញទៅធ្វើការ ស្រាប់តែពួគេហៅកញ្ចៀវអបអរ និងបានឃើញយោធាស្លៀកពាក់ខោអាវខ្មៅ និងមានភ្នែកក្រហមៗ ។ នៅពេលនោះស្ថានទូតបារាំង បានស្នើសុំឲ្យប្រជាជនបារាំងចាកចេញ ប៉ុន្តែខ្លួនមិនចេញទៅដោយសុខចិត្តនៅជាមួយប្ដី និងកូននៅស្រុកខ្មែរ ។ ចាប់ពីថ្ងៃទី១៧ ខែមេសា ខ្លួនមិនអាចទៅកាន់ស្ថានទូតបារាំងរហូតហើយ មួយថ្ងៃក្រោយមកខ្មែរក្រហម បានប្រាប់ឲ្យប្រជាជនចេញពីផ្ទះតែពីរបីថ្ងៃប៉ុណ្ណោះ ដើម្បីគេចចេញពីការទម្លាក់គ្រាប់បែក ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថា ប្ដីរបស់ខ្លួនមានការទុកចិត្តទៅលើទាហានខ្មែរក្រហមណាស់ ដោយគិតថា សន្តិភាពនឹងកើតមាន ។ នៅពេលជម្លៀសប្រជាជន ខ្លួនបានឃើញយោធាស្លៀកពាក់ពណ៌បៃតងបីនាក់ លួចអីវ៉ាន់ពីក្នុងហាងមួយរួចយកមកដាក់នៅក្នុងឡានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយយោធាទាំងនោះ



យុវជនកំពុងធ្វើការក្នុងសិប្បកម្មដែកមួយកន្លែងក្នុង
អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ
(ថតដោយ ហ្គូណា ប៊ិយស្រ្តុង នៅខែសីហា ឆ្នាំ១៩៧៨)
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

បានអន្តុយនៅលើដីបូលឡាន ដោយបង្គាប់ឲ្យប្តីរបស់ខ្លួនបើកតាមផ្លូវទៅតាខ្មៅ ។ ពេលធ្វើដំណើរនោះទាហានបានបាញ់កាំភ្លើងឡើងលើដើម្បីងាយស្រួលធ្វើដំណើរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថាមិត្តភក្តិខ្លួនម្នាក់ ត្រូវបានខ្មែរក្រហមសម្លាប់ដែរដោយសារនៅរង់ចាំប្តី ។ ស្ថានភាពនៅពេលនោះមានការលំបាក ដោយសារតែមានមនុស្សដើរទាំង ក្មេងយំរញ៉េរញ៉ៃហើយសៀវភៅ និងលុយត្រូវបានគេយកទៅបោះចោលរប៉ាត់រប៉ាយពេញផ្លូវ និងមានមនុស្សស្លាប់ជាច្រើននាក់យ៉ាងអាសោច ។

## គ) ស្ថានភាពក្រោយពេលជម្លៀសប្រជាជន

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេម៉ានូអ៊ែលហ្សាកូមី បានបន្តការសួរទាក់ទងនឹងសមាជិកគ្រួសារ និងស្ថានភាពរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ ។ ដើមបណ្តឹងរដ្ឋប្បវេណីអាហុងសូបានរៀបរាប់ថា ពេលនោះខ្លួនបានទៅនៅក្នុងភូមិកោះទឹកវិល ហើយខ្មែរក្រហមបានតម្រូវឲ្យខ្លួនកាត់សក់ខ្លីស្លៀកពាក់ខោអាវខ្មៅបង្ខំឲ្យខ្លួន និងកូនធ្វើការដោយពុំមានអាហារហូបចុកគ្រប់គ្រាន់នោះឡើយ ។ ក្រៅពីនោះមានការស៊ើបពីប្រវត្តិគ្រួសារដែលដើមបណ្តឹងរដ្ឋប្បវេណីប្រៀបធៀបទៅនឹងគុកឥតជញ្ជាំង ដោយសារតែខ្មែរក្រហមតាមយាមឃ្លាំមើលជាប់ជានិច្ច ។ ដើមបណ្តឹងរដ្ឋប្បវេណី អាហុងសូ បានរៀបរាប់បន្តថា ពេលរស់នៅភូមិកោះទឹកវិលបានមួយអាទិត្យ ខ្មែរក្រហមបានកោះហៅប្រជាជនឲ្យទៅប្រជុំនៅវត្តព្រៃទួត ព្រមទាំងបានឃើញទាហានឡើងនិយាយកោតសរសើរចំពោះអង្គការយ៉ាងខ្លាំង ។ បន្ទាប់មកទាហាននោះបាននិយាយថា នៅមុនពេលបានទទួលជ័យជម្នះពួកបរទេសត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅប្រទេសខ្លួនវិញហើយហេតុអ្វីក៏នៅតែមានបរទេសនៅទីនេះទៀត ហើយបើមិនធ្វើការទេ នឹងត្រូវបាញ់សម្លាប់ចោល ។ ដើមបណ្តឹងបានបន្តថា ពាក្យទាំងនេះខ្លួននៅតែចាំមិនដែលភ្លេចឡើយ ។

មេធាវីបានបន្តសួរទាក់ទងនឹងហេតុការណ៍ដែលបានកើតឡើងចំពោះប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថាប្តីរបស់ខ្លួនជាមនុស្សចូលចិត្តឡូឡា និងបាននិយាយភាសាបារាំង និងអង្គុយគ្រេសជាមួយមិត្តភក្តិហើយមួយអាទិត្យក្រោយមកប្តីរបស់ខ្លួនត្រូវបានខ្មែរក្រហមមកហៅ ដោយសារមានអ្នកឆ្លើយដាក់ ។ នៅថ្ងៃបន្ទាប់ អាហុងសូ បានទទួលដំណឹងថា ប្តីរបស់ខ្លួនត្រូវបានបញ្ជូនទៅរៀនសូត្រ ប៉ុន្តែក្រោយមក ក៏បានបាត់ខ្លួនរហូត ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តរៀបរាប់អំពីរយៈពេលដែលខ្លួនត្រូវបានជម្លៀសទៅទីកន្លែងផ្សេងទៀត ។ ចំពោះនារីដែលមានស្វាមីត្រូវបានខ្មែរក្រហមចាប់ខ្លួនទាំងអស់ ត្រូវបានជម្លៀសតាមឡានទៅដល់ខេត្តពោធិ៍សាត់ ហើយនៅពេលនោះខ្លួនបានឃើញប្រជាជនស្លាប់ជាច្រើននាក់នៅលើឡាន ។ ចំណែកអ្នកដែលនៅមូលដ្ឋានស្រាប់មិនត្រូវបានអង្គការជម្លៀសឡើយ ។ ក្រោយពេលទៅដល់ពោធិ៍សាត់ និងសម្រាកបានបីថ្ងៃ ទើបមានរថភ្លើងមកដឹកប្រជាជនទាំងនោះបន្តទៅស្វាយស៊ីសុផុន ។ ពេលទៅដល់ទីនោះខ្មែរក្រហមបានបែងចែកប្រជាជនជាក្រុមៗ ដែលមាន១០គ្រួសារ ហើយមួយក្រុមៗមានត្រាក់ទ័រមកដឹកទៅដាក់នៅភ្នំលៀប ភ្នំទ្រយោង និងភ្នំត្រឡោក ។ ចំណែកខ្លួនបានទៅដល់ភ្នំលៀប ហើយនៅទីនោះប្រធានភូមិបានណែនាំថាក្រុមខ្លួនគឺជាប្រជាជនថ្មីហើយអ្នកដែលនៅទីនោះស្រាប់គឺជាប្រជាជនចាស់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្ថែមថា នៅទីនោះខ្លួនត្រូវបានខ្មែរក្រហមហៅថា "យាយបារាំងៗ" និងធ្វើការរុកគួនទាត់ធាក់ ទាញកអាវបង្ខំឲ្យខ្លួនទៅធ្វើការ ។ ខ្មែរក្រហមទាំងនោះមានអាយុប្រហែល ១៥ឆ្នាំតែប៉ុណ្ណោះ ព្រមទាំងមិនចេះអក្សរសោះឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ទៀតថា នៅពេលនោះ ខ្លួនមានជម្ងឺគ្រុនចាញ់ ប៉ុន្តែថ្នាំព្យាបាល គឺពុំមានអ្វីក្រៅពីស្លោស្លឹកឈើ ដើម្បីព្យាបាលប៉ុណ្ណោះ ចំណែកបងស្រីរបស់ខ្លួនដែលមានជំងឺនោះ ក៏បានស្លាប់នៅពេលនោះដែរ ដែលកូនប្រុសម្នាក់ សព្វថ្ងៃកំពុងមានជំងឺផ្លូវចិត្តថែមទៀត ។ ដើមបណ្តឹងរដ្ឋប្បវេណីបន្តទៀតថា ខ្លួនបានទទួលការរើសអើងដែលមានសភាពធ្ងន់ធ្ងរ ដោយសំអាងហេតុផលថា ខ្លួនដែលជាប្រជាជនថ្មីហូបតែបបរ ហើយអ្នកខ្លះទៀតក៏បានចាប់កន្លាត និងកណ្តូប ដើម្បីបរិភោគ ។ ចំណែកអ្នកខ្លះបានឈ្នោះជាមួយឆ្កែប្រជាជនចាស់ទៀតផង ដោយសារឆ្កែនោះមានរបស់ហូបល្អជាងខ្លួន ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានបន្តរៀបរាប់ជូនអង្គជំនុំជម្រះឲ្យបានជ្រាបអំពីការស្លាប់របស់ប្អូនប្រុស ក្មួយ និងកូនរបស់ខ្លួនដោយសារ

ពុំមានអាហារហូបចុកគ្រប់គ្រាន់ ។

### ៣) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ ដឺវ៉ាល់ ដេស្មាឯល បានចាប់ផ្តើមសំណួរទាក់ទងនឹង ការបាញ់គ្រាប់រ៉ុក្កែត មុនពេលរំដោះទីក្រុងភ្នំពេញ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ជាថ្មីថា នៅពេលនោះ ពិតជាមានការបាញ់ប្រោះ ដែលបណ្តាលឲ្យមានអ្នករបួស និងអ្នកជំងឺជាច្រើននាក់នៅតាមមន្ទីរពេទ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានសង្កេតឃើញថា នៅពេលយោធាខ្មែរក្រហមចូលមកដល់ យោធាទាំងនោះ ហាក់បីដូចជាមើលងាយប្រជាជនជាខ្លាំង ខណៈដែលប្រជាជនអបអរសាទរទទួល ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកពីស្ថានភាពនៅពេលចាកចេញពីទីក្រុងភ្នំពេញដោយបានបញ្ជាក់ថា នៅពេលនោះមានការសម្លាប់ទាហានលន់ នល់ ប៉ុន្តែពេលធ្វើដំណើរទៅតាមផ្លូវមានសាកសពភាគច្រើនជាប្រជាជនស៊ីវិល ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានសួរដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ឡើងវិញនូវអ្វីដែលខ្លួនបានឆ្លើយជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងស្ថានភាពជម្លៀសចេញពីទីក្រុង និងស្ថានភាពរស់នៅក្រោយពេលជម្លៀសនោះ ហើយដើមបណ្តឹងរដ្ឋប្បវេណី អាហ៊ុងសូ បានឆ្លើយតបស្របទៅនឹងអ្វីដែលខ្លួនបានលើកឡើងកន្លងមក ។

សហព្រះរាជអាជ្ញារងជាតិ ចាន់ តារាស្មី បានសាកសួរបន្តទាក់ទងនឹងមធ្យោបាយដឹកជញ្ជូនក្នុងពេលជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញនិងសំណួរមួយចំនួនទៀត ដែលទាក់ទងនឹងមេដឹកនាំខ្មែរក្រហម ប៉ុន្តែ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថាខ្លួនពិតជាពុំធ្លាប់បានជួបមេដឹកនាំខ្មែរក្រហមនៅពេលនោះទេ ។

### ៤) ការសួរដេញដោលដោយមេធាវីការពារក្តីជនជាប់ចោទ

មេធាវី ចាស្តេ ប៉ោ បានសួរទាក់ទងនឹងជនភៀសខ្លួនមកភ្នំពេញក្នុងរយៈពេលមុនឆ្នាំ១៩៧៥ ។ ដោយសារតែពេលវេលាកន្លងផុតយូឆ្នាំ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណី ពុំចាំពីចំនួនប្រជាជនភៀសខ្លួនចូល ទីក្រុងភ្នំពេញជាក់លាក់នោះទេ ដោយគ្រាន់តែដឹងថា នៅមុននោះមានប្រជាជនប្រហែល២លាននាក់ ហើយក្រោយមក គឺមានប្រហែល៣លាននាក់ ។ ប្រជាជនខ្លះមានបងប្អូនមកនៅជាមួយគ្នា ចំណែកប្រជាជនខ្លះរស់នៅតាមចិញ្ចើមផ្លូវ ។ ដើមបណ្តឹងរដ្ឋប្បវេណី ពុំបានចងចាំពីលក្ខខណ្ឌជីវិតរបស់អ្នកទាំងនោះយ៉ាងណាខ្លះនោះឡើយ ប៉ុន្តែតម្លៃទំនិញ នៅពេលនោះមានការឡើងថ្លៃជាគំហុក ។

ដើមបណ្តឹងរដ្ឋប្បវេណី បានបន្ថែមទៀតថា ប្រជាជនវៀតណាមដែលរស់នៅក្នុងរបប លន់ នល់ ត្រូវបានសម្លាប់ចោលនៅតាមផ្លូវនិងវត្ត ។ ម្តាយរបស់ខ្លួន ដែលជាជនជាតិវៀតណាមដែរនោះ មានការភ័យខ្លាចយ៉ាងខ្លាំង ដោយសារតែមានការសម្លាប់ប្រល័យពូជសាសន៍បែបនេះ ។ ទាក់ទងនឹងពាក្យថា “អង្គការ” ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ខ្លួនដំបូងគិតថាអង្គការគឺជាមនុស្សម្នាក់ជាក់លាក់ ប៉ុន្តែ ក្រោយមកទើបដឹងថា អង្គការគឺមិនមែនជាមនុស្សនោះទេ ហើយគ្រប់បទបញ្ជា ឬសេចក្តីសម្រេចពីមេភូមិ ឬអ្វីទាំងអស់តែងតែលើកឡើងដោយយោងទៅលើអង្គការជានិច្ចដោយមិនដឹងថា នរណាជាអ្នកដឹកនាំអង្គការនោះទេ ។ ទាក់ទងនឹងនិយមន័យនៃពាក្យ “អង្គការ” មេធាវីបានលើកឡើងនូវការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាហ៊ុងសូ ដែលធ្លាប់បានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការបដិវត្តប្រជាជនកម្ពុជាកាលពីឆ្នាំ១៩៧៩ ដោយអាននូវសាលក្រម និងសក្ខីកម្មនោះ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ខ្លួនមិនដឹងច្បាស់ពីពាក្យថា អង្គការមានន័យយ៉ាងណានោះទេ ប៉ុន្តែមិនអាចបកពាក្យនេះថាជារដ្ឋាភិបាលនោះឡើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមេធាវី ចាស្តេ ប៉ោ ជួយផ្តល់និយមន័យជាក់លាក់នូវពាក្យនេះផង ប៉ុន្តែមេធាវីឆ្លើយតបថាខ្លួនអាចពន្យល់បាន ប៉ុន្តែវាពុំមែនជាភារកិច្ចរបស់ខ្លួននោះឡើយ ។ អាហ៊ុងសូ បានជម្រាបជូនអង្គជំនុំជម្រះថាខ្លួនពុំបានកត់ត្រាថានរណាជាជនរងគ្រោះនៅក្នុងតុលាការបដិវត្តប្រជាជនកម្ពុជាក្នុងឆ្នាំ១៩៧៩ នោះទេ ដោយសារនៅពេលនោះខ្លួនបានទ្រហោយំ ដោយសារតែភាពសង្វេកខ្លាំងពេកនៃរបបខ្មែរក្រហម ។ អាហ៊ុងសូ បានបន្តទៀតថា ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ ប៉ុល ពត និង អៀង សារី នោះឡើយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែក្រោយមកទើបមានមន្ត្រីពេទ្យវៀតណាមម្នាក់បានប្រាប់ថា ប៉ុល ពត និង អៀង សារី គឺជាមេបង្ករហេតុ ទើបខ្លួនយល់ថាអ្នកទាំងពីរនេះហើយជាអ្នកបង្កើតឲ្យមានទុក្ខសោកវេទនារបស់យើងទាំងអស់គ្នា ។ ដូច្នេះនៅក្នុង

តុលាការបដិវត្តប្រជាជនកម្ពុជា ខ្លួនបានលើកយកឈ្មោះបុគ្គលទាំងពីរនោះមកបញ្ជាក់ជូនតុលាការនាពេលនោះ ។

## ៥) ការថ្លែងសេចក្តីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ដេនីស អាហ៊ុងសូ

ក្រោយពេលមេធាវីអន្តរជាតិការពារក្តី នួន ជា បានបញ្ចប់ការតាំងសំណួររបស់ខ្លួន អង្គជំនុំជម្រះបានផ្ទេរវេទិកាជូនទៅក្រុមការពារក្តីផ្សេងទៀត ប៉ុន្តែដោយសារពុំមានសំណួរអង្គជំនុំជម្រះបានផ្តល់វេទិកាជូនដើមបណ្តឹងរដ្ឋប្បវេណីដើម្បីថ្លែងពីទុក្ខសោករបស់ខ្លួន ។ ការថ្លែងទុក្ខសោកមានដូចតទៅ ៖

«សូមអរគុណច្រើនលោកប្រធាន ។ ខ្ញុំចង់ប្រកាសនៅថ្ងៃនេះថា ក្នុងរយៈពេលនោះខ្ញុំបានទទួលរងនូវការឈឺចាប់យ៉ាងខ្លាំងជីវិតខ្ញុំនេះគឺថា ធ្លាប់តែនៅក្នុងប្រទេសដែលមានសន្តិភាពបានធ្លាក់ចូលទៅក្នុងឋាននរក គឺឋាននរកប្រចាំថ្ងៃតែម្តង ហើយគេដកហូតយើង អ្វីៗរបស់យើងគ្រប់បែបយ៉ាងគេដកហូតយើងចេញពីផ្ទះ គេរឹបអូសបំផ្លាញចោលនូវអ្វីៗដែលយើងបានកសាងជីវិតខ្ញុំ ដែលរយៈពេល៣០ឆ្នាំនោះត្រូវបានបំផ្លាញខ្ទេចខ្ទីឲ្យក្លាយជាផេះផង់ ។ ខ្ញុំនៅតែមានព្យសនកម្មជាច្រើនមកលើខ្ញុំយើងមិនមានការថែទាំខាងផ្នែកពេទ្យមិនមានគ្រូពេទ្យ យើងទទួលរងនូវការខ្វះខាតអាហារ មិនមានអនាម័យ ខ្ញុំកើតនូវជំងឺជាច្រើន ជំងឺដែលសំខាន់បំផុតសម្រាប់ខ្ញុំនោះគឺខ្ញុំបានកើតរបេង ។ ប្រសិនបើកងទ័ពវៀតណាមមិនមកទាន់នោះទេ នោះគឺថាខ្ញុំស្លាប់បាត់ទៅហើយ គឺថាខ្ញុំបានព្យាបាល នៅមន្ទីរពេទ្យសាំងអង់ទាន់ គឺថាខ្ញុំកើតជំងឺគ្រុនចាញ់ទៀត ។ ជំងឺទាំងពីរនេះហើយ គឺថាខ្ញុំនៅតែមានស្លាកស្នាមជាប់ជានិច្ច ខ្ញុំនៅមានស្នាមនៃជំងឺគ្រុនចាញ់ ហើយជំងឺនេះដូចជានៅជាប់ខ្ញុំជាមួយខ្ញុំជានិច្ច ។ ហើយនៅពេលដែលយើងមានជំងឺគ្រុនញាក់ នៅពេលដែលគ្រុនចាញ់ហើយគេទាញអូសយើងចេញពីផ្ទះឲ្យយើងចេញទៅធ្វើការនៅក្នុងស្រែ នៅក្រោមកំដៅថ្ងៃហែងនោះ គឺថាខ្ញុំចង់សួរអស់លោកទៅមើលថាតើលោកប្រធានលោកមេធាវី លោក លោកស្រីចៅក្រមគិតទៅមើលថា តើខ្ញុំលំបាកវេទនាប៉ុណ្ណា ។ ខ្ញុំទទួលរងនូវការឈឺចាប់ទាំងផ្នែករាងកាយទាំងផ្នែកផ្លូវចិត្ត មិនអាចរៀបរាប់នូវអ្វីដែលបានកើតឡើងឲ្យអស់នោះទេ ជាដំបូងនោះគឺការជម្លៀស គេបណ្តេញយើងឲ្យចេញពីផ្ទះ គេមិនស្តាប់យើងទេ គេឲ្យយើងចេញ បើថាមិនចេញទេគឺថាយើងមិនអាចនៅបានទៀតទេ នៅពេលដែលគេបណ្តេញយើងចេញពីផ្ទះទៅដល់ស្រុកស្រែហើយ គេឲ្យយើងធ្វើការជាទម្ងន់ ហើយគេសើចចំអកយើងទៀត ព្រោះគេហៅខ្ញុំថា យាយបារាំង គេសើចចំអកចំពោះខ្ញុំ គេដកយកកូនពីខ្ញុំចេញ មិនឲ្យនៅជាមួយខ្ញុំ ហើយមិនប្រាប់ខ្ញុំថាយកទៅណាទៀត គេគ្រាន់តែប្រាប់ថាអង្គការនឹងមើលថែកូនរបស់អ្នកឯងហើយ មិនមែនជាកូនរបស់អ្នកឯងទេ គឺជាកម្មសិទ្ធិរបស់អង្គការមិនចាំបាច់ខ្វល់ពីកូនទេ ពួកវាមិនមែនជាកូនរបស់អ្នកឯងទៀតទេ ពីព្រោះថាពួកវាបានបំពាក់បំប៉នមនោគមវិជ្ជាអស់ហើយ ។ ហើយនៅពេលដែលកូនរបស់ខ្ញុំជិតស្លាប់នោះ គឺថាបានមួយកូនចាននោះក៏ខ្ញុំមិនអាចផ្តល់ឲ្យកូនស្រីខ្ញុំនោះធ្វើឲ្យកូនស្រីខ្ញុំស្លាប់ដោយអត់បាយ សូម្បីតែមួយកូនចាននោះ ខ្ញុំឈឺចាប់ខ្លាំងណាស់ ។ ខ្ញុំទទួលរងនូវព្យសនកម្មខ្លាំងណាស់ ហើយខ្ញុំអាចរៀបរាប់បានច្រើនផ្សេងទៀត ។ អ្វីដែលពួកនោះបានធ្វើនោះ តើសព្វថ្ងៃនេះគេបានដាក់ទោស ពួកអ្នកប្រព្រឹត្តអស់នេះហើយឬនៅ? សព្វថ្ងៃនេះគឺថាខ្ញុំនៅតែមានអារម្មណ៍ឈឺចាប់ ប៉ុន្តែខ្ញុំត្រូវតែខំរស់នៅដើម្បីកូនរបស់ខ្ញុំ ខ្ញុំត្រូវតែប្រឹងរឹងមាំ រឹងប៉ឹងឲ្យមានសុខភាពល្អ ។ ពួកគេបង្ខំឲ្យយើងធ្វើការ ហើយអស់ លោកគិតមើលថាបើសិនជាខ្ញុំវិញនោះតើត្រូវធ្វើយ៉ាងម៉េចដើម្បីចាកចេញពីស្ថានភាពបែបនេះនោះ? ហើយបើសួរខ្ញុំថាមានព្យសនកម្មអ្វីខ្លះនោះ គឺយើងគិតមើលទៅថាភាពសាហាវឃោរឃៅ ការធ្វើទារុណកម្ម ការវាយទាត់ធាក់ ហើយគ្រាន់តែយើងលួចស្ករត្នោតបន្តិចនោះ គេយកយើងទៅហាលថ្ងៃខ្ញុំ ហើយឲ្យគេមើលមេរៀនយ៉ាងម៉េចៗនោះ គឺគេធ្វើបាបយើង គេមិនគោរពសិទ្ធិមនុស្សទាល់តែសោះ ។ គេសម្លាប់មនុស្សស្រេចតែចិត្ត ។ យើងមិនមែនជាមនុស្សទេ គេចាត់ទុកដូចជាសត្វធាតុគឺគេលែងគិតយើងជាមនុស្សហើយ គេគិតថាយើងជាសត្វតែប៉ុណ្ណោះ ខ្ញុំនៅតែនិយាយម្តងហើយម្តងទៀតថា នៅពេលនោះគឺថា គ្រោះអត់ឃ្លាន នោះគឺថា រៀបចំត្រឹមត្រូវគេគ្រោងផែនការដើម្បីធ្វើម៉េចឲ្យប្រជាជនអត់ឃ្លានស្លាប់ឲ្យមានតែដៃទទេ ។ ហើយគេបានប្រាប់ថា បើសិនជាអត់បាយនោះម៉េចក៏ពួកយើងមិនស្លាប់ យើងក៏អត់បាយដែរ កុំបេះតែថាគេឲ្យ យើងអត់បាយ

ស្លាប់នោះ ។ គេមិនបានថែទាំ ព្យាបាលយើងទេ ពេលយើងឈឺ គ្មានថ្នាំសង្កូវឲ្យយើងព្យាបាលទេ គឺគេសម្លាប់យើង គេរៀបចំផែនការដើម្បីសម្លាប់យើងដោយការបង្អត់បាយយើងតែម្ដង ។ ដូច្នេះ ជារៀងរាល់ថ្ងៃនេះខ្ញុំសុបិន្តអាក្រក់រហូតនៅពេលយប់ គឺជាសុបិន្តមកលងខ្ញុំ ។ ខ្ញុំមិនអាចឈានជើងចូលមកប្រទេសកម្ពុជាទៀតទេ ទោះខ្ញុំស្រលាញ់កម្ពុជា តែខ្ញុំមិនអាចមកទេអស់រយៈពេលជាង ៣០ឆ្នាំមកហើយ ខ្ញុំមិនអាចលើកជើងឈានចូលទឹកដីកម្ពុជាបានទេ ព្រោះថាវាធ្វើឲ្យខ្ញុំនឹកឃើញសុបិន្តអាក្រក់ទាំងឡាយដែលខ្ញុំបានឆ្លងកាត់ ដែលខ្ញុំបានទទួលរង ។ ខ្ញុំក៏ដូចជាប្រជាជនកម្ពុជាដែរ គឺថាយើងមិនអាចទទួលរងទ្រាំទ្រនូវអំពើទាំងអស់នេះបានទេ ។ វាមានទំហំធំធេងណាស់ មិនមែនមានតែខ្ញុំម្នាក់ឯងទេ គឺថាមានមនុស្សរាប់លាននាក់ដែលទទួលរងនូវការឈឺចាប់ ។ ពួកគេឈឺចាប់ទាំងអស់គ្នា ។ ហើយថ្ងៃនេះ បើសិនជាអ្នកណាអាចរៀបរាប់ការឈឺចាប់បាន ពួកគេនឹងមានការធូរស្រាលហើយ ។ ខ្ញុំមិនអាចកសាងនូវជីវិតថ្មីបានទេ ដោយសារតែរឿងទាំងអស់នេះ ។ ឥឡូវនេះខ្ញុំនៅសល់តែកូនប្រុសម្នាក់គត់ ហើយកូនប្រុសរបស់ខ្ញុំហ្នឹងក៏មានបញ្ហាតក់ស្លុតរន្ធត់ជាប់ជានិច្ចព្រោះថា គេធ្វើទារុណកម្មវាដូច្នេះវានៅតែរន្ធត់ នឹកឃើញរឿងនោះឡើង វាមានការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំង ។ ដូច្នេះអ្នកដែលបានប្រព្រឹត្តនូវអំពើទាំងអស់នោះសូមឲ្យទទួលរងនូវកាត់ទោសឲ្យបានយុត្តិធម៌បំផុត ។

លោកប្រធានសូមអរគុណលោកប្រធាន ហើយសូមអរគុណដល់តុលាការទាំងមូលផងដែរ» ។



កូនកម្មាភិបាលខ្មែរក្រហមកំពុងអង្គុយនៅលើគ្រែដែកក្រោមផ្ទះមួយ
(ថតដោយ ហ្គូណា ប៊ិយស្រ្តុង នៅខែសីហា ឆ្នាំ១៩៧៨) (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្តាប់សក្ខីកម្មសាក្សី សួន កានិល

## ថ្ងៃទី១៤-១៧ ខែធ្នូ ឆ្នាំ២០១២

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ បន្ទាប់ពីបញ្ចប់ការសួរដេញដោលសាក្សី ខាំ ផាន់ ហៅ ផាន វ៉ាន អង្គជំនុំជម្រះសាលាដំបូងបានកោះហៅសាក្សីឈ្មោះ សួន កានិល ដែលជាអតីតអ្នកវាយសារទូរលេខក្នុងរបបខ្មែរក្រហមដើម្បីផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ សក្ខីកម្មរបស់សាក្សីរូបនេះផ្តោតជាសំខាន់ លើប្រព័ន្ធទំនាក់ទំនងការងាររវាងថ្នាក់មជ្ឈិម និងថ្នាក់មូលដ្ឋានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ការសួរដេញដោលសាក្សីរូបនេះចាប់ផ្តើមដោយសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងបន្ទាប់មកអង្គជំនុំជម្រះប្រគល់វេទិកាជូនមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។

ការផ្តល់សក្ខីកម្មរបស់សាក្សី សួន កានិល បានចំណាយពេល ២ថ្ងៃ គឺនៅថ្ងៃទី១៤ និងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ដោយមានការចូលរួមពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី ប្រជាជន សិស្សនិស្សិត និងអ្នកសង្កេតការណ៍អំពីកិច្ចដំណើរការនីតិវិធី ប្រមាណ ៤០០នាក់ មកពីរាជធានីភ្នំពេញ ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ។

### ១) ប្រវត្តិសាវតាររបស់សាក្សី

នៅមុនពេលប្រគល់វេទិកាជូនភាគីដើម្បីសួរដេញដោល ប្រធានអង្គជំនុំជម្រះ គឺចៅក្រម និល ណុន បានសាកសួរអំពីប្រវត្តិសាវតាររបស់សាក្សី សួន កានិល ។ ឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះ សួន កានិល បានរៀបរាប់ថា ក្រៅពីឈ្មោះ សួន កានិល ខ្លួនមានឈ្មោះហៅក្រៅថា នាង សព្វថ្ងៃមានអាយុ៥៩ឆ្នាំ មានទីកន្លែងកំណើតនៅភូមិឈូក ឃុំប្រលាយ ស្រុកស្ទោង ខេត្តកំពង់ធំ ។ មានមុខរបរជាកសិករ ។ សាក្សីមានឪពុកឈ្មោះ សួន ស៊ិន និងម្តាយឈ្មោះ ចាន់ គឹមហួត ហើយមានភរិយាឈ្មោះ ជីវ នី ឬ មាស នី និងមានកូន៦ ។

បន្ទាប់មកប្រធានអង្គជំនុំជម្រះបានជូនដំណឹងសាក្សីអំពីសិទ្ធិ និងករណីកិច្ចនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ។ សាក្សី កានិល បានបញ្ជាក់ថា ខ្លួនធ្លាប់ផ្តល់សក្ខីកម្មជាមួយការិយាល័យ សហចៅក្រមស៊ើបអង្កេតចំនួន២លើកនៅលំនៅដ្ឋានរបស់ខ្លួនផ្ទាល់ ។


សាក្សី សួន កានិល (ប្រភព៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

### ២) ការសួរដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវិន្ទ បានចាប់ផ្តើមសំណួរដំបូងទាក់ទងនឹងការចូលធ្វើបដិវត្តន៍របស់សាក្សី ដោយចោទសួរថា តើសាក្សីចូលធ្វើបដិវត្តន៍ដំបូងនៅទីកន្លែងណា និងនៅថ្ងៃខែឆ្នាំណា? សួន កានិល បានបញ្ជាក់ថា ខ្លួនបានចូលធ្វើបដិវត្តន៍នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧១ នៅឃុំខ្វាយ ស្រុកជីក្រែង ខេត្តសៀមរាប ។ សាក្សីបានបន្តថា នៅទីនោះខ្លួនបានទទួលការអប់រំផ្នែកសារទូរលេខពីសំណាក់កម្មាភិបាលខ្មែរក្រហមម្នាក់ ឈ្មោះ យឿន ។ និយមន័យនៃទូរលេខត្រូវបានបង្រៀននៅក្នុងវគ្គរៀនសូត្រនោះ ដើម្បីងាយស្រួលក្នុងការទាក់ទងជាមួយកងទ័ពទាំងអស់ ទាំងកងទ័ពជើងគោក ជើងទឹក និងជើងអាកាស ។ អំឡុងពេលចុងឆ្នាំ១៩៧២ ឬដើមឆ្នាំ១៩៧៣ ខ្លួនត្រូវបានផ្ទេរមកធ្វើការនៅរោងពុម្ពមួយដែលមានទីតាំងនៅក្នុងខេត្តកំពង់ចាម ។ នៅក្នុងរោងពុម្ពនោះមានការបោះពុម្ពទស្សនាវដ្តី "រស្មីបដិវត្តន៍" ហើយអ្នកដែលមានសិទ្ធិក្នុងការសម្រេចថា

ឯកសារណាត្រូវបោះពុម្ពនោះ គឺសិទ្ធិរបស់លេខាភូមិភាគ ។ សាក្សី បន្តថា ឯកសារទាំងនោះត្រូវបានចែកចាយទៅតាមតំបន់ និងស្រុក ដែលកម្មាភិបាលធ្វើការ ហើយកម្មាភិបាលភូមិភាគនៅពេលនោះឈ្មោះ ធុច ។ ក្នុងអំឡុងពេលធ្វើការនៅទីនោះ ខ្លួនក៏ធ្លាប់ឃើញទស្សនាវដ្ដីទង់បដិវត្តដែរ ប៉ុន្តែមិនត្រូវបានអនុញ្ញាតឲ្យអានទស្សនាវដ្ដីនោះទេ ដោយសារតែខ្លួនពុំមែនជាសមាជិកបក្ស ។

សាក្សីអះអាងថា ខ្លួនធ្លាប់បានរស់នៅជាមួយ កែ ពក នៅអំឡុងឆ្នាំ១៩៧៣ ពេលដែលកំពុងមានការវាយប្រហារខ្លាំងក្នុងខេត្តកំពង់ធំ ។ សាក្សីបន្ថែមថា កែ ពក គឺជាសេនាធិការភូមិភាគ ដូច្នេះ នៅពេលមានដំណឹងអ្វី កែ ពក នឹងរាយការណ៍ជូនលេខាភូមិភាគ ហើយលេខាភូមិភាគនឹងរាយការណ៍បញ្ជូនបន្តទៅថ្នាក់លើ ។ ការរាយការណ៍នេះ ធ្វើឡើងតាមរយៈសារទូរលេខ ។ នៅក្នុងឆ្នាំ១៩៧៣ធ្លាប់មានសារទូរលេខមួយត្រូវបានផ្ញើជូនមន្ទីរ៨៧០ ប៉ុន្តែគ្រាន់តែជាដំណឹងអំពីជ័យជម្នះតែប៉ុណ្ណោះ ។ នៅក្នុងឆ្នាំ១៩៧៤ សាក្សីត្រូវបានផ្លាស់មកធ្វើការនៅខេត្តសៀមរាប ដោយពុំដឹងអំពីការជម្លៀសប្រជាជននៅឧដុង្គ និងខេត្តក្រចេះឡើយ ។

ទាក់ទងនឹងការបែងចែកភូមិភាគ សាក្សីបានបញ្ជាក់ថា នៅក្រោយខែមេសា ឆ្នាំ១៩៧៥ ចាប់ផ្ដើមមានការបែងចែកភូមិភាគដោយ កែ ពក បានឡើងពីសេនាធិការភូមិភាគទៅជាប្រធានភូមិភាគឧត្ដរ ហើយនិងមានការបែងចែកជា៣តំបន់ គឺតំបន់៤១ ៤២ និង៤៣ ។

សាក្សីកត់សម្គាល់ថា សារទូរលេខគឺសរសៃរឈាមតភ្ជាប់រវាងថ្នាក់ក្រោម និងថ្នាក់លើ យ៉ាងមានប្រសិទ្ធភាពនៅពេលនោះ ។ ក្រៅពីសារទូលេខក៏មានការប្រើប្រាស់សំបុត្រដើម្បីទាក់ទងគ្នាដែរ ។

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា ឆវិន្ទ បានបន្តសាកសួរទាក់ទងនឹងការបាត់ខ្លួនរបស់កម្មាភិបាលដែលគ្រប់គ្រងនៅតាមតំបន់ និងកម្មាភិបាលថ្នាក់ក្រោម ។ សួន កានិល បានអះអាងថា ការចាប់ខ្លួនកម្មាភិបាលនៅក្នុងភូមិភាគឧត្ដរបានចាប់ផ្ដើមខ្លាំងនៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ តាមរយៈការហៅឲ្យទៅរៀនសូត្រ និងការផ្លាស់ប្ដូរទីកន្លែង បន្ទាប់មកអ្នកទាំងនោះក៏ត្រូវបានចាប់ខ្លួនតែម្ដង ។ សាក្សីបន្តថា ការហៅនោះធ្វើឡើងតាមរយៈសំបុត្រ និងសារទូរលេខ ដែលចេញមកពីថ្នាក់មជ្ឈិមតាមរយៈភូមិភាគ ។ សាក្សីបានបញ្ជាក់ថា មានកម្មាភិបាលមួយចំនួនត្រូវបានកោះហៅដោយមន្ទីរ៨៧០ ដើម្បីរៀនសូត្រនៅភ្នំពេញ មានដូចជា ឈ្មោះ សី ឈ្មោះ វៃ រាប និង លី ជាដើម ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រេនន័រ បានបន្តពីសហការីរបស់ខ្លួន ដើម្បីចោទសួរសាក្សីទាក់ទងនឹងការបញ្ជូនសារពីថ្នាក់មជ្ឈិមមកថ្នាក់ភូមិភាគដើម្បីចាប់ខ្លួនកម្មាភិបាលថ្នាក់ស្រុក និងថ្នាក់តំបន់ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា រេនន័រ បន្តសួរអំពីវិធីសាស្ត្រក្នុងការបញ្ជូនសារទូរលេខពីថ្នាក់មជ្ឈិមមកថ្នាក់ភូមិភាគ ។ សាក្សីបានពន្យល់ថា ការបញ្ជូនសារពីថ្នាក់មជ្ឈិមមកថ្នាក់ភូមិភាគធ្វើឡើងពីរដងក្នុងមួយថ្ងៃ គឺនៅម៉ោង ៨ព្រឹក និងម៉ោង៦ល្ងាច សារទូរលេខទាំងអស់ដែលផ្ញើមកពីថ្នាក់មជ្ឈិមគឺចេញជាលេខ បន្ទាប់មកទើបមានក្រុមបកប្រែសារទូរលេខ យកសារទាំងនោះមកធ្វើការបកប្រែឲ្យចេញជាអក្សរ និងមានក្រុមវាយម៉ាស ដើម្បីបញ្ជូនសារទាំងនោះទៅថ្នាក់តំបន់បន្តទៀត ។

### ៣) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឹម ម៉េងឃី បានចាប់ផ្ដើមសំណួររបស់ខ្លួន ដោយផ្ដោតសំខាន់លើទំនាក់ទំនងរវាងសាក្សី និង កែ ពក ។ សាក្សីបញ្ជាក់ថា ចាប់ពីឆ្នាំ១៩៧៥មក ខ្លួនពុំសូវមានទំនាក់ទំនងជិតស្និតជាមួយ កែ ពក ទៀតឡើយ ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងការជម្លៀស និងស្ថានភាពរស់នៅរបស់ប្រជាជននៅភូមិភាគកណ្ដាល សាក្សីបានអះអាងថា ខ្លួនពុំបានដឹងពីបញ្ហាទាំងអស់នេះទេ ។ ប៉ុន្តែខ្លួនធ្លាប់បានឃើញមានការជម្លៀសប្រជាជនពីភូមិភាគបូព៌ាឆ្លងកាត់ភូមិភាគកណ្ដាលនៅប៉ុន្មានថ្ងៃ មុនពេលរបបខ្មែរក្រហមដួលរលំ ។ ក្រោយពេលកងទ័ពវៀតណាមចូលមកដល់ទីនោះ ប្រជាជនដែលត្រូវបានជម្លៀសទាំងអស់នោះបានត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ។

មេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត ត្រូវបានផ្ដល់វេទិកាសួរដេញដោល



ក្មេងស្រីកំពុងត្បាញអម្បោះក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (ប្រភពរូប ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)



សកម្មភាពក្នុងរោងពុម្ពនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (ប្រភពរូប ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីសហភាគារបស់ខ្លួន។ មេធាវីរូបនេះបានចោទសួរដោយផ្តោតសំខាន់លើការជម្លៀសប្រជាជន ថាតើប្រជាជនទាំងនោះត្រូវបាននាំយកទៅទីណា? សួន កានិល បានបញ្ជាក់ថា ប្រជាជនទាំងនោះត្រូវបានជម្លៀសឲ្យទៅធ្វើទំបន់១មករា គឺមានទាំងប្រជាជនចាស់ និងប្រជាជនថ្មី ដែលមកពីគ្រប់ទីកន្លែង ហើយទំបន់នេះបានប្រើរយៈពេលកសាងជាង១ឆ្នាំ ដោយប្រើកម្លាំងប្រជាជនសុទ្ធសាធ។ សាក្សីបន្តថា ប្រជាជនទាំងនោះត្រូវបានកំណត់លក្ខខណ្ឌការងារ និងរបបអាហារយ៉ាងតឹងរឹង។

## ៤) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីជាតិការពារក្តីជនជាប់ចោទ នួន ជា គឺមេធាវី សុន អរុណ បានចាប់ផ្តើមសំណួរពាក់ព័ន្ធនឹងទស្សនាវដ្តីទង់បដិវត្តថា តើសាក្សីធ្លាប់បានឃើញទស្សនាវដ្តីនេះដែរឬទេ? សាក្សីបានបញ្ជាក់ថា ក្នុងអំឡុងពេលធ្វើការនៅរោងពុម្ពនៅក្នុងឆ្នាំ ១៩៧៣ ខ្លួនធ្លាប់បានឃើញទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីរណៈសិរ្សរួបរួមជាតិ ប៉ុន្តែពុំមានសិទ្ធិអានទស្សនាវដ្តីទាំងនោះឡើយ។

ទាក់ទងនឹងការចាប់ខ្លួនកម្មាភិបាល មេធាវី អរុណ បានដកស្រង់សក្ខីកម្មដែលសាក្សីធ្លាប់បានផ្តល់ជូនចៅក្រមស៊ើបអង្កេតថា កែ ពក ពុំដែលសម្រេចចាប់ខ្លួនអ្នកនៅក្រោមបង្គាប់ដោយចិត្តឯងឡើយ គឺត្រូវមានការសម្រេចពីថ្នាក់មជ្ឈិម។ ឆ្លើយតបនឹងការលើកឡើងនេះ សាក្សីបានពន្យល់ថា មូលហេតុដែលខ្លួនហ៊ាននិយាយដូច្នេះ ដោយសារនីរសារដែលទទួលបញ្ជាឲ្យចាប់ខ្លួនប្រាប់ខ្លួន។ ម៉្យាងវិញទៀត អ្នកដែលត្រូវបានចាប់ខ្លួន គឺត្រូវបានបញ្ជូនទៅទីក្រុងភ្នំពេញ ហើយ កែ ពក ក៏ធ្លាប់បញ្ជាក់ដែរថា ទាល់តែមានបញ្ជាពីថ្នាក់លើ ហើយមានឈ្មោះនៅក្នុងសំបុត្រទើបខ្លួនហ៊ានចាប់។ ជាទូទៅអ្នកដែលត្រូវចាប់ខ្លួន គឺសុទ្ធសឹងជាកម្មាភិបាលដែលមានតួនាទីខ្ពស់ ចំណែកឯកម្មាភិបាលថ្នាក់ក្រោមខ្លួនមិនដឹងថា ការចាប់នោះមានបញ្ជាពីថ្នាក់លើឬយ៉ាងនោះទេ។

បន្ទាប់មក មេធាវី អរុណ បន្តសួរអំពីភាពខុសគ្នារវាងពាក្យជូន និង ចម្លងជូន។ ឆ្លើយតបនឹងសំណួរនេះ កានិល បានបញ្ជាក់ថា ជូន មានន័យថា ជូនទៅបុគ្គលណាម្នាក់។ ប៉ុន្តែបើ ចម្លងជូន គឺ ជូនទៅបុគ្គលផ្សេងៗទៀតដើម្បីដឹងជាព័ត៌មាន។ មេធាវីបានលើកឡើងអំពីសារទូរលេខ លេខ១២ ដែលបញ្ជាក់ថា សារទូរលេខនេះត្រូវបានផ្ញើជូនគណៈ៨៧០ និងចម្លងជូន អ៊ំ នួន អ៊ំខៀវ..។



ព្រះអង្គម្ចាស់ សុផា ណាវង្ស នៃប្រទេសឡាវកំពុងចាប់ដៃជាមួយកុមារក្នុងការដ្ឋានសំណង់មួយកន្លែង ដោយមានការអមដំណើរពីសំណាក់ ខៀវ សំផន (រូបឆ្វេង) (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

សាក្សីបញ្ជាក់ថា គណៈ៨៧០ គឺសំដៅលើអ្នកទាំងអស់ដែលធ្វើការនៅមន្ទីរ៨៧០។

សូមបញ្ជាក់ថា ក្រុមមេធាវីការពារក្តី ខៀវ សំផន និង អៀង សារី បានចំណាយពេលប្រហែល ១០នាទី ដើម្បីស្នើឲ្យ សួន កានិល បញ្ជាក់ឡើងវិញនូវចំណុចដែលខ្លួនយល់ថាពុំទាន់មានភាពច្បាស់លាស់តែប៉ុណ្ណោះ។

សវនាការស្តីពីការផ្តល់សក្ខីកម្មរបស់សាក្សី សួន កានិល បានបញ្ចប់នៅព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០១២។ មុនពេលបញ្ចប់អង្គជំនុំជម្រះបានជូនដំណឹងអំពីការផ្អាកកិច្ចដំណើរការនីតិវិធីសវនាការពេលរសៀល ដោយសារសាក្សីដែលត្រៀមនឹងចូលមកផ្តល់សក្ខីកម្មបន្ទាប់ពីសាក្សី សួន កានិល បានទទួលរងគ្រោះថ្នាក់ចរាចរណ៍ ដែលមិនអាចចូលមកផ្តល់សក្ខីកម្មនៅក្នុងរបស់តុលាការបាន។

សូមបញ្ជាក់ថា ដោយសារមានការឈប់សម្រាកបំណាច់ឆ្នាំ អង្គជំនុំជម្រះបានផ្អាកកិច្ចដំណើរការនីតិវិធីសវនាការរហូតដល់ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៣។

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ វ៉ាន់ថាន់ ពៅដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

ប្រជាជន១៧មេសា ៖ គឺជាជនស៊ីវិលទាំងឡាយដែលត្រូវបានជម្លៀសពីទីក្រុង ឬទីប្រជុំជននានាបន្ទាប់ពីការដួលរលំនៃរបបសាធារណរដ្ឋខ្មែរនៅខែមេសា ឆ្នាំ១៩៧៥ ។ ប្រជាជនទាំងនេះត្រូវបានខ្មែរក្រហមហៅម្យ៉ាងទៀតថា "ប្រជាជនថ្មី" ឬ"ប្រជាជនបញ្ញើ" ។

ប្រជាជនមូលដ្ឋាន ៖ គឺជាជនទាំងឡាយណាដែលរស់នៅតាមតំបន់ជនបទគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាមុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ប្រជាជនទាំងនេះត្រូវបានខ្មែរក្រហមហៅម្យ៉ាងទៀតថា "ប្រជាជនចាស់" ។


មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥
ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨
អ៊ីម៉ែល ៖ dccam@online.com.kh
គេហទំព័រ ៖ www.dccam.org ឬ
www.cambodiatribunal.org


គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ *Bureau of Democracy, Human Rights, and Labor, U.S. Department of State* ។

| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | អៀង ធីរិទ្ធ | ភា | (អត់ដឹង) | E1/54.1 |







**ឆាយ ឈុនលី**
បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**លីម ជ័យច័ត្ត**
បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិទទួលបានពានរង្វាន់មេដាយមាសក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។

**ខី សុជាតា**
បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**ចាន ប្រាថ្នា**
បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



ទាហាននៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាកំពុងឈរនៅលើផ្លូវ សាល ដឺហ្គោល ក្នុងទីក្រុងភ្នំពេញ ក្នុងខែមករា ឆ្នាំ១៩៧៩ ។
រូបខាងក្រោយ គឺជាផ្សារធំថ្មី ។ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)